ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 24-Jun-2014, 12:49
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៩នាទី**

**សវនាការលើកទី១៨៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី
*(Ms. Faiza ZOUAKRI)*

កញ្ញា មីរីអ៊ាម ម៉ាហ្វេសាន់ទិ
*(Ms. Miriam MAFESSANTI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

កញ្ញា សុង ឆរ័ត្ន

លោក ឃីត រេយន័រ *(Mr. RAYNOR Keith)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ(*Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ប៉ាស្កាល់ អូប៊ីង *(Mr. Pascal AUBOIN)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

លោកស្រី បេនី យេ *(Ms. Ms. Beini YE)*

លោកស្រី ម៉ារី ហ្គីរ៉ូដ *(Ms. Marie GUIRAUD)*

លោក អេមម៉ានូអ៊ែល ហ្សាកូមី

*(Mr. Emmanuel JACOMY)*

លោកស្រី កាទ្រីណា ម៉ារី ណាតាលី

*(Ms. Katrina Marie Natale)*

លោក ហុង គីមសួន

លោក សំ សុគង់

លោក ឡោ ជុនធី

លោក គីម ម៉េងឃី

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ប្រធានអង្គជំនុំ (ចៅក្រម និល ណុន) | ខ្មែរ |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី គ្រីស្ទីន ម៉ាទីណូ | បារាំង |
| លោកស្រី ទី ស្រ៊ីនណា | ខ្មែរ |
| លោក ប៉ាស្កាល់ អូប៊ីង | បារាំង |
| លោកស្រី ធុច ផាន់ដារ៉ា-ស (TCCP-156) | បារាំង |
| លោកស្រី ចាន់ សុភាព ហៅ ចាន់ សុជាតិ (TCCP-7) | ខ្មែរ |
| លោកស្រី អេង អេងលី (TCCP-13) | ខ្មែរ |
| លោកស្រី ហូ ចន្ថា (TCCP-198) | ខ្មែរ |
| លោក ខៀវ សំផន | ខ្មែរ |
| លោក នួន ជា | ខ្មែរ |

# ឧបសម្ព័ន្ធ

# ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី

**លោកស្រី ឆុច ផាន់ដារា-ស** (TCCP-156)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ..........................................ទំព័រ ២
សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ ផ្តើមពី ..........................................ទំព័រ ៩
សួរដោយលោក ឃីត រេយ៍ន័រ ផ្តើមពី..........................................ទំព័រ ២២
សួរដោយលោក សុន អរុណ ផ្តើមពី ..........................................ទំព័រ ២៥
សួរដោយលោក រ៉ិចឆ័រ កូប៉េ ផ្តើមពី..........................................ទំព័រ ២៧


**លោកស្រី ចាន់ សុភាព ហៅ ចាន់ សុជាតិ** (TCCP-7)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ..........................................ទំព័រ ៣០
សួរដោយលោកស្រី គ្រីស្ទីន ម៉ាទីណូ ផ្តើមពី ..........................................ទំព័រ ៣៩
សួរដោយលោក ឃីត រេយ៍ន័រ ផ្តើមពី..........................................ទំព័រ ៤៣
សួរដោយលោក គង់ សំអុន ផ្តើមពី ..........................................ទំព័រ ៤៦


**លោកស្រី ឆេង អេងលី** (TCCP-13)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ..........................................ទំព័រ ៤៩
សួរដោយលោក ប៉ាស្កាល់ អូប៉ីង ផ្តើមពី..........................................ទំព័រ ៧២
សួរដោយលោក សេង ប៊ុនឃាង ផ្តើមពី..........................................ទំព័រ ៧៧


**លោកស្រី ហូ ចន្ថា** (TCCP-198)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ..........................................ទំព័រ ៥២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៩:២២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការថ្ងៃនេះ អង្គជំនុំជម្រះបន្តស្តាប់នូវសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មនូវរបស់ដើម្បីរដ្ឋប្បវេណីមួយចំនួនតាមកាលវិភាគដែលបានគ្រោងទុក និងបានជម្រាបជូនភាគីរួចហើយកាលពីថ្ងៃចន្ទ ដើមសប្តាហ៍នេះ។

លោក ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះដែលកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

[០៩:១០:២១]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ គ្រប់ភាគីនៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួននៅខាងក្រោមបន្ទប់សវនាការតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយមូលហេតុបញ្ហាសុខភាព។ ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់សក្ខីកម្មថ្ងៃនេះមានចំនួន៤នាក់។ ទី១ គឺដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-156។ ទី២ គឺដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-7។ ទី៣ គឺដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-13។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនឹងធ្វើសក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ពីប្រទេសបារាំង។ ទី៤ គឺដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-198។ ដើមបណ្តឹងរដ្ឋប្បវេណីទាំង៣រូបមានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ លោក ផារី។ មន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី TCCP-156 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[០៩:១៣:១០]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរុណសួស្តីលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ តើលោកស្រីឈ្មោះអី?

**លោកស្រី ធុច ផាន់ដារា-ស៖**

**ធ៖** ចាស ខ្ញុំឈ្មោះ ខ្ញុំសូមឈ្មោះ ធុច ផាន់ដារា-ស។

**ស៖** បាទអរគុណលោកស្រី ផាន់ ដារា។ ទី១ អង្គជំនុំជម្រះសូមជម្រាបជូនលោកស្រីថា លោកស្រីមុននឹងមានប្រសាសន៍ លោកស្រីរងចាំមើលក្បាលមីក្រូហ្វូននេះ វាឲ្យភ្លើងសញ្ញាសិន មានន័យថាក្បាលមីក្រូហ្វូនចាប់ផ្តើមប្រតិបត្តិការ។ សំឡេងរបស់លោកស្រីពេលដែលលោកស្រីនិយាយទៅ វាចូលក្នុងប្រព័ន្ធចែកចាយសំឡេងសម្រាប់ភាគីដែលពាក់ព័ន្ធទាំងអស់ ហើយជាពិសេសគឺសម្រាប់ផ្តល់ទៅអង្គភាពបកប្រែភាសា គេនឹងបកប្រែភាសាលោកស្រីជាពីរភាសាទៀត គឺភាសាបារាំង និងភាសាអង់គ្លេសដែលប្រើប្រាស់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ។ បាទគ្រាន់តែបង្អង់បន្តិចទៅហើយខាងសោតទស្សន៍ហ្នឹង ខាងបុគ្គលោកសោតទស្សន៍ គេនឹងសម្របសម្រួលបញ្ហាក្បាលមីក្រូហ្វូនហ្នឹងហើយ ដើម្បីសម្រួលដល់ការបកប្រែភាសាឲ្យបានពេញលេញ។

តើលោកស្រីមានអាយុប៉ុន្មាន?

[០៩:១៤:២២]

**ស៖** ខ្ញុំសូម ខ្ញុំសំណូមពរលោកប្រធានចាស។ ព្រោះខ្ញុំចង់និយាយថ្លែងការណ៍ជាភាសាបារាំង ព្រោះគ្រួសារខ្ញុំ -- សូមអនុញ្ញាតលោកប្រធានចាស។ ព្រោះគ្រួសារខ្ញុំនៅស្រុកបារាំងសុទ្ធតែបារាំងទាំងអស់ កូនចៅ គ្រួសារ ហើយនិងសាច់ថ្លៃ ក្មួយ សុទ្ធតែអត់ចេះនិយាយខ្មែរ។ ហើយពេលហ្នឹងគេចាំស្តាប់ខ្ញុំថ្លែងការណ៍ចាស។ សូមអនុញ្ញាតពីលោកប្រធាន!

**ធ៖** បាទ មិនអីទេ! អង្គជំនុំជម្រះអនុញ្ញាតក្នុងការប្រើប្រាស់ភាសាទាំងបីនេះនៅក្នុងកិច្ចដំណើរការសវនាការនេះ គឺអាចធ្វើទៅបានបាទ។ អ៊ីចឹងអនុញ្ញាតឲ្យប្រើប្រាស់ជាភាសា និយាយលោកស្រីនិយាយជាភាសាៗបារាំងចុះ។ សូមអ្នកបកប្រែភាសារៀបចំនូវការបកប្រែភាសាផ្លាស់ប្តូរឆាណែលទៅជាសាក្សីនេះផ្តល់សក្ខីកម្មជាភាសាបារាំងវិញ!

លោកស្រីអាចប្រាប់អាយុលោកស្រីបានទេ តើលោកស្រីអាយុប៉ុន្មាន?

**ផៈ** ខ្ញុំកើតនៅថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៤៦។ ខ្ញុំមានសញ្ជាតិបារាំង។ ខ្ញុំរៀបការហើយ ខ្ញុំមានកូនបីនាក់ ហើយកូនម្នាក់បានស្លាប់នៅក្នុងអំឡុងរបបប្រល័យពូជសាសន៍។

**សៈ** លោកស្រីមានទីកន្លែងកំណើតនៅទីកន្លែងណា? ហើយលំនៅដ្ឋានបច្ចុប្បន្នលោកនៅទី -- លោកស្រីនៅទីកន្លែងណា?

[០៩:១៥:៥៧]

**ផៈ** ខ្ញុំកើតនៅទីក្រុងភ្នំពេញ គឺសង្កាត់លេខ៣។ ខ្ញុំកើត -- ខ្ញុំស្នាក់នៅទឹកល្អក់ជាមួយឪពុកម្ដាយ។ ហើយឥឡូវនេះ ខ្ញុំស្នាក់នៅទីក្រុងប៉ារីស។

**សៈ** បាទ អរគុណលោកស្រី ផាន់ដារ៉ា។ ក្នុងនាមលោកស្រីជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសវនាការនេះ អង្គជំនុំជម្រះសាលាដំបូងផ្ដល់ឱកាសឲ្យលោកស្រីឡើងថ្លែងរៀបរាប់ដល់អង្គសវនាការអំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មទាំងឡាយដែលបានកើតមានចំពោះលោកស្រីជាអាទិ៍ ការខូចខាតខាងផ្លូវចិត្ត ខាងផ្លូវកាយ ឬខាងសម្ភារៈ។ ព្យសនកម្មផ្ទាល់ខ្លួន ដែលជាបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋ ដែលបានកើតឡើងពិតប្រាកដរហូតដល់បច្ចុប្បន្ននេះ ដែលនាំឲ្យលោកស្រីប្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋទាំងឡាយដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទចំនួនពីររូបគឺលោក នួន ជា និងលោក ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកស្រីក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

[០៩:១៧:១៣]

បាទ នេះជាឱកាសដែលអង្គជំនុំជម្រះផ្ដល់ជូនលោកស្រីក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីនេះ។

សូមអញ្ជើញ!

**ផៈ** ខ្ញុំចាំគឺនៅថ្ងៃទី១៧ មេសា នៅពេលខ្មែរក្រហមចូលមកដល់ទីក្រុង យើងទាំងអស់គ្នាមានភាពសប្បាយរីករាយណាស់នៅពេលដែលឃើញមានការផ្លាស់ប្ដូររបបបែបនេះ ពីព្រោះថាយើងនិយាយប្រាប់គ្នាថា យើងទទួលបានសន្តិភាពហើយ។ ខ្ញុំឃើញម្ដាយខ្ញុំកាន់ទង់ជ័យសគ្រវី ហើយគាត់យើងទាំងអស់គ្នាស្រែកថាយើងលែងមានសង្គ្រាមហើយ យើងទទួលបានសន្តិភាពទាំងអស់គ្នាហើយ។ ហើយយើងនឹងយកទ្រព្យសម្បត្តិយើងដាក់ចូលសហគមន៍ទាំងអស់គ្នា។ នៅពេលនោះគឺថាយើងរីករាយមែន

ទែន ប្រជាជនសប្បាយរីករាយហ៊ោកញ្ជៀវពេញហ្នឹង ហើយយើងគិតថាសង្គ្រាមនឹងចប់ទៅហើយ។ ហើយនៅពេលដើមរសៀលមានខ្មែរក្រហមចូលមកដល់ ពួកគេបានប្រាប់យើងឲ្យចេកចេញ។ ដំបូងយើងអត់យល់ទេថា ហេតុអីក៏អ៊ីចឹង? ម៉េចក៏ឲ្យយើងចេញទៅអ៊ីចឹង? យើងត្រូវការការកសាងប្រទេសឡើងវិញ យើងដាក់ទ្រព្យសម្បត្តិចូលសហគមន៍ទាំងអស់គ្នា យើងសប្បាយរីករាយ យើងនឹងព្រមធ្វើ ក៏ប៉ុន្តែហេតុអីក៏យើងចាក ឲ្យយើងចេញទៅវិញ? ក៏ប៉ុន្តែខ្មែរក្រហមនិយាយថា ត្រូវតែចាកចេញ អ្នកទាំងអស់គ្នាចាកចេញតែ៣ថ្ងៃទេ។ ក្រោយពី៣ថ្ងៃហ្នឹងមកហើយគឺអាចមកវិញបានហើយ។ រដ្ឋាភិបាលត្រូវការរៀបចំទីក្រុងឲ្យស្អាត ដូច្នេះសូមឲ្យយើងទាំងអស់គ្នាចេញទៅ ដើម្បីឲ្យយើងរៀបចំទីក្រុង ហើយនិងជាពិសេសគឺកង -- កុំឲ្យអាមេរិកាំងទម្លាក់គ្រាប់បែក។

[០៩:១៩:០៦]

ពេលដំបូងយើងទាំងអស់គ្នាដូចជារាងស្ទាក់ស្ទើរ រួញរាដែរ ក៏ប៉ុន្តែក្រោយមកមានអ្នកជិតខាងប្រាប់ថាយើងត្រូវតែរៀបចំអីវ៉ាន់ យើងឃើញមានគេចេញគ្រប់គ្នាហើយ អ៊ីចឹងយើងត្រូវតែចេញ។ ពេលនុ៎ង យើងនៅជាមួយឪពុកម្តាយ រួចហើយយើងស្នាក់នៅផ្ទះជុំគ្នា។ ឪពុកម្តាយខ្ញុំក៏គាត់ ពួកគាត់ភ្ញាក់ផ្អើលដែរ ព្រោះយើងអត់បានត្រៀមខ្លួនដើម្បីរៀបចំអីវ៉ាន់ចាកចេញទេ។

ប្រហែលជា១ម៉ោងក្រោយមក មានទាហានផ្សេងទៀតមកដល់។ ពេលនុ៎ងយើងដូចជារាងខ្លាចបន្តិចដែរ ពីព្រោះថាយើងឃើញពួកខ្មែរក្រហមនុ៎ងដូចជាកាចណាស់ មើលទៅពួកទាហានហ្នឹង។ ពួកគេបានប្រាប់ឲ្យយើងថាឲ្យរៀបចំអីវ៉ាន់ចេញទៅ ចេញតែ៣ថ្ងៃទេ។ ពេលនោះ ឪពុកម្តាយ -- ឪពុកខ្ញុំបានប្រាប់ថា ឲ្យយកតែអីវ៉ាន់ចាំបាច់ទៅបានហើយ ចេញទៅតែប៉ុន្មានថ្ងៃទេ រៀបចំទៅ ឲ្យក្មេងៗចេញទៅ។ ពេលនោះ យើងមានកូនតូចៗពីរនាក់ ហើយមានក្មួយពីរនាក់ដែលជាកូនរបស់បងខ្ញុំ។ បងខ្ញុំគាត់នៅបារាំងហើយ ពេលនុ៎ងហើយបន្ទាប់មកឪពុកខ្ញុំនាំឲ្យជួបជុំគ្នាវិញ។ ដូច្នេះ ទាំងអស់មានក្មេងៗបួននាក់ យើងយកទឹកបន្តិច ថ្នាំសង្កូវតិចតួច ហើយនិងមានអង្ករ ហើយមានខោអាវ។ ពេលហ្នឹងគឺថាមានមនុស្សច្រើនមែនទែន។ ហើយយើងចាកចេញទៅតាមផ្លូវអ៊ីចឹងទៅ ខ្ញុំឃើញមានសាកសពនៅរាយប៉ាយពេញផ្លូវ ពេលហ្នឹងពួកយើងចាប់ផ្តើមភ័យ ឃើញសាកសពបែបហ្នឹង។

[០៩:២១:០៤]

ហើយយើងមានឡានពីរ ហើយឡានពិបាកចេញទៅណាស់ គឺថាចេញទៅបានតិចៗទេ ជួនកាលទៅក៏យើងរុញឡាន ព្រោះថាមនុស្សមកពេញហ្នឹង យើងពិបាកធ្វើដំណើរណាស់។ ហើយមានប្អូនខ្ញុំគាត់

មានកង់ កង់គាត់ជិះកង់ ប្អូនស្រី ហើយពេលយប់យើងទៅដល់ យើងយឺតបន្តិចទៅហើយ។ ពេលនោះ យើងទៅដល់កន្លែងមួយ គឺនៅៗកែងផ្លូវព្រះសីហនុ ហើយពេលហ្នឹងៗមានអ្នក យើងឃើញ --យើងទៅដល់ យើងឮសំឡេងមួយស្រែកថា ឲ្យនាឡិកាមកខ្ញុំមក ហើយសំឡេងហ្នឹងគឺថាសំឡេងកាចមែនទែន។ ហើយដោយសារតែខ្លាចបង់បាត់កូន ខ្លាចបង់បាត់ក្មេងៗនោះ ខ្ញុំអត់បាន ខ្ញុំដូចជាភ័យ ហើយបន្ទាប់មក យើងមានឮស្នូរកាំភ្លើង ក្រោយមកខ្ញុំឃើញមានដូចជាមនុស្សម្នាក់ដែលទើបតែស្លាប់ថ្មីៗ។

ចាប់ពីហ្នឹង យើងយល់ឃើញថា អ៊ូ! ស្ថានភាពគឺ ស្ថានភាពអាចមានគ្រោះថ្នាក់ហើយ យើងទាំងអស់គ្នាក៏ចាប់ផ្ដើមភ័យខ្លាចមែនទែន។ បន្ទាប់មកគេដកយកឡាន ដំបូងហ្នឹងយើងមានឆ្កែមួយ ឆ្កែអាល្លឺម៉ង់ទៅ យើងទៅតាមដែរ ហើយនៅពេលដែលគេដកយកឡានយកអីហ្នឹង ហើយកង់អីក៏យើងឲ្យគេភ្លាមៗ ហើយ -- ព្រោះថាយើងខ្លាចណាស់ពេលនោះ។ ហើយបន្ទាប់មក ឆ្កែហ្នឹងអត់ចង់ទៅជាមួយយើងទេ ព្រោះវាឃើញគេយក -- ឃើញឡានអីចឹង វាចង់នៅជាមួយឡាន។ ហើយដោយសារយើងខ្លាចពេកហ្នឹង យើងទុកអីវ៉ាន់អី យើងទុកខោអាវអីនៅក្នុងឡានចោល យើងយកតែទឹកបន្តិចបន្តួចទេ។ ហើយយើងបន្ទាប់មកយើងទៅគីឡូម៉ែត្រលេខ១៣ ពីព្រោះថានៅគីឡូម៉ែត្រលេខ១៣ហ្នឹង យើងមានដីតូចមួយ ហើយយើងមានផ្ទះមួយ និងយើងដាំដំណាំតិចតួច។ អីចឹងយើងក៏ទៅគីឡូម៉ែត្រលេខ១៣។ នៅហ្នឹងយើងស្នាក់នៅមួយយប់ ស្អែកឡើងយើងបន្តដំណើរទៀត ហើយមានទាហានខ្មែរក្រហមហ្នឹង ចេះតែបង្ខំឲ្យយើងថា ទៅមុខៗទៅ។ ពេលនុ៎ងហើយ ដែលខ្ញុំឃើញមានសភាពរន្ធត់នៅក្នុងជីវិតរបស់ខ្ញុំនោះ។

[០៩:២៣:៥១]

យើងឃើញមានស្ត្រីកើតកូន ប្រសូត្រកូន សម្រាលកូននៅនឹងតាមផ្លូវ។ ឃើញមានអ្នកជំងឺនៅលើគ្រែ មានព្យួរសេរ៉ូម ហើយនិងនៅហាលថ្ងៃក្ដៅហែង។ ខ្ញុំឃើញមនុស្សចាស់ដែលគាត់មិនអាចដើរបាន គាត់ពិបាកដើរ ហើយឪពុកម្ដាយយើងក៏ចាស់ៗ។ ពេលហ្នឹង គឺថាវាជាស្ថានភាពពិបាកមែនទែនសម្រាប់ក្មេងៗកម្ពុជា។ ទាហានចេះតែបង្ខំឲ្យយើងទៅមុខទៀត។ បន្ទាប់មកយើងក៏បាន -- បន្ទាប់ពីបីបួនយប់មកនោះ យើងទៅដល់ភូមិមួយឈ្មោះ ភូមិអង្គរមាស។ មុនពេលទៅដល់ភូមិអង្គរមាសនោះ មានក្មួយរបស់យាយខ្ញុំដែលជាអ្នក -- យាយខ្ញុំដែលជាអ្នកចាស់នៅក្នុងភូមិហ្នឹង គាត់មករកខ្ញុំ ហើយគាត់ខ្សឹបប្រាប់ខ្ញុំ គាត់ប្រាប់ខ្សឹបប្រាប់ថាឲ្យកម្ទេចចោលទៅអត្តសញ្ញាណបណ្ណ លិខិតស្នាមផ្សេងៗហ្នឹង កុំឲ្យទុកដានឲ្យសោះ។ គេឲ្យយើង -- គាត់ខ្សឹបប្រាប់ថា ឲ្យដូរឈ្មោះទៅ កុំឲ្យហៅថា ដារា-ស អីចឹង

ដាក់ឈ្មោះខ្លីទៅបានហើយ។ ចាប់ពីពេលហ្នឹងហើយ គឺថាខ្ញុំដាក់យកតែឈ្មោះ ផែល ទៀតទេ លែង ផាន់ដារា-ស គេហៅតែ ផែលៗដោយខ្លី។

[០៩:២៥:៤៨]

យើងនៅក្នុងភូមិហ្នឹងអស់មួយរយៈកាល។ ពេលព្រឹកយើងធ្វើការនៅចម្ការ ហើយមានមនុស្សប្រុសៗមួយក្រុមហ្នឹងទៅធ្វើការនៅឆ្ងាយៗ ហើយ១០ថ្ងៃបានត្រឡប់មកផ្ទះម្ដង។ ស្ត្រីនាំគ្នាធ្វើការនៅស្រែចម្ការ។ ជារៀងរាល់ថ្ងៃគឺមានកិញក្មេងៗមកតាមដានមើល ហើយមានគេដានមើលអ្នកដែលទៅធ្វើការ១០ថ្ងៃត្រឡប់មកម្ដងហ្នឹងក៏គេតាមដាន។ ចំពោះខ្ញុំគឺថារយៈពេលខ្លីហ្នឹងក៏ប៉ុន្តែគឺថាគិតទៅដូចជាយូរមែនទែន ហើយអ្នកចាស់ដែលជាក្មួយរបស់ម្ដាយ -- របស់យាយខ្ញុំហ្នឹង គឺថាបានឲ្យយើងហូបចុក គឺគាត់បានផ្ដល់ដំឡូង ផ្ដល់ស្រូវ អង្ករ ក៏ប៉ុន្តែម្ហូបទាំងអស់ហ្នឹងគឺថាគ្មានប្រហុតអ៊ីន គ្មានអីទេ យើងអត់មានត្រីទេ។ ដូច្នេះយើងក៏អាចត្រដររស់បាន ហូបបានជាមួយនឹងដំឡូងជាមួយអង្ករតិចតួចហ្នឹង ដោយមានអ្នកចាស់ឲ្យហ្នឹង។

បន្ទាប់មកក៏មានការជម្លៀសចេញពីភូមិហ្នឹង មានឡានកាំមីញ៉ុងមកដឹកយើងឲ្យចេញពីភូមិ កូនភូមិនុំង។ ឡានហ្នឹងក៏នាំយើងទៅដល់កំពង់ឆ្នាំង បន្ទាប់មកទៅពោធិ៍សាត់ ហើយក្រោយមកក៏យើងជិះរថភ្លើង រថភ្លើងហ្នឹងគឺថាសម្រាប់ដឹកគោក្របីអីចឹង ដូចដឹកដូចគោដូចក្របី គឺថាយើងដាក់បញ្ជៀតគ្នា ហើយបន្ទាប់មកទៅដល់ភ្នំជើងទិញ។ គឺថាភ្នំហ្នឹងហើយគឺថាយើងរស់នៅជារបៀបគ្រួសារយើង យើងអត់មានអីដើម្បីសង់ខ្ទមទេ យើងធ្វើម៉េចធ្វើទៅធ្វើតាមខ្លួនឯង យើងអត់មានកាំបិត អត់មានសម្ភារៈអ្វីទាំងអស់។ យើងដំបូងនោះគឺថាយើងដោះដូរគ្នាដើម្បីរកបានកាំបិត ដើម្បីយកទៅកាប់ដើមឈើ យកមកសង់ខ្ទម កូនខ្ទម ហើយសម្រាប់ឲ្យក្មេងៗរស់នៅ។ យើងធ្វើការដូចគ្នាគឺថាពី -- តាំងពីព្រលឹម ហើយរហូតដល់យប់ ហើយយើងមានម្ហូបអាហារនោះ គឺថាបន្តិចបន្តួចបំផុត គឺថាមានតែមួយកូនវែក ក្មេងៗឃ្លានៗហើយពេលហ្នឹងគឺថាជារដូវមូសុង គឺថាក្មេងៗដែលធ្លាប់តែរស់នៅស្រួលហ្នឹង គឺថាពិបាកមែនទែន មករស់នៅរបៀបអីចឹងអត់មានអីទាំងអស់ គ្មានអីហូបចុក។

[០៩:២៨:៤៥]

ហើយគាត់មកសួរ -- ក្មេងៗហ្នឹងចេះតែសួរយើងថា ម៉េចក៏មករស់នៅក្នុងព្រៃអីចឹង ម៉េចក៏មិនទៅនៅផ្ទះយើង យើងមានអីហូបចុកគ្រប់គ្រាន់ ឥឡូវមករស់នៅត្រដរ ត្រដេរត្រដរអីចឹង ហើយពួកយើងដូចអត់មានអីចម្លើយទៅឲ្យក្មេងៗទាំងអស់ហ្នឹងទេ។ ពេលហ្នឹងគឺថាយើងមានក្មេងៗបួននាក់។

បន្ទាប់ហ្នឹងមកគឺថា មនុស្សប្រុសៗហ្នឹងចុះទៅធ្វើការ ហើយខ្ញុំឃើញឪពុកខ្ញុំ គេឲ្យគាត់ទាញអូសនង្គ័លជំនួសឲ្យគោក្របី។ ហើយឃើញឪពុកខ្ញុំហ្នឹងដូចជាចាស់ជាងអាយុដល់ទៅ១០ឆ្នាំ -- ចាស់ជាងអាយុ១០ឆ្នាំទៅទៀត គ្រាន់តែធ្វើការបានប៉ុន្មានថ្ងៃហ្នឹងទៅ។ ថាការងារហ្នឹងគឺថាមិនអាចទ្រាំទ្របានទេ ឃើញសក់គាត់ឡើងស្កូវ គឺថាឃើញការគាត់ធ្វើការហ្នឹងលំបាកមែនទែន។ នេះជារូបភាពមួយដែលគួរឲ្យរន្ធត់ ហើយខ្ញុំក៏មិនចង់ស្រមៃឃើញរូបភាពហ្នឹងឡើងវិញទៀតដែរ។ នេះជារបៀបធ្វើការពី១ថ្ងៃ ទៅ១ថ្ងៃអ៊ីចឹង។ យើងធ្វើការដូចៗគ្នា ហើយនៅថ្ងៃមួយនោះគេឆ្លើយដាក់យើង គេចោទយើងពេលនោះថ្ងៃមួយនោះខ្មែរក្រហមក៏បានមកដល់មកចាប់យើងគឺនៅតាំងពីព្រលឹម ហើយនាំយើងទៅ។ ហើយពេលនុ៎ងប្ដីខ្ញុំគាត់ឈឺ។ គាត់ជាពេទ្យ។ តាំងពីថ្ងៃដំបូងនោះ គាត់ឈឺគាត់ហើមដៃហើមជើងពេញ ហើយគាត់ក៏នៅក្នុងខ្ទមហ្នឹង។ ហើយពេលហ្នឹងខ្មែរក្រហមនាំយើងចេញទៅគឺថាគ្នាយើងពេលហ្នឹងប្រាំមួយនាក់ សមាជិកយើងប្រាំមួយនាក់។ ហើយយើងឃើញមានពូខ្ញុំ អ៊ំខ្ញុំ យាយ តាខ្ញុំ នៅក្នុងហ្នឹងដូចជាប្រាំមួយគ្រួសារនៅក្នុងភូមិអង្គរមាសហ្នឹងគឺថាយើងចេញទៅភ្នំជើងទិញហ្នឹង គឺយើងប្រាំមួយគ្រួសារ។

[០៩:៣១:១៥]

នៅពេលដែលខ្មែរក្រហមនាំពួកយើងចេញទៅទិសដៅមួយដែលយើងមិនស្គាល់នោះ ខ្ញុំគិតថាអូ! ចប់ហើយយើង គេយកទៅសម្លាប់ចោលនៅតាមវាលស្រែហើយ។ យើងក៏ត គេតម្រង់ គេនាំទៅបន្តកន្ទុយគ្នាអ៊ីចឹង តម្រង់ជួរ។ ពេលហ្នឹងខ្ញុំគិថាប្រហែលជាម៉ោងប្រាំ ប្រាំមួយព្រឹកទេ ហើយមនុស្សគេនាំគ្នាធ្វើការនៅក្នុងស្រែចម្ការ ហើយគេនាំគ្នាមើលយើងមក ហើយខ្ញុំគិតថា អូ!គេបាញ់យើងចោលនៅជិតកូនភ្នំហ្នឹងហើយ។ ក៏ប៉ុន្តែ គេនាំយើងទៅដល់បឹងកន្ទួត។ ហើយគេថបថសួរចម្លើយ សួរនាំយើងៗ។ ពេលនោះមានមេក្រុមឈ្មោះ តាផន មេកងគឺថាមានទាហានប្រុស គេនាំគ្នាសួរចម្លើយយើង សួរប្រវត្តិរូបយើងដូចពីដំបូងអ៊ីចឹង។ គេសួរយើង ប្រវត្តិរូបឲ្យពេញ១ថ្ងៃ។ យើងគឺថា យើងនៅតែលាក់ដដែល។ ខ្ញុំប្រាប់គេថាខ្ញុំអ្នកគ្រឿងទេស ហើយយើងអត់មានឯកសារអីទេ ព្រោះយើងបានបោះចោលហើយ។ យើងថាយើងគ្រាន់តែជាអាជីវករលក់ដូរ។

[០៩:៣២:៤១]

គេសួរហ្នឹងគឺថាសួរតឹងតែងមែនទែនគឺថា តាំងពីព្រលឹមរហូតទៅដល់ល្ងាច។ សួរដដែលៗគេសួរថាអ្នកឯងជាប្រពន្ធរបស់ឧត្តមសេនីយ៍មែន? ប្ដីរបស់អ្នកឯងជាពេទ្យមែន? ជាមន្ត្រីរាជការជាន់ខ្ពស់មែន? អ៊ីចឹងយើង យើងនៅតែលាក់បាំងដដែល យើងឆ្លើយថាអត់ទេ ពួកយើងជាប្រជាជនសាមញ្ញ

ធម្មតា។ យើងគ្រាន់តែជាអ្នកលក់ដូរ ជាអាជីវករទេ។ ហើយនៅពេលនុំងនោះគឺថាមានប្រពន្ធរបស់ឧត្តមសេនីយ៍ហ្នឹង គាត់វ៉ឺសតែនឹងឆ្លើយបែកការណ៍ទៅហើយ។ ព្រោះថាអ៊ីចេះ ខ្ញុំឃើញអារម្មណ៍គាត់ហ្នឹង ដូចជាគាត់ចង់ឆ្លើយ ក៏ប៉ុន្តែបន្ទាប់មកគឺថាគាត់អាចនៅអត់ឆ្លើយទេ។ ចុងក្រោយគេសួរអត់ដឹងអីហ្នឹង ក៏គេដោះលែងយើងទៅ ប្រហែលជាម៉ោងមួយ គេដោះលែងពួកយើង។ ហើយពេលដោះលែងហើយនោះ គេឲ្យយើងហូបចុកទៅ គឺថាពេលនោះយើងរីករាយមែនទែន ដែលយើងបានបាយ ឃើញបាយបែបនេះនោះគឺថាដូចមានត្រីងៀត មានអីទៀត ដូចយើងសប្បាយចិត្តណាស់ពេលនោះ។ និយាយទៅដូចជាអាហារដ៏អស្ចារ្យអ៊ីចឹងមានបាយ មានត្រីងៀត។ ហើយឪពុកម្ដាយខ្ញុំគាត់លោតអរតែម្ដងលោតកញ្ឆេង ឃើញពេលបានបាយអ៊ីចឹង។

[០៩:៣៤:២២]

តែខ្ញុំឮពាក្យចចាមអារ៉ាមថា បន្ទាប់ពីគេឲ្យបាយហើយហ្នឹងគឺថាគេសម្លាប់ហើយ។ អ៊ីចឹងខ្ញុំក្នុងចិត្តហ្នឹង ខ្ញុំនៅតែខ្លាចអ៊ីចឹង។ ខ្ញុំហូបតែពាក់កណ្ដាលទេ ព្រោះខ្ញុំគិតថានេះជាម្ហូបចុងក្រោយ ជាលើកចុងក្រោយហើយ។ ពេលពាក់កណ្ដាល ខ្ញុំឲ្យទៅឪពុកម្ដាយខ្ញុំ។ ក៏ប៉ុន្តែជាសំណាងល្អមែនទែនចុងក្រោយគេលែងយើង។ ប៉ុន្តែគេបំបែកយើងចេញពីគ្នា គឺថាប្រហែលជានៅចម្ងាយពីគ្នា ២គីឡូម៉ែត្រ យើងអ៊ីចឹងប្រហែលជា -- ពេលនោះយើងនៅក្បែរៗគ្នាទេ បើយើងគិតទៅ២គីឡូម៉ែត្រហ្នឹង។ ហើយមានអ្នក មានគិញ មានឈ្លបមកតាមដានយើង ស៊ើបមើលយើង។ ហើយខ្មែរក្រហមបានបញ្ជូនឪពុកម្ដាយខ្ញុំដែលជាមនុស្សចាស់ជរាហ្នឹងទៅធ្វើការជាមួយក្មេងៗដែលអត់មានបាយ អត់មានការហូបចុក អត់មានអី។

ដូច្នេះ នៅឆ្នាំ៧៦ហ្នឹង គឺថាសមាជិកក្រុមគ្រួសារយើងចាប់ផ្ដើមស្លាប់ជាបន្តបន្ទាប់ម្នាក់ម្ដងៗហើយពេលហ្នឹងទៅ។

**លោកស្រី ធុច ផាន់ដារា-ស (និយាយភាសាខ្មែរ)៖**

ចាសសូមទោស ខ្ញុំសូមទឹក ចាសសូមញ៉ាំទឹកចាស។

*(សម្រាករយៈពេលខ្លី)*

[០៩:៣៦:៣៧]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកស្រីមេធាវី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំឈ្មោះ ម៉ារី ខ្ញុំការពារដើមបណ្ដឹងរដ្ឋប្បវេណីនេះ។ ជាបឋម ខ្ញុំសូមរំឭកអំពីឯកសារដែលអាចអនុញ្ញាតឲ្យតុលាការ ហើយនិងភាគីអាចយល់អំពីសក្ខីកម្មរបស់គាត់។ គាត់បានសុំខ្លួន តាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅខែមករា ឆ្នាំ២០០៨ ហើយយើងមានទម្រង់បែបបទរបស់គាត់ គឺឯកសារ D22/189, ខ្ញុំសូមឲ្យលេខ ERN ជាភាសាបារាំងគឺ 00259374 ទៅដល់77, ERN ជាភាសាអង់គ្លេសគឺ 00847852 ទៅដល់ 57, ERN ជាភាសាខ្មែរគឺ 00404256 ទៅដល់ 67។ អ្នកស្រី ហ្វេនីញ៉េស គាត់បានផ្ដល់សក្ខីកម្មបន្ថែមដែលត្រូវបានថតនៅថ្ងៃទី០៩ មេសា ឆ្នាំ២០០៩។ ERN ជាភាសាអង់គ្លេសគឺ 00852179 ទៅដល់ 81, ERN ជាភាសាបារាំងគឺ 00584551 ទៅដល់ 53។ អ្នកស្រី ហ្វេនីញ៉េស មិនត្រូវដែលបានស្ដាប់ដោយចៅក្រមស៊ើបអង្កេត ឬក៏សហព្រះរាជអាជ្ញានោះទេ ក៏ប៉ុន្តែគាត់ត្រូវបានទទួលដោយដើមបណ្ដឹងរដ្ឋប្បវេណីដោយការិយាល័យសហព្រះរាជអាជ្ញាក្នុងចំពោះជម្លៀសដំណាក់កាលទី១។

[០៩:៣៨:៥២]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៖**

**ស៖** អ្នកស្រី ខ្ញុំៗសូមជម្រាបសួរអ្នកស្រី។ ខ្ញុំទើបតែបង្ហាញឯកសារដែលធ្វើឲ្យអ្នកស្រីត្រូវបានទទួលជាដើមបណ្ដឹងរដ្ឋប្បវេណី។ ហើយខ្ញុំដឹងថាអ្នកស្រីបានអានឯកសារទាំងអស់នេះដែរឬទេ? បើសិនជាបានអាន តើព័ត៌មានទាំងអស់នេះត្រឹមត្រូវដែរឬទេ ឬក៏អ្នកស្រីមានអ្វីចង់បន្ថែម?

**លោកស្រី ធុច ផាន់ដារ៉ា-ស៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់និយាយលោកស្រី! ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការសិនណា!

[០៩:៣៩:៤៧]

**លោកស្រី ធុច ផាន់ដារ៉ា-ស៖**

**ឆ៖** លោកស្រីមេធាវី ខ្ញុំបានអានឯកសារហ្នឹងហើយ ហើយខ្ញុំសង្កេតឃើញថាមានការភាន់ច្រឡំបន្តិចបន្តួច គឺថាបញ្ហោវាយកុំព្យូទ័រទេ ទាក់ទងទៅនឹងគ្រប់កាំភ្លើងដែលធ្លាក់មកលើផ្ទះខ្ញុំនៅឆ្នាំ១៩៧២

ហើយគ្រាប់ផ្លោងនោះ គឺជាគ្រាប់ផ្លោងរបស់វៀតកុងទេ មិនមែនជាគ្រប់ផ្លោងរបស់ខ្មែរក្រហមទេ។ ហើយក្នុងចម្លើយនោះឃើញដាក់ថាជាគ្រាប់ផ្លោងរបស់ខ្មែរក្រហម។ អ៊ីចឹងខ្ញុំសូមកែតម្រូវកន្លែងនេះបន្តិច។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៖**

**ស៖** ខ្ញុំសូមអរគុណ។ ឥឡូវក្នុងពេលយើងពេលវេលាដែលនៅសល់នេះ ខ្ញុំសូមចោទសំណួរមួយចំនួនទាក់ទងទៅនឹងផលប៉ះពាល់ដែលអ្នកស្រីបានរៀបរាប់ថា ទាក់ទងនឹងជីវិតរបស់អ្នកស្រី ហើយនិងអង្គហេតុមួយចំនួនអ្នកស្រីបានឆ្លងកាត់។ នៅក្នុងសេចក្ដីផ្ដើមដែលអ្នកស្រីបានរៀបរាប់ អ្នកស្រីបាននិយាយអំពីពីការបង្អត់អាហារ។ ខ្ញុំចង់ដឹងថាតើការបង្អត់អាហារនេះ មានផលប៉ះពាល់អ្វីខ្លះមកលើរូបអ្នកស្រី? ហើយសិនជាមាននោះអ្វីខ្លះ?

[០៩:៤១:00]

**ឆ៖** ផលប៉ះពាល់នៃការបង្អត់អាហារដែលមានមកលើខ្ញុំនោះ ខ្ញុំគិតថានៅពេលដែលចាកចេញពីប្រទេសកម្ពុជានៅឆ្នាំ៧៩នោះ ខ្ញុំគិតតែពីញុំាអាហារដើម្បីឲ្យមានកម្លាំងឡើងវិញ ហើយពេលនោះ ខ្ញុំសុខភាពមាំមួនជាងមុន ក៏ប៉ុន្តែខ្ញុំកាលណោះនោះគឺថាគិតតែពីញុំាទេ មិនគិតផាសុកភាព ពីអ្វី ពីផ្ទះសម្បែងអីទេ។ កាលនោះ អ្វីដែលខ្ញុំត្រូវការគឺចំណីអាហារតែប៉ុណ្ណោះឯង។

**ស៖** ខ្ញុំសូមអរគុណ។ នៅក្នុងកំណត់ហេតុរបស់ -- នៅក្នុងដើមសវនាការនេះ អ្នកស្រីបានលើកឡើងថាឪពុកម្ដាយរបស់ -- ឪពុករបស់លោក ហើយនិងអ្នកចាស់នោះ ហើយនៅក្នុងវប្បធម៌របស់អ្នកស្រី តើអ្នកស្រីមានទទួលអារម្មណ៍យ៉ាងម៉េចខ្លះ ចំពោះឪពុកម្ដាយរបស់ខ្លួននេះ? តើឪពុកម្ដាយរបស់លោកនេះ អ្វីដែលគាត់បានទទួលរងនេះ ធ្វើឲ្យអ្នកស្រីយល់ មានអារម្មណ៍យ៉ាងម៉េចដែរ?

[០៩:៤២:១៦]

**ឆ៖** ដូចលោកដឹងស្រាប់ហើយថា ឪពុកម្ដាយដូចជាព្រះជាម្ចាស់អ៊ីចឹង។ យើងមិនអាចប៉ះពាល់គាត់បានទេ គាត់ជាទីសក្ការ: ហើយនៅពេលដែលយើងឃើញឪពុកម្ដាយ គឺថាស្លាប់នៅអាយុ៤៣ឆ្នាំ ៤៤ឆ្នាំនោះ គឺថាស្លាប់មុនអាយុ។ ខ្ញុំដែលថាខ្ញុំមិនអាចបំភ្លេចបានទេ អ្វីដែលខ្ញុំឃើញនេះៗ។ នៅក្នុងគាត់ស្លាប់នៅក្នុងលក្ខខណ្ឌ ដូចយើងមិន -- ថាវាហួសពីៗសត្វធាតុនោះទៀត គឺថាវាក្នុងលក្ខខណ្ឌមួយដែលថាខ្ញុំមិនអាចរកពាក្យណាមកពិពណ៌នាពីលក្ខខណ្ឌនេះបានទេ។ ខ្ញុំ -- គាត់ គេទម្លាក់គាត់ចូលក្នុងរណ្ដៅដោយគ្មានអ្វីទាំងអស់ ហើយខ្ញុំមិនដឹងថាគេទម្លាក់គាត់នៅក្នុងរណ្ដៅកន្លែងណានោះទេ។ យើង --

អ៊ីចឹងខ្ញុំមាន -- រាល់ថ្ងៃនេះ ខ្ញុំស្តីបន្ទោសខ្លួនឯង ដែលមិនអាចដឹងថាគាត់នៅកន្លែងណា។ ដែលមិនអាចជួយសង្គ្រោះជីវិតរបស់គាត់បាន។ បើកាលណោះ បើខ្ញុំក្លាហានជាងនេះវិញនោះ ខ្ញុំមុខប្រហែលជាអាចលួចស្រូវលួចស្អី១សព្វបែបយ៉ាងដើម្បីឲ្យគាត់មានអាហារហូបចុក ប្រហែលជាដល់ពេលនេះ ប្រហែលជាគាត់អាចនៅរស់ក៏ថាបានដែរ។

[០៩:៤៣:៥០]

អ៊ីចឹងដូចអ្នកស្រី លោកស្រីមេធាវីដឹងហើយ គឺថាគាត់បាត់ទៅរហូតហើយ គ្មានថ្ងៃណាវិលត្រឡប់វិញទេ។ ដោយសារអាស្រ័យហេតុនេះហើយបានខ្ញុំមកផ្តល់សក្ខីកម្មនៅទីនេះ ដើម្បីសុំឲ្យរកយុត្តិធម៌ ពីព្រោះថា១យើង១ដូចជារំឭកទៅដល់ព្រលឹងបុព្វ -- អ្នកដែលស្លាប់ទៅហើយ។ អ៊ីចឹង ខ្ញុំជាអ្នកកាន់សាសនាព្រះពុទ្ធអ៊ីចឹង ខ្ញុំដឹងថាព្រលឹងហោះហើរនៅក្នុងពិភពលោកយើងនេះ គឺថានៅតែមានរលកញ័រនៃព្រលឹងនេះ ហើយបើសិនជាយុត្តិធម៌ត្រូវបានរកឃើញនោះ គឺថា១ជាកិត្តិយសមួយដែល១តម្រូវឲ្យខ្ញុំចង់ផ្តល់ទៅឲ្យព្រលឹងដែល១មនុស្សរាប់លាន -- ២លាននាក់ដែលកំពុងតែអណ្តែតត្រសែតគ្មានទិសដៅនេះ។ ជាកិត្តិយសដែលខ្ញុំចង់ឲ្យគេផ្តល់ឲ្យព្រលឹងទាំងអស់ហ្នឹង។

[០៩:៤៥:០២]

**ស៖** សូមអរគុណ។ លោកស្រីបាននិយាយអំពីឪពុករបស់អ្នកស្រី ហើយនៅក្នុងសេចក្តីបឋមដាក់ហ្នឹងដែរ គឺថាលោកស្រីបាននិយាយអំពីកូនប្រុសរបស់លោកស្រីដែរ។

**លោកស្រី ម៉ារី ហ្គ្រីវ៉ូដ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបញ្ចាំងរូបថតបួនស្លឹក ដែលខ្ញុំនឹងប្រើជាមូលដ្ឋានដើម្បីចោទសំណួរអ្នកស្រីដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងទៅនឹងសមាជិកក្រុមគ្រួសាររបស់គាត់ ហើយនិងទាក់ទងទៅនឹងលក្ខខណ្ឌរក្សារូបថតទាំងអស់នេះ។ ខ្ញុំគិតថារូបនេះ យើងបានបញ្ជូនទៅភាគីម្សិលមិញហើយ។ អ៊ីចឹងខ្ញុំគ្រាន់តែសូមការអនុញ្ញាតបញ្ចាំងរូបថតទាំងអស់នេះ។ ហើយបន្ទាប់មកខ្ញុំចោទសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី។ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះអនុញ្ញាត! ហើយក៏សូមរំឭកថា ដើមបណ្តឹងរដ្ឋប្បវេណីមានពេលវេលាពីនេះទៅរហូតដល់ត្រឹមម៉ោងដប់តែប៉ុណ្ណោះ។

[០៩:៤៦:១០]

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៖**

**ស៖** លោកស្រី គឺថាខ្ញុំមិនដឹងថាលោកស្រីមើលឃើញដែរឬទេ រូបថតបញ្ចាំង? រូបថតនេះគឺថាខ្ញុំចង់ឲ្យអ្នកស្រីពន្យល់ទៅតុលាការ ហើយនិងភាគី ថារូបថតទាំងអស់នេះ ជារូបថតរបស់អ្នកណា?

**លោកស្រី ធុច ផាន់ដារា-សៈ**

**ឆ៖** នេះកំពុងតែប្រឡែងលែង កាលណោះ គឺថាក្មេងវាឃ្លានខ្លាំង ហើយគេបោះចំណីឲ្យឆ្កែ វាទៅដណ្ដើមឆ្កែ។ អ៊ីចឹងកាលណោះ គឺកូននោះមានជំងឺ ហើយយើងចង់រកថ្នាំដើម្បីព្យាបាល កាលហ្នឹងវាអត់មានអីទាល់តែសោះ។ អ៊ីចឹងកាលហ្នឹង ដូចជំងឺរលាកខួរក្បាល។ វាពិបាក -- គួរឲ្យអាណិតណាស់ កាលហ្នឹងឃើញក្មេងហ្នឹងពាក់អាវយឺតហ្នឹងពណ៌លឿង គឺខ្ញុំមើលឃើញហ្នឹង គឺជារូបកូនខ្ញុំហ្នឹង គឺថាយើងឃើញអាវពណ៌លឿងហ្នឹង។ កាលនោះ គឺថាឃើញកូន ខ្ញុំឃើញកូនខ្ញុំដាច់ខ្យល់។ កូនខ្ញុំសួរខ្ញុំថាពេលនោះ វាមុននឹងស្លាប់ហ្នឹង ញញឹមដាក់ខ្ញុំហើយ ឲ្យវាឲ្យខ្ញុំញញឹមដាក់វាវិញ។ ហើយខ្ញុំគួរឲ្យចំពោះខ្ញុំក្ដុកក្ដួលណាស់ ព្រោះថាអស់លោកទាំងអស់គ្នាយល់ហើយ ថាពេលកូនជិតស្លាប់ហើយញញឹមដាក់ម្ដាយ ហើយសុំឲ្យម្ដាយញញឹមដាក់វិញនេះ។

[០៩:៤៨:១២]

**ស៖** ឥឡូវយើងសូមបញ្ចាំងរូបថតទៅទៀត បើសិនជាអ្នកស្រីចង់បន្ថែមអ្វីមួយទៀត ឬក៏មិនមែនជាពេលហ្នឹងទេ។ ខ្ញុំចង់ឲ្យអ្នកស្រីពន្យល់ទៅតុលាការ ហើយនិងភាគីអំពីលក្ខខណ្ឌនៃការរក្សារូបថតទាំងអស់នេះៗ។ យើងខ្ញុំឃើញរូបថតកូនរបស់លោកស្រី ហើយបន្ទាប់មកទៀតគឺរូបថតម្ដាយរបស់អ្នកស្រី ហើយនិងប្ដីរបស់អ្នកស្រីដែលស្លាប់នៅឆ្នាំ៧៦។ អ៊ីចឹងអ្នកស្រីអាចពន្យល់ពីរបៀបរក្សារូបថតទាំងអស់នេះបានទេ? តើរូបថតទាំងអស់នេះ ជាទ្រព្យសម្បត្តិដែលសល់តែមួយគាត់ ដែលសល់ពីរបបខ្មែរក្រហមហ្នឹង ឬក៏យ៉ាងម៉េចចំពោះអ្នកស្រី?

**ឆ៖** ខ្ញុំខំរក្សារូបថតនេះណាស់ ព្រោះថាខ្ញុំគ្មានអ្វីផ្សេងទៀតទេ។ ខ្ញុំបានដាក់ចូលក្នុងថង់ផ្លាស្ទិក ដាក់លាក់កប់ទៅក្នុងដី នៅពេលដែលខ្ញុំចេញទៅធ្វើការនៅសម័យនោះ គឺថាខ្ញុំតាមយករូបថតតាមរហូត នេះមើលរូបប្ដីខ្ញុំដែលជាពេទ្យកាលនោះ វេជ្ជបណ្ឌិត។

**ស៖** តើរូបថតទាំងអស់នេះ ជាអនុស្សាវរីយ៍តែមួយគត់ដែលលោកបានរក្សា ពីសម័យមុនឆ្នាំ៧៥នោះ តើអ៊ីចឹងមែនទេ?

[០៩:៤៩:៤៩]

**ឆ៖** ចាស អ៊ីចឹងហើយ នេះជាអនុស្សាវរីយ៍តែមួយគត់។

**ស៖** ខ្ញុំមានសំណួរពីរទៀត ព្រោះខ្ញុំដឹងថា លោកស្រីចង់សួរទៅជនជាប់ចោទ ទៅលោក ខៀវ សំផន ជាដើម។ អ៊ីចឹងដោយសារពេលវេលាខ្លីនោះ ខ្ញុំសូមចោទសំណួរពីរទៀតទាក់ទងទៅនឹងការនិរទេសខ្លួនចេញទៅប្រទេសបារាំង ហើយ -- អ៊ីចឹងលោក កាលណាយើងនិយាយពីផលប៉ះពាល់នៃឧក្រិដ្ឋនោះ តើយើងការនិរទេសនេះវាយ៉ាងម៉េច? តើអ្នកស្រីអាចពន្យល់ប្រាប់តុលាការបានទេ នៅពេលដែលអ្នកស្រីទៅដល់ប្រទេសបារាំងនៅខែតុលា ឆ្នាំ៧៩ នោះដែលទៅដល់នោះជាមួយនឹងកូនរបស់អ្នកស្រី កូនប្រុសម្នាក់ ហើយកូនស្រីម្នាក់ ហើយនិងបងស្រីរបស់អ្នកស្រី?

**ឆ៖** ខ្ញុំមានជីវិតបី ខ្ញុំ -- អ៊ីចឹងខ្ញុំមានមុនហ្នឹងគឺថាជីវិតខ្ញុំល្អ ឱកាសល្អណាស់ ហើយបន្ទាប់មកទៀត -- ហើយកាលដែលខ្ញុំនៅក្មេងនោះគឺថាខ្ញុំ -- កាលខ្ញុំនៅបារាំងនោះគឺថា ជាការតស៊ូដើម្បីឱ្យរស់ឡើងវិញ គឺថាកាលនោះមានអារម្មណ៍ថាខ្លួនឯងឯកការ ត្រូវតែតស៊ូ កាលណោះហើយត្រូវតែខំរៀនយកបណ្ណបើកបរ ខំរៀនពេលល្ងាចដើម្បីទទួលបានសញ្ញាបត្រ ហើយមានរកការងារបានធ្វើ។ ហើយអ៊ីចឹងគឺថា ធ្វើឱ្យយើងអស់កម្លាំងចិត្តណាស់ គឺថាវាអស់ឫសគល់ជាដើមកំណើតជាខ្មែរ។ ខ្ញុំចេះបារាំងដែរ ខ្ញុំដឹងវប្បធម៌បារាំងដែរ ក៏ប៉ុន្តែខ្ញុំអង្កាល់ណោះចូលទៅប្រទេសបារាំងស្ថិតនៅក្នុងមជ្ឈដ្ឋានមួយគឺថាវាការផ្លាស់ទីអីខុសគ្នា អាកាសធាតុអីក៏ខុសគ្នា ហើយខ្ញុំត្រូវចិញ្ចឹមកូនហើយនិងបងខ្ញុំ។ អ៊ីចឹងហើយពេលខ្លះហ្នឹង ខ្ញុំនោះធ្លាក់ក្នុងជំងឺខូចចិត្ត ហើយចូលដេកពេទ្យផង។ អ៊ីចឹងជារយៈកាលមួយដែលថា ខ្ញុំមិនអាចភ្លេចបានទេ ផ្នែកផ្លូវចិត្តពេល--

[០៩:៥២:២៩]

**ស៖** អរគុណអ្នកស្រី។ ជាសំណួរចុងក្រោយ ពីដើមសវនាការនេះគឺអ្នកស្រីចង់និយាយជាភាសាបារាំង សូមអនុញ្ញាតពីតុលាការអម្បាញ់មិញនេះ ពីព្រោះថាប្ដីរបស់អ្នកស្រី ហើយនិងក្រុមគ្រួសាររបស់អ្នកស្រីទាំងអស់ដែលនៅស្រុកបារាំងនេះ មិននិយាយខ្មែរទេ។ តើសំណួរសួរថា តើអ្នកស្រីនិយាយអំពីរបបខ្មែរក្រហមនេះជាមួយកូនចៅរបស់លោកស្រីដែរឬទេ?

**ឆ៖** ខ្ញុំនិយាយម្ដងម្កាលទេ និយាយតិចណាស់ ខ្ញុំនិយាយតែទៅកាន់កូនពៅរបស់ខ្ញុំនោះតិចណាស់ ហើយកូនប្រុសខ្ញុំអាធំជាងគេហ្នឹង ខ្ញុំមិនដែលនិយាយពីសម័យ ប៉ុល ពត នេះទេ។ កូនពៅនិយាយបន្តិចបន្តួច ហើយខ្ញុំនិយាយជាមួយមិត្តភក្ដិដែរ ហើយជាមួយ ប៉ុន្តែជាមួយប្ដីខ្ញុំនោះ ខ្ញុំនិយាយច្រើនដែរពីរបប ពីរយៈកាលខ្មែរក្រហមនេះ។ ហើយអ៊ីចឹងហើយ គាត់ថាឥឡូវនេះគាត់កំពុងតាមដាន

សវនាការនេះដោយផ្ទាល់ហើយនេះ។

**ស៖** អ៊ីចឹងឥឡូវនេះអ្នកស្រីគិតទៅអ្នកណានេះ ពេលដែលអ្នកស្រីកំពុងតែផ្តល់សក្ខីកម្មនេះ ឥឡូវនេះ ភ្លាមៗហ្នឹង?

[០៩:៥៣:៤៦]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់និយាយលោកស្រី!

**លោកស្រី ធុច ផាន់ដារ៉ា-សៈ**

**ឆ៖** នៅក្នុងតុលាការនេះគឺថាអ្វីដែលខ្ញុំនឹកឃើញដំបូងហ្នឹង គឺថាម្តាយខ្ញុំតែម្តង។ ខ្ញុំមិនអាចទទួលស្គាល់ថាគាត់កំពុងស្លាប់នោះទេ។ ខ្ញុំរូបថត -- រូបគាត់នេះកំពុងតាមខ្ញុំរហូត។ កាលនុំងគាត់ឃ្លានខ្លាំង ហើយយើងកាលណោះយើងទៅសហករណ៍ហ្នឹង ទៅ -- ហើយគាត់កាន់ចានមួយដើម្បីសុំម្ហូបបបរអីហ្នឹង ដល់គាត់ស្គមពេកអស់កម្លាំងចានហ្នឹងក៏ធ្លាក់ហ្នឹងទៅ គាត់ក៏ប្រវេប្រវាដើម្បីរកអង្ករបាយហ្នឹងឡើងវិញនេះ។ ហើយគឺពេលនេះគឺថាខ្ញុំក្នុងឋានៈជាកូនគាត់នោះ ខ្ញុំ -- អ្នកម្តាយខ្ញុំសូមប្តឹងដើម្បីគាត់នេះឯង។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៖**

តើអ្នកស្រីចង់ចោទសំណួរទៅជនជាប់ចោទ ពីរសំណួរ --

លោកប្រធានខ្ញុំចង់ដឹងថា តើគាត់ត្រូវសួរយ៉ាងម៉េច? គាត់ចោទសំណួរឆ្លងតាមលោកប្រធានឬក៏យ៉ាងម៉េច? អ្នកស្រីដើមបណ្តឹង រដ្ឋប្បវេណីអ្នកស្រីបានត្រៀមសំណួរហើយៗដឹងថាពីរសំណួរហ្នឹង។ ឥឡូវសូមអញ្ជើញចោទសួរ ឆ្លងតាមរយៈលោកប្រធាន។

[០៩:៥៥:៤២]

**លោកស្រី ធុច ផាន់ដារ៉ា-សៈ**

ខ្ញុំសូមចោទសំណួរពីរសំណួរទៅ ខៀវ សំផន។ ខ្ញុំចង់ដឹងថាហេតុអ្វីបានខ្មែរក្រហមនុំងសង្កត់តែទៅលើប្រជាជនថ្មីដែលហៅថាយើងមានឋានៈដូចគ្នាសោះហ្នឹង ម៉េចក៏សង្កត់ធ្ងន់ទៅលើតែប្រជាជនថ្មី? ហើយមួយទៀតទាក់ទងនឹងស្ម័យទិតៀនហ្នឹង ចង់ដឹងថាស្ម័យទិតៀនហ្នឹងដើម្បីអ្វី? មានន័យអ្វីទៅ?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះជូនសំណួរនេះទៅលោក ខៀវ សំផន ដើម្បីលោកអាចឆ្លើយតប

ទៅនឹងសំណួរនេះ។ លោកខៀវ សំផន!

[០៩:៥៣:៣០]

**លោក ខៀវ សំផន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអស់លោក លោកស្រីចៅក្រម។ សូមគោរពអង្គសវនាការទាំងមូល។ សូមគោរពបងប្អូនរួមជាតិទាំងអស់។

លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ដំបូងខ្ញុំសូមជម្រាបថា ខ្ញុំពិតមែនតែខ្ញុំមិនបាន ដឹងអំពីទុក្ខសោកវេទនាជាក់ស្តែងរបស់លោកស្រី។ ហើយស្តាប់លោកស្រីមកនិយាយនៅពេលនេះ ខ្ញុំក៏ខ្លោចផ្សាក្នុងចិត្ត យល់ដល់ទុក្ខសោកលំបាកវេទនារបស់លោកស្រី ព្រាត់ប្រាសកូនចៅប្តីសី។ ប៉ុន្តែសំណួររបស់លោកស្រីទាំងពីរនេះចំពោះខ្ញុំ វាទាក់ទងគ្នា។ សំណួរទី១ ទាក់ទងនឹងសំណួរទី២ គឺវាទាក់ទងទៅមនោគមន៍វិជ្ជាដែលគេហៅថាមនោគមន៍វិជ្ជានៃវណ្ណៈ និងការតស៊ូវណ្ណៈ។ ឯខ្ញុំជាបញ្ញាជន ខ្ញុំមិនមែនជាជនជាអ្នកមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជាទេ ហើយខ្ញុំសូមជម្រាបលោកស្រីថា មេដឹកនាំកម្ពុជាប្រជាធិបតេយ្យខ្លះរហូតដល់សមាជិកកម្ពុជាប្រជាធិបតេយ្យខ្លះបានចាត់ទុកខ្លួនខ្ញុំនេះ ដែលជាបញ្ញាជនជាន់ខ្ពស់ហ្នឹងជាមនុស្សជើងមិនជាប់ដី ហើយគ្មានបានការអីទេ។ អាហ្នឹងខ្ញុំជម្រាបលោកស្រីឲ្យច្បាស់យ៉ាងនេះ។ ក៏ប៉ុន្តែដោយខ្ញុំត្រូវបានបង្ខំចិត្តរត់គេចខ្លួនចេញពីភ្នំពេញទៅជ្រកកោននៅខាងបក្សកុម្មុយនីស្តកម្ពុជាការពារ។

[១០:០០:០៨]

នៅជាមួយគេ១ឆ្នាំ ២ឆ្នាំទៅ ក៏ខ្ញុំត្រូវចូលបក្សកុម្មុយនីស្តកម្ពុជា។ ហើយក៏ជាបណ្តើរៗក៏យល់គោលការណ៍របស់គេជាបណ្តើរៗបានខ្លះៗ។ ដូច្នេះ ខ្ញុំសូមជម្រាបលោកស្រីតាមលទ្ធភាពដែល ខ្ញុំបានយល់ដឹង។ ខ្ញុំសូមជម្រាបថាតាមទ្រឹស្តីមនោគមន៍វិជ្ជារបស់បក្សកម្ពុជាបដិវត្តន៍មានពីររយៈកាល។ រយៈកាលទី១ គេហៅថារយៈកាលបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ គឺជារយៈកាលដែលតស៊ូប្រឆាំងនឹងអាណានិគមនិយមបារាំង និងចក្រពត្តិអាមេរិក។ ដូច្នេះជារយៈកាលដែលត្រូវប្រមូលកម្លាំងជាតិទាំងអស់ធំទូលាយមករួបរួមគ្នាតស៊ូ។ សូម្បីជាជននោះ ជាជនសក្តិភូមិក៏គេប្រមូលដែរ។ ទោះបីជាទិសដៅរបស់គេជាត្រូវតែតស៊ូរំលាយរបបសក្តិភូមិដែលគេសន្មតថាជារបបជិះជាន់កសិករ។ ដូច្នេះ បងប្អូននៅភ្នំពេញជាច្រើនក៏ចូលរួមតស៊ូដែរ។ ចូលរួមតស៊ូតាមរូបភាពផ្សេងៗ ដូចជាធ្វើបាតុកម្ម ធ្វើវិទ្ធេទកម្មប្រឆាំងនឹងរបប លន់ នល់ ជាដើម ឬក៏ស្រាក់លុយគ្នាទិញថ្នាំសង្កូវ ពិសេសថ្នាំគ្រុនចាញ់ ផ្ញើទៅអ្នក

តស៊ូនៅក្នុងព្រៃ។ ពេលនោះសមានជនរបស់កម្លាំងតស៊ូមានច្រើនណាស់នៅភ្នំពេញ ភាគច្រើនលើសលប់តែម្ដង។ បើមិនបានផ្ដល់ធ្វើឧបត្ថម្ភ ធ្វើជាសកម្មភាពអ្វីក៏ក្នុងចិត្តរបស់ខ្លួនក៏គាំទ្រការតស៊ូ។ ហ្នឹងគឺសូមជម្រាបយ៉ាងនេះ ជារយៈកាលទី១។

[១០:០៣:២៤]

រយៈកាលទី២ គេហៅថារយៈកាលបដិវត្តន៍សង្គមនិយម និងរយៈកាលកសាងសង្គមនិយម។ នៅខែ តាមខ្ញុំចាំនៅខែមេសា -- នៅខែឧសភា នៅវិហារព្រះកែវ ជាលើកដំបូងបង្អស់ នៅពេលប្រជុំមជ្ឈិម នៅមុខអង្គប្រជុំមជ្ឈិមមួយនៅវិហារព្រះកែវ។ ប៉ុល ពត បានតំណាងឲ្យគណៈអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជាប្រកាសថា ជ័យជម្នះ១៧ មេសា ១៩៧៥ ជាទីបញ្ចប់នូវបដិវត្តន៍សង្គមនិយម -- នូវបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ។ មានន័យថាអស់រណសិរ្សរួបរួមជាតិកម្ពុជា អស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាហើយ គឺចូលរយៈកាលសង្គមនិយម កសាងសង្គមនិយម កសាងប្រទេស ការពារប្រទេស។

ប៉ុល ពត គិតដូច្នេះដោយយល់ថា សភាពការណ៍វាបន្ទាន់ណាស់។ វៀតណាមក្រោយគេរំដោះក្រោយគេបានរួបបង្រួមប្រទេសគេហើយ គេត្រូវការប្រទេសកម្ពុជាហើយ គេច្បាស់ជាបែរមកវ៉ៃកម្ពុជាហើយ។ ដូច្នេះកម្ពុជាត្រូវកសាងប្រទេសឲ្យលឿន ដើម្បីកុំឲ្យវៀតណាមដេញទាន់ត្របាក់លេប។ ដូច្នេះបដិវត្តន៍សង្គមនិយម កសាងសង្គមនិយមហ្នឹងជារួមមកមានស្អី គឺថាដីធ្លីទាំងអស់ វាទៅជាដីធ្លីលែងនៅជាកម្មសិទ្ធិរបស់សមាជិកសហករណ៍ទៀតហើយ គឺដីធ្លីទាំងអស់វាជា១កម្មសិទ្ធិរបស់សហករណ៍ ជាកម្មសិទ្ធិ គេប្រើពាក្យថា ជាកម្មសិទ្ធិរបស់ប្រជាជន។ ដូច្នេះយើងធ្វើទំនប់ ធ្វើប្រឡាយ វាររហ័ស វាមិនប្រទាក់នឹងដីនេះមួយអំពក ដីនោះមួយអំពក។ ដីរួមគ្នាទូទាំងប្រទេស វាជារបស់រួមទៅ វាលឿន ធ្វើទំនប់ក៏លឿន ជីកប្រឡាយក៏លឿន។

[១០:០៦:៤៥]

ហើយខ្ញុំបានឃើញអ៊ីចឹងមែន នៅឆ្នាំ៧៦ ដែលខ្ញុំមានឱកាសចេញពីភ្នំពេញម្ដងៗ ខ្ញុំបានឃើញទំនប់ ដូចជាត្រពាំងថ្ម ដូចជាទំនប់ខាងលិចបាត់ដំបង – ខ្ញុំភ្លេចឈ្មោះហើយ មិនដឹងជាទំនប់អី – ធំមែនទែន។ បើទំនប់ត្រពាំងថ្មវិញ ហាក់ដូចជាសមុទ្រនៅកណ្ដាលវាលដែលពីដើមហួតហែង ហើយវាចេញជាស្រែ ជាក្រឡាឈើត្រង់ មើលទៅដាច់កន្ទុយភ្នែក នាំឲ្យខ្ញុំមានចិត្តរំភើបរីករាយមែនទែន។ ហើយគេថា "មានស្រូវមានអ្វីៗទាំងអស់"។ គឺថាប្រជាជនក៏មានបានហូបគ្រប់គ្រាន់ នាំចេញទៅលក់នៅខាង

00917435



ក្រៅ ពិសេសនៅប្រទេសជាមិត្ត ហៅថាប្រទេសជាមិត្តនោះ គឺគេដាក់គេមើលពេលនោះមានប្រទេស ចិន ប្រទេសកូរ៉េ ប្រទេសយូហ្គោស្លាវី ជាដើម។

ហើយយើងអាចទិញឧបករណ៍បង្កបង្កើនផលមកវិញ តាំងពីចប កាំបិត ពូថៅ ឡើងទៅរហូតដល់រោងចក្រជាបណ្ដើរៗ ហើយនិងដែកថែបដើម្បីធ្វើទ្វារទឹក បិតទឹកចេញចូល បង្ហូរទឹកចូលស្រែ។ ហើយខ្ញុំឃើញៗគេទិញគ្រឿងចក្រធំៗណាស់ សម្រាប់ជួយជាកម្លាំងប្រជាជនដែរ ប៉ុន្តែចែកមិនទាន់ក៏ត្រូវរៀតណាមចូលមកកម្ពុជាទៅ ដោយចែកមិនទាន់។

[១០:០៩:១៣]

បាទ ខ្ញុំចង់និយាយថា ខ្ញុំបានឃើញទំនប់ទាំងអស់នោះ ខ្ញុំរីករាយរំភើបចិត្តមែនទែនពេលនោះ។ ប៉ុន្តែដល់មកស្ដាប់សក្ខីកម្មបងប្អូនដែលបានមករួម ដែលបានមកធ្វើសក្ខីកម្មជាបន្តបន្ទាប់ ទើបខ្ញុំរន្ធត់ចិត្តខ្លាំងមែនទែន។ ខ្ញុំមិនបានដឹងថាទំនប់នោះ ប្រឡាយនោះ វាបានមកដោយការបង់ថ្លៃវាខ្ពស់យ៉ាងនេះទេ។ ខ្ញុំមិនដឹងទាល់តែសោះ សូមជម្រាបលោកស្រី ហើយខ្ញុំក៏រន្ធត់ចិត្តមែនទែន ពេលដែលស្ដាប់សាក្សី ឬ ភាគីរដ្ឋប្បវេណី ដើមបណ្ដឹងរដ្ឋប្បវេណីម្ដងៗមក។ នេះសូមជម្រាបយ៉ាងនេះ។

ឥឡូវអំពីបញ្ហាមួយទៀត ដោយសារគេយល់អ៊ីចឹងហើយបានគេថា ទាំងអស់គ្នាត្រូវសម្រួចកម្លាំងជាតិទាំងអស់ ត្រូវខំធ្វើទំនប់ ធ្វើប្រឡាយ ហើយអ្នកមកក៏និយាយពីរឿងទំនប់ប្រឡាយអ៊ីចឹងមែន។ អាហ្នឹងហើយដែលខ្ញុំចង់ជម្រាបថា អត់មានទិសដៅបែងចែកជាតិយើងទេ។ ឯពីរឿងគេហៅថា ទិតៀន ស្វ័យទិតៀន ក៏នៅក្នុងក្របខ័ណ្ឌ គេហៅថា វណ្ណៈ និងតស៊ូវណ្ណៈ មនោគមន៍វិជ្ជាវណ្ណៈ និងតស៊ូវណ្ណៈហ្នឹងដែរ។ ពិសេសបក្ខជនៗហ្នឹងត្រូវក្នុងរយៈកាលបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ត្រូវលះបង់ជាងគេ ធ្វើជាគំរូដល់ជាតិ ដល់ប្រជាជនទាំងមូល ដើម្បីគេស្ម័គ្រចិត្តមកចូលរួមជាមួយក្នុងការតស៊ូ ហើយដើម្បីមានទស្សនៈយ៉ាងនេះ ដែលត្រូវធ្វើការទិតៀន ស្វ័យទិតៀន។ អ៊ីចឹងហើយបានជាកងទ័ពប្រជាធិបតេយ្យកម្ពុជា អ្នកណាក៏ទទួលស្គាល់ដែរ ថាជាកងទ័ពដែលប្រយុទ្ធស្រួចស្រាល់ដែលមានវិន័យខ្ពស់ វាមិនដូចពួកខ្មែរសេរីដែលដើរប្លន់ ឆក់ប្លន់ប្រជាជននោះទេ។ ខ្ញុំជម្រាបអ៊ីចឹង។

[១០:១២:៣៦]

ឯខ្ញុំវិញ ខ្ញុំក្នុងការទិតៀន ស្វ័យទិតៀននេះ ខ្ញុំក៏ត្រូវតែធ្វើហ្នឹងគេដែរ ដើម្បីកសាងខ្លួនឲ្យទៅជាវណ្ណៈអធន ពេលៗចូលក្នុងរបបរយៈកាលបដិវត្តន៍សង្គមនិយម កសាងសង្គមនិយមនេះ។ ក៏ប៉ុន្តែខ្ញុំវាលះបង់ចោលធាតុដើមរបស់ខ្លួនវាអត់បាន វានៅតែវណ្ណៈអនុធន វានៅតែគំនិតអនុធន ជាប់នឹងរឿង

កម្មសិទ្ធិកំប៉ិកកំប៉ុក ស្រឡាញ់កូន ស្រឡាញ់ចៅ។ ចិត្តហៅថា តាំងចិត្តហើយថាតម្កល់ផលប្រយោជន៍ការតស៊ូខ្ពស់ជាងអ្វីៗទាំងអស់។ ក៏ប៉ុន្តែឲ្យលះបង់ខ្ពស់ ហើយប្រមូលចិត្តថ្លើមគិត តាមគិតគូឃើញអ្វីៗទៅតាមទស្សនៈវណ្ណៈអធន ទស្សនៈកសិករក្រ ទស្សនៈកសិករកណ្តាល ថ្នាក់ក្រោម ខ្ញុំធ្វើមិនកើត។ ឯអ្នកដឹកនាំឯទៀតៗ ខ្លះគេជាបញ្ញាជនមែន ប៉ុន្តែគេជាបញ្ញាជនថ្នាក់ទាប ហើយឆ្លងកាត់ការតស៊ូវណ្ណៈជាបន្តបន្ទាប់ ឆ្លងកាត់ការទិតៀន ស្វ័យទិតៀន ជាបន្តបន្ទាប់។ គេកសាងខ្លួនគេបាន គេកម្ចាត់ចោលទស្សនៈអនុធនរបស់គេបាន គេគិតគូតែការតស៊ូ ដង្ហើមចេញចូលរបស់គេជាប់តែនឹងការតស៊ូ។ ឯខ្ញុំខ្ញុំធ្វើមិនបានដូចគេទេ។ នេះខ្ញុំសូមជម្រាបលោកស្រីដោយត្រួសៗប៉ុណ្ណេះ។

បាទ សូមអស់ សូមអរគុណ ហើយយ៉ាងម៉េចៗ សូមអធ្យាស្រ័យដល់ខ្ញុំផងចុះ។ ដូចខ្ញុំបានជម្រាបហើយ ខ្ញុំមិនមែនជាអ្នកមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជាទេ។

[១០:១៥:១០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អញ្ជើញលោកស្រីមេធាវី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាអ្នកស្រី ហ្វេនីញ៉េស គាត់ចង់ដែលនិយាយខ្លីទេ ជាចុងក្រោយនេះ ប្រហែលជាពីរបីឃ្លាទេ។ ហើយអ៊ីចឹងខ្ញុំចង់ដឹងថាលោកប្រធានអនុញ្ញាតឬក៏អត់? ខ្ញុំ--

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! ដើម្បីមុននឹងអនុញ្ញាតសូម -- សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។ ខ្ញុំពិនិត្យមើលពេលវេលា កូនក្តីរបស់ខ្ញុំបានណែនាំខ្ញុំថា គាត់នឹងឆ្លើយសំណួរដែលដាក់ដោយដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែមានពេល ឬអត់? បើតុលាការអនុញ្ញាត គាត់ក៏ចង់ឆ្លើយទៅនឹងសំណួរនេះដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! លោក នួន ជា លោកអាចឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីអម្បាញ់មិញនេះ។ សំណួរយើងរៀបឡើងវិញ ហេតុអ្វីបានជាខ្មែរក្រហម

សង្កត់ធ្ងន់តែទៅលើប្រជាជនថ្មី ព្រោះពួកគេមានឋានៈដូចគ្នា គឺដូចគ្នានឹងប្រជាជនដទៃទៀត ហើយក៏ដូចគ្នាទៅនឹងមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យដែរ? នេះជាសំណួរទី១។ សំណួរទី២ អ្វីទៅស្វ័យទិតៀន មានន័យថាដូចម្ដេច? សូមលោក នួន ជា ឆ្លើយ!

[១០:១៧:១៤]

**លោក នួន ជា៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធានជាទីគោរព! សូមគោរពបងប្អូនរួមជាតិទាំងអស់ ទាំងក្នុងប្រទេស ទាំងក្រៅប្រទេស។ ខ្ញុំសូមបញ្ជាក់នូវសំណួរនេះទៅតាម-- ពីព្រោះខ្ញុំមានសុខភាពមិនអំណោយឲ្យ នេះ ខទី១។ ខទី២ ខ្ញុំឆ្លើយទៅតាមអ្វីដែលមានប្រយោជន៍ដល់ជាតិ និងប្រជាជនខ្ញុំ។

ហើយជាបឋមនេះ ខ្ញុំសូមគោរពនូវវិញ្ញាណក្ខន្ធរបស់ប្រជាជនទាំងអស់ របស់ក្រុមគ្រួសារអ្នកដែលត្រូវបាត់បង់បងប្អូន សាច់ញាតិទាំងអស់ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ទោះបីជាក្នុងសម័យនោះវាស្មុគស្មាញ មានច្រើនបក្ខពួកដែលអាងខ្លួនថាជាកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏ប៉ុន្តែក្នុងឋានៈដឹកនាំ ខ្ញុំ នួន ជា ក៏ត្រូវតែទទួលស្គាល់នូវការខ្វះខាតរបស់ខ្លួន។ ខ្ញុំទទួលស្គាល់ ក៏ប៉ុន្តែខ្ញុំម្ដងទៀត ខ្ញុំសូមសម្ដែងនូវការសោកស្ដាយ ដោយការដឹកនាំនេះ វាមិនបានដិតដល់ នេះ ខទី១។

ខទី២ ខ្ញុំសូមបញ្ជាក់នូវសំណួរដូចតទៅនេះ ដែលថាបែងចែកប្រជាជន១៧មេសា និងប្រជាជនមូលដ្ឋាននោះ។ ប្រការនេះតាមខ្ញុំយល់ គោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជាមិនមានការបែងចែកអ្នកមូលដ្ឋាន និងអ្នកថ្មីតែបន្តិចណាសោះឡើយ ពីព្រោះយើងត្រូវការរួមរួបជាតិ ឯកភាពជាតិ សាមគ្គីជាតិទាំងអស់ដើម្បីការពារប្រទេសឲ្យរួចផុតអំពីការឈ្លានពាន វាតទី លេបទឹកដីរបស់ប្រទេសជិតខាង ដូចជាបងប្អូនបានជ្រាបហើយ អ្នកណា? ខ្ញុំមិនបាច់ចង្អុលឈ្មោះថាអ្នកណាទេ ប៉ុន្តែឃើញច្បាស់ហើយៗ។ ប្រទេសជិតខាងយើងដែលគេមានមហិច្ឆតាឈ្លានពានវាតទីប្រទេសយើង គ្រោះថ្នាក់ធំណាស់ដល់ប្រទេសជាតិយើង។ នេះខ្ញុំសូមបញ្ជាក់។

[១០:២០:០១]

ក្រៅពីនេះ ខ្ញុំគឺក៏មានគោលបំណងរួមជាមួយប្រជាជនទាំងអស់អ្នកស្នេហាជាតិទាំងអស់ ដើម្បីការពារជាតិ ការពារប្រជាជន នេះខទី១។ ដូច្នេះគ្មានសំណួមពរអីទៅបែងចែកជាតិឯងយ៉ាង នេះយ៉ាងនោះអ្នកថ្មីអ្នកចាស់អត់ទេ។

ខទី២ អំពីការស្វ័យទិតៀន និងការទិតៀន។ ត្រង់នេះខ្ញុំសូមបញ្ជាក់ថាការទិតៀន និងការស្វ័យ

ទិតៀនដើម្បីបំបាត់ ឬកម្ចាត់នូវធាតុ។ ខ្ញុំសូមបញ្ជាក់ថាធាតុ ធាតុអាក្រក់ ធាតុដែលមិនមែនជាអ្នកស្នេហាជាតិដែលនៅក្នុងខ្លួនយើងឲ្យអស់ មិនមែនកម្ចាត់បុគ្គលទេ សូមបញ្ជាក់ថែមទៀតថាកម្ចាត់ធាតុ។ នេះខ្ញុំសូមបញ្ជាក់ហើយបញ្ជាក់ទៀត។ កុំច្រឡំ សូម្បីនៅក្នុង ផ្ទៃក្នុងយើងខ្ញុំក៏មានការភាន់ច្រឡំខ្លះដែរកាលពីមុនណ៎ា។ ដូច្នោះភាន់ច្រឡំរហូតដល់ទៅការកសាងសង្គមនិយម រួបរួម គេថា រួបរួមៗអី? រួបរួមមធ្យោបាយបង្កបង្កើនផលទេ មិនមែនរួបរួមទ្រព្យសម្បត្តិ បុគ្គលអីជាកង់ជាអីៗនោះ មិនមែនទេ។ មានការភាន់ច្រឡំច្រើនណាស់ ខ្ញុំសូមបញ្ជាក់ហើយបញ្ជាក់ទៀត គឺប្រមូលនូវមធ្យោបាយបង្កបង្កើនផលដូចជាដីធ្លីនេះរួមគ្នាមកដើម្បីយើងធ្វើឲ្យបានស្រួលធ្វើទំនប់ទប់ ទំនប់ទឹកក៏បាន ធ្វើអីៗក៏បានវាមិនកំប៉ិកកំប៉ុកតូចតាចអីច្រើនទេ។ នេះបញ្ហានេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

[១០:២១:៥៤]

**ប្រធានអង្គជំនុំ៖**

អរគុណលោក នួនជា។

ជាបន្តនេះអង្គជំនុំជម្រះផ្តល់ឱកាសជូនទៅដើមបណ្តឹងរដ្ឋប្បវេណីនិយាយចុងក្រោយប៉ុន្មាននាទីដែលបានស្នើសុំតាមរយៈមេធាវីរបស់ខ្លួន។ សូមអញ្ជើញលោកស្រី ផាន់ដារា!

**លោក នួន ជា៖**

ខ្ញុំសូមបន្តដូចតទៅនេះ គ្រួសារខ្ញុំក៏បានទទួលនូវគ្រោះកម្ម នេះខ្ញុំសូមបញ្ជាក់ជាក់ស្តែងដូចជា ស្ងួន កាសេត។ ស្ងួន កាសេត នេះត្រូវជាក្មួយខ្ញុំបង្កើត ស្រាប់តែស្លាប់ ខ្ញុំស៊ើបសួរទៅថាទៅ ខ្ញុំមិនដែលដឹងផង ហើយ ភូ យឹង ដែលជាគ្រូបង្រៀន, ស៊ីវ ហេង សុទ្ធតែជាសាច់ញាតិរបស់ខ្ញុំទាំងអស់។ ហើយខ្ញុំត្រូវការអីទៅសម្លាប់ជាតិឯងប្រជាជនឯង អត់ទេ។ នេះខ្ញុំសូមបញ្ជាក់ហើយបញ្ជាក់ទៀត។ គ្រួសារខ្ញុំក៏ខ្ញុំការពារមិនបានផង។ ពេលរំដោះហើយ ខ្ញុំទៅជួបម្តាយខ្ញុំ ម្តាយខ្ញុំយំថាអញអ្ហា! គេច្រានអញដួលត្រឡប់ត្រលិនអ្ហា។ ខ្ញុំថាច្រានរឿងអីម៉ែ? ពេលជម្លៀស ចុះអញនៅភូមិ អញទៅជម្លៀសទៅឯណាទៀត? ដូច្នោះខ្ញុំយល់ឃើញថា ក្នុងកម្ពុជាប្រជាធិបតេយ្យហ្នឹងក៏មានអ្នកដែលមិនល្អដែរ។ នេះខ្ញុំសូមបញ្ជាក់ហើយបញ្ជាក់ទៀតដូចតទៅ ដូចអ៊ីចឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក នួន ជា។ ការឆ្លើយតបនឹងសំណួរពីរសំណួរដែលសួរឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណឹងចុះ ឃើញថាសមល្មមហើយនៅចម្លើយតបរបស់លោកចំពោះសំណួរដែល

សួរ។ ឥឡូវនេះអង្គជំនុំជម្រះអស់ពេលហើយ។ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុម -- ទៅដើមបណ្តឹងរដ្ឋប្បវេណីដើម្បី មានឱកាសនិយាយចុងក្រោយ ដែលគាត់បានស្នើសុំ។

សូមអញ្ជើញលោកស្រី ផាន់ដារា!

[១០:២៣:៥០]

**លោកស្រី ធុច ផាន់ដារា-សះ**

ខ្ញុំគ្រាន់តែសុំឲ្យលោក ទៅលោក ខៀវ សំផន ដែលជាបញ្ញាជន ហើយកាន់សាសនាព្រះពុទ្ធ ដើម្បីសុំឲ្យគាត់លើកដៃសំពះ ឧទ្ទិសកុសលដល់ព្រលឹងអ្នកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ទៅទាំងអស់។ ហើយអ៊ីចឹងយើងធ្វើដូច្នេះទៅដើម្បីឲ្យព្រលឹងរបស់គាត់ហ្នឹងទៅកាន់សុគតិភពឲ្យស្គាល់សន្តិភាព ថាឲ្យវិញ្ញាណក្ខន្ធគាត់ហ្នឹងទៅដល់សុគតិភព។ អ៊ីចឹងគ្រាន់តែជាសំណូមពរទេ សុំឲ្យលោក ខៀវ សំផន លើកដៃសំពះដូចជាខ្ញុំដែរ ព្រោះយើងកាន់សាសនាព្រះពុទ្ធដូចគ្នា ហើយក៏ជាបញ្ញាជនដូចគ្នាដែរ។

**លោក ខៀវ សំផន៖**

ខ្ញុំបានរួមចំណែក ដែលខ្ញុំមិនដឹងថាបងប្អូនសាច់ញាតិលោកស្រីបានត្រូវជួបប្រភពនិងទុក្ខលំបាកវេទនា ហើយបងៗប្អូនជាច្រើនត្រូវជួបប្រទះ រួមទាំងបងប្អូនកសិករមូលដ្ឋានផងដែរហ្នឹង ជួបប្រទះនឹងទុក្ខសោកវេទនាជាច្រើន។ ខ្ញុំរន្ធត់ចិត្តណាស់ ហើយរួមព្រមជាមួយនេះ ខ្ញុំមិនភ្លេចដល់វិញ្ញាណក្ខន្ធដល់យុទ្ធជនយុទ្ធនារីដែលលូនទៅវ៉ៃរំដោះភ្នំពេញ ក្រោមគ្រាប់បែកបេ៥២ក្រាលព្រំ។ អ្នកស្លាប់ក៏ស្លាប់ទៅ អ្នកនៅក៏ចេះតែខំរុលទៅឲ្យជិតកងទ័ព លន់ នល់ ដើម្បីកុំឲ្យគ្រាប់បែកយន្តហោះបេ៥២វាទម្លាក់ៗត្រូវ។ ទៅកៀកឲ្យជាប់ លន់ នល់។ ដូច្នេះបងប្អូនប្រយុទ្ធតស៊ូនេះក៏មានពលីជីវិតច្រើនណាស់។ ហើយខ្ញុំសូមលើកដៃសំពះគោរពដោយសុភាពរាបសា ដល់វិញ្ញាណក្ខន្ធវរយុទ្ធជនវរយុទ្ធនារីទាំងអស់នេះ ក៏ដូចជាដល់វិញ្ញាណក្ខន្ធបងប្អូនយើងទាំងអស់ ដែលបានត្រូវពលីជីវិតទៅក្នុងសភាពការណ៍ប្រទេសយើងដែលវាត្រូវជួបប្រទះអស់ពីសង្គ្រាមអាមេរិក វាជាប់នឹងសង្គ្រាមវៀតណាម។ និយាយរួមកម្ពុជាប្រជាធិបតេយ្យ គ្មានទាន់បានស្គាល់សន្តិភាពមួយៗរយៈពេលណាមួយទេ។ អានេះ ខ្ញុំសូមគោរពដល់វិញ្ញាណក្ខន្ធបងប្អូនទាំងអស់។

[១០:២៧:០៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ខៀវ សំផន។ ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅដើម -- តំណាងសហ

ព្រះរាជអាជ្ញាដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ ហើយមានរយៈពេល១០នាទីបាទ។

**លោក ឃីត វេយ៍ន័រ៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងសវនាការទាំងមូល ហើយនិងមេធាវីទាំងអស់។ ហើយជាពិសេសលោកស្រី ផាន់ដារា-ស។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** ហើយខ្ញុំសូមអនុញ្ញាតនឹងសួរសំណួរពីរផ្នែកនៅក្នុងសក្ខីកម្មរបស់លោកស្រី។ ទី១ទាក់ទងទៅនឹងបុគ្គលដែលលោកបាននិយាយទៅ និយាយអំពីឧត្តមសេនីយ៍ ថាច់ សារី។ សូមលោកស្រីរៀបរាប់ថាតើជាសាច់ញាតិអ្វីជាមួយនឹង ថាច់ សារី នេះជាមួយនឹងលោកស្រីបាទ?

[១០:២៨:១៨]

**លោកស្រី ធុច ផាន់ដារា-ស៖**

**ផ៖** ឧត្តមសេនីយ៍ ថាច់ សារី ជាបងប្អូនជីដូនមួយថ្លៃរបស់ខ្ញុំ គាត់រៀបអាពាហ៍ពិពាហ៍ជាមួយបងប្អូនជីដូនរបស់ -- បងប្អូនស្រីជីដូនមួយរបស់ខ្ញុំ។ ដូច្នេះនិយាយទៅ គឺគាត់ជាបងប្អូនជីដូនមួយថ្លៃ។

**ស៖** តើគាត់ជួបជោគវាសនាដូចម្តេច?

**ផ៖** នៅថ្ងៃដែលខ្មែរក្រហមចូល បងប្អូនជីដូនមួយខ្ញុំចេញពីផ្ទះ។ បើតាមសម្តីរបស់បងប្អូនជីដូនមួយមួយទៀត ដែលជួបយើងនៅអង្គរមាសនោះ គាត់ប្រាប់ថា គាត់ត្រូវបានគេប្រកាសហៅតាមវិទ្យុឲ្យទៅបង្ហាញខ្លួននៅក្រសួងឃោសនាការ។ ដូច្នេះលោក ថាច់ សារី ហ្នឹងក៏គាត់ធ្វើដំណើរទៅ។ ហើយបងប្អូនជីដូនមួយស្រីរបស់ខ្ញុំហ្នឹង បានប្រាប់ថា គាត់ហ្នឹងឃើញគេសម្លាប់លោក ថាច់ សារី ដែលជាបងប្អូនជីដូនមួយថ្លៃហ្នឹង។ គាត់ជាអ្នករាយការណ៍ប្រាប់ខ្ញុំ អំពីការសម្លាប់នេះ។

[១០:២៩:៣៧]

**ស៖** ខ្ញុំបានស្រាវជ្រាវក្នុងឯកសារ ក្នុងរឿងក្តីនេះ ខ្ញុំចង់ពិនិត្យមើលឈ្មោះជាការប្រកបអក្សរឯកសារ E3/276។ ខ្ញុំមានសេចក្តីដកស្រង់តែជាភាសាអង់គ្លេស ដោយសារពី -- បានមកពីក្រសួងការបរទេស ជាបណ្ណាសារក្រសួងការបរទេសសហរដ្ឋអាមេរិក។ អង់គ្លេស ERN 00168021 ដល់1។ នៅក្នុងឯកសារនេះ គឺមានចំណងជើងថា "និយាយអំពីទីភ្នាក់ងារសារព័ត៌មានបារាំងដែលបញ្ជាក់ថា

ឧត្តមសេនីយ៍នោះ គឺត្រូវបានគេសម្លាប់ ផ្សព្វផ្សាយតាមទីក្រុងហុងកុង"។ ជាភាសាអង់គ្លេស នៅថ្ងៃទី ២១ ឧសភា ឆ្នាំ១៩៧៦។ អត្ថបទនោះ មានខ្លឹមសារដូចខាងក្រោម ខ្ញុំសូមដកស្រង់៖ "បាងកក ថ្ងៃទី២១ ខែឧសភា ខ្មែរក្រហមបានចាប់បានឧត្តមសេនីយ៍៥៤នាក់របស់កម្ពុជា នៅពេលដែលកាន់កាប់ទីក្រុងភ្នំពេញនោះ នៅថ្ងៃទី -- នៅខែមេសា ឆ្នាំ១៩៧៥ ហើយមានរបាយការណ៍ថា ខ្មែរក្រហមបានសម្លាប់អ្នកទាំងនោះ ហើយជាញឹកញាប់គឺសម្លាប់ទាំងក្រុមគ្រួសារផងដែរ។ ចលនាតស៊ូនោះបានប្រកាសថ្ងៃនេះ ហើយគឺមានបញ្ជីឧត្តមសេនីយ៍ទាំង៥៤នាក់នោះ"។ ហើយខ្ញុំចង់ពិនិត្យមើលថាតើប្រាកដថាការសរសេរឈ្មោះនោះ ដូចខាងក្រោមនេះត្រឹមត្រូវដែរឬទេ? គឺ ធី-អេច-អេ-ស៊ី-អេច។ បាទ ឈ្មោះគាត់សារី គឺ អេស-អេ-អ័រ-វ៉ាយ តើនេះជាសរសេរឈ្មោះត្រឹមត្រូវនូវបងជីដូនមួយរបស់លោកស្រីដែរឬទេដែលថាឈ្មោះ ថាច់ សារី នោះ?

[១០:៣១:៥៧]

**ផ៖** ត្រឹមត្រូវហើយលោក គឺសរសេរអ៊ីចឹងហើយ គឺ តេ-អះ-អា-សេ-អះ-អេស-អា-អែរ-អ៊ីហ្គារិច– ថាច់ សារី គាត់ប្រធានផ្នែកភ័ស្តុភារនៅសម័យរបប លន់ នល់។

**សៈ** នៅពេលដែលលោកបានឮថា លោក ថាច់ សារី ត្រូវបានគេសម្លាប់នោះ តើអ្នកនោះបានប្រាប់ថាគេសម្លាប់អ្នកផ្សេងទៀតទេ នៅថ្ងៃនោះ ដែលជាអ្នកដែលមានទំនាក់ទំនង ឬក៏ជាអតីតទាហាននល់ នល់ នោះបាទ?

**ផ៖** ខ្ញុំអត់ដឹងព័ត៌មានលម្អិតទេ គាត់បានប្រាប់ គាត់មិនបានប្រាប់ខ្ញុំលម្អិតនោះទេ។ គឺថាចំពោះយើងនោះ គឺថាយើងគ្រាន់តែធ្វើពិធីបុណ្យតូចមួយដើម្បីរំឭកវិញ្ញាណក្ខន្ធគាត់ ហើយអ៊ីចឹង យើងអត់អាចនិយាយអីលើសពីហ្នឹងទៀតទេ សូមអភ័យទោសផងលោក។

[១០:៣៣:០០]

**សៈ** ឥឡូវនេះ ខ្ញុំចូលដល់ប្រធានបទផ្សេង។ នៅពេលដែលលោកស្រីបានបញ្ជាក់ថា គេដឹកតាមកាមីញ៉ុង ដឹកតាមខេត្តកំពង់ឆ្នាំង ទៅដល់ខេត្តពោធិ៍សាត់ ហើយលោកស្រីបាននិយាយថា មានការដឹកបន្តទៅតាមរថភ្លើងដែលដឹកសត្វ ដឹកគោក្របី។ លោកស្រីបានដឹងពីការជម្លៀសទីក្រុងភ្នំពេញ គឺនៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥។ តើលោកស្រីអាចប្រាប់ខ្ញុំបានទេថា តើប៉ុន្មានខែក្រោយមក ឬក៏នៅក្នុងឆ្នាំណាដែលគេដឹកលោកស្រីតាមរទេះភ្លើងដឹកសត្វពាហនៈ ទៅដល់ខេត្តពោធិ៍សាត់នោះ?

**ផ៖** ចំពោះចំណុចនេះ គឺថាខ្ញុំដូចជាមិនច្បាស់ទេ ខ្ញុំមិនដឹងថាតើប៉ុន្មានខែ ប៉ុន្មានថ្ងៃនោះទេ ខ្ញុំ

ភ្លេចហើយ ព្រោះថាវាយូរហើយ។ ក៏ប៉ុន្តែហ្នឹងគឺថារថភ្លើងហ្នឹង គឺថាដឹកយើងពីអង្គរមាសចេញទៅ ហើយគឺថាពេលទៅដល់ហ្នឹង គឺថាគេដឹកចេញពីអង្គរមាសហ្នឹងទៅដល់ភ្នំជើងទិញ។ លោកដឹងហើយថា ពេលនុំង គឺថាអត់មានពេល មានវេលាអីទេ យើងអត់ដឹងអីទាំងអស់។ គឺថាពេលហ្នឹង គឺថាវែងណាស់ សូម្បីតែ២០ថ្ងៃហ្នឹង គឺដូចជា២ខែ ៣ខែអីចឹង។ អីចឹងរយៈពេលតែ៣០ថ្ងៃជាង គឺដូចជា១ឆ្នាំ ២ឆ្នាំអីចឹង គឺថាពេលវេលាដូចថាអត់មានជាក់លាក់ទេ នៅពេលហ្នឹងនោះ។

[១០:៣៤:៤០]

**ស៖** តើលោកស្រីមានជម្រើសទេ ថាត្រូវជិះ ឬក៏មិនត្រូវជិះទៅលើរថយន្តដឹកសត្វពាហនៈនោះ នៅពេលនោះ?

**ឆ៖** ខ្ញុំអត់មានជម្រើសទេ ពីព្រោះថាមានទាហាននៅពីក្រោយយើងរហូត គឺថាគេរុញយើងឲ្យចាប់យើងដាក់រថភ្លើងតែម្តង ហើយមនុស្សគឺថានៅពាសពេញតែម្តងនៅក្នុងរថភ្លើងនោះ។

**ស៖** លោកស្រីបានរៀបរាប់ពីសម័យដែលទៅដល់កន្លែងនោះ នៅពេលដែលមានថា ទុរ្ភិក្ស ការអត់ឃ្លានហ្នឹងខ្លាំងឡើង តើលោកអាច លោកស្រីអាចជម្រាបតុលាការដែរឬទេ ថាតើនៅពេលដែលទៅដល់ព្រៃ តើអ្នកទាំងអស់នោះបានចាប់ផ្តើមស្លាប់ដែរឬទេ អ្នកដែលជម្លៀសទៅដល់ទៅនោះៗ?

**ឆ៖** នៅពេលដែលខ្ញុំនៅភ្នំជើងទិញ គឺថាយើងចាប់ផ្តើមមានបញ្ហាសុខភាពជាច្រើន យើងអត់មានម្ហូបអាហារហូបចុកទេ។ ដូច្នេះមានអ្នកខ្លះនោះគាត់ព្យាយាមទៅរកបន្លែព្រៃ ទៅរកបន្លែបង្កាអីចឹង។ ខ្ញុំក៏ខ្ញុំទៅរកស្ពៃដែរ ហើយនៅពេលនុំងគឺថាមានមុតបន្លាមុតអី ហើយដូច្នេះស្នាមហ្នឹងគឺថានៅជាប់រហូតអីចឹង គឺថាខ្ញុំពេលហ្នឹងគឺថាគ្រុន ហើយអត់មានការរះកាត់អីទេ។ ដូច្នេះពេលនុំងគឺថាភាពអត់ឃ្លាននោះកើតមានហើយតាំងពីពេលនុំងមកនោះ។ ពួកគេមិនបានផ្តល់អាហារឲ្យយើងហូបចុកទេ។

[១០:៣៦:៣៩]

**ស៖** បាទនេះជាសំណួរចុងក្រោយរបស់ខ្ញុំលោកស្រី។ បាទ លោកស្រីបានទៅដល់ភ្នំនោះ ដែលថាព្រៃ។ សំណួរចង់សួរថា តើអ្នកទាំងនោះស្លាប់ក្នុងរយៈពេល១ម៉ោង ១អាទិត្យ ឬក៏១ខែក្រោយពីការទៅដល់តំបន់ព្រៃនោះបាទ?

**ឆ៖** ខ្ញុំបានឃើញអ្នកខ្លះហូបបន្លែ ឬក៏ស្មៅច្រើនពេកហើយរាករូស ហើយពេលនោះក៏ចាប់ផ្តើមមានអ្នកស្លាប់ ក៏ប៉ុន្តែនៅគ្រួសារខ្ញុំទេ ទាល់តែឆ្នាំ៧៦ហើយទេបានមានអ្នកចាប់ផ្តើមស្លាប់ម្តងបន្តកន្ទុយគ្នានោះ ម្នាក់ម្តងៗនោះ។

**លោក ឃីត រេយ៉ន័រ៖**

សូមអរគុណលោកស្រី ខ្ញុំមិនមានសំណួរអ្វីទៀតទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

សូមអញ្ជើញ!

[១០:៣៧:៥៥]

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន!

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក សុន អរុណ៖**

**ស៖** សូមជម្រាបសួរអ្នកស្រីសាក្សី។ ខ្ញុំមានសំណួរតែពីរទេ ហើយសហការីរបស់ខ្ញុំ សហភាតាខ្ញុំនឹងមានសំណួរពីរទៀត។ សំណួរទី១ ខ្ញុំបានឮលោកស្រីបានជម្រាបទៅតុលាការថាៗ "ឆ្នាំ ១៩៧២ គ្រាប់ផ្លោងរបស់វៀតកុងធ្លាក់មកលើផ្ទះខ្ញុំ មិនមែនគ្រាប់របស់ខ្មែរក្រហមទេ"។ ខ្ញុំសួរថា តើអ្នកស្រីដឹងដោយសារអ្វី បានជាអ្នកស្រីដឹងថាគ្រាប់ផ្លោងរបស់យៀកកុង?

**លោកស្រី ធុច ផាន់ដារ៉ា-សះ**

**ឆ៖** ពីព្រោះថា មានឯកសារចេញមកពីឪពុកខ្ញុំដែលវ៉ៃជាអង្គលីលេខជាភាសាបារាំង ដែលគាត់សុំដូរមុខតំណែង ហើយនៅក្នុងឯកសារនុ៎ងគាត់សរសេរថា "នៅថ្ងៃទី០៦ ឧសភា នោះគឺថាពួកវៀតកុងបានបាញ់ផ្លោងមកលើផ្ទះ"។ ព្រោះថាគាត់ក៏គាត់ធ្វើជាយោធាដែរ គាត់ធ្វើការក្រោមបង្គាប់របស់ឧត្ដមសេនីយ៍ ថាច់ សារី ហើយពីមុនហ្នឹងគាត់ជានាយកផ្នែកហិរញ្ញវត្ថុនៅខាងរដ្ឋករស្វយ័ត។ អ៊ីចឹងខ្ញុំផ្អែកលើឯកសារហ្នឹងហើយ បានខ្ញុំប៊ានថាយៀកកុងអ្នកបាញ់ផ្លោងនោះ ហើយខ្ញុំមាននៅប៉ារីសនូវឯកសារនុ៎ង ហើយខ្ញុំក៏បានផ្ដល់ចម្លងជូនមេធាវីរបស់ខ្ញុំដែរ បើសិនជាលោកចង់ឃើញនោះ។

[១០:៣៩:៤៣]

**ស៖** អរគុណ។ នេះជាប្រវត្តិសាស្ត្រសំខាន់ណាស់។ ហើយខ្ញុំសូមសួរបន្ទាប់សំណួរអំមិញបន្ថែមបន្តិចទៀតថា បើអ៊ីចឹងមានន័យថានៅឆ្នាំ១៩៧២ នុ៎ងមាន យៀកកុង វ៉ៃចូលដល់ស្រុកខ្មែរហើយ

អ៊ីចឹងទេ? មានៗក្នុងសំបុត្រហ្នឹងមានបន្ថែមថាអ៊ីចឹងទេ មានន័យថាអ៊ីចឹងដែរ? ពីព្រោះអីពេលហ្នឹងយើងច្បាំងជាមួយនឹងខ្មែរក្រហម ខាង លន់ នល់ ច្បាំងជាមួយខ្មែរក្រហម។ ប៉ុន្តែហេតុអីបានជាទ័ពយៀកកុង ចូលផ្ទះអ្នកស្រីទៅវិញ? អ៊ីចឹងមានន័យថាប្រហែលជាពេលហ្នឹង យៀកកុង ចូលមកវៃស្រុកខ្មែរដែរ។

**ឆ៖** ខ្ញុំមិនឆ្លើយទៅនឹងសំណួរទេ ហ្នឹងទេ ពីព្រោះថាខ្ញុំជាពលរដ្ឋស៊ីវិលខ្ញុំអត់អាចឆ្លើយចំពោះបញ្ហានយោបាយបានទេ ខ្ញុំអត់ដឹងទេ។ ពាក់ព័ន្ធនឹងបញ្ហានយោបាយ ខ្ញុំអត់ដឹងទេ ខ្ញុំគ្រាន់តែផ្អែកទៅលើអត្ថបទដែលមានសរសេរស្រាប់តែប៉ុណ្ណោះ។

**ស៖** សូមអរគុណ។ បើសិនជាលោកប្រធានមិនយល់ទាស់ខ្ញុំស្នើសុំក្នុងឋានៈជាភាគី សុំឯកសារសំបុត្ររបស់ឪពុកលោកស្រីផ្ញើទៅជូនហ្នឹង ដើម្បីជាប្រវត្តិសាស្ត្រ។ អាហ្នឹងបើសិនជាខាងតុលាការមិនយល់ទាស់ទេ។

[១០:៤១:២០]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៤២:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណហើយលើសំណើនេះ អង្គជំនុំជម្រះសូមបញ្ជាក់លើពីរចំណុច។ ទី១គឺលោកស្រីដើមបណ្តឹងរដ្ឋប្បវេណីប្រសិនបើអាចផ្តល់នូវឯកសារថតចម្លងតាមសំណើសុំរបស់លោកមេធាវីជាតិការពារក្តីលោក នួន ជា មកដល់អង្គជំនុំ ជម្រះសាលាដំបូងនូវឯកសារដែលគាត់ស្នើសុំអម្បាញ់មិញនេះក៏ជាការល្អដែរ ទី១។ បញ្ហាទី២ ពាក់ព័ន្ធនឹងឯកសារ ហើយនិងសំណួរទាំងឡាយដែលពាក់ព័ន្ធនឹងឯកសារនេះមិនពាក់ព័ន្ធទៅនឹងយុត្តាធិការពេលវេលានៃកិច្ចដំណើរការសវនាការដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការនេះទេ។ ពីព្រោះយុត្តាធិការរបស់អ.វ.ត.ក នេះ កំណត់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

[១០:៤៣:៤៩]

**សួរដោយលោក សុន អរុណ៖**

ខ្ញុំមានសំណួរមួយទៀត។ សំណួរមួយនេះខ្ញុំនៅក្នុងការស្តាប់ចម្លើយអ្នកស្រីបានជម្រាបតុលាការមុននេះបន្តិច អ្នកស្រីបានជម្រាបថា នៅឆ្នាំ -- នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ពេលនោះខ្មែរក្រហមបាន

ដេញអ្នកស្រី និងគ្រួសារចេញពីផ្ទះ។ មានទាហានសម្លៀកបំពាក់ផ្សេងៗមកប្រាប់ថាឲ្យចេញពីផ្ទះ។ ហើយក្រោយមកទៀតអ្នកស្រីអំមិញបានមានប្រសាសន៍អ៊ីចឹងថា ក្រោយមកទៀតមានទាហានៗមួយប៉ែក មួយក្រុមផ្សេងទៀតដែលមានសម្លៀកបំពាក់ផ្សេង បានមកប្រាប់ថា ឲ្យចេញពីផ្ទះហើយធ្វើមុខមាំ ហើយតែ៣ថ្ងៃគេនឹងឲ្យចូលវិញ។ ខ្ញុំសួរ ខ្ញុំរំឭកហ្នឹង សម្ដីខ្ញុំនិយាយទាំងប៉ុន្មានខុសឬត្រូវ? បើមិនត្រូវ សូមលោកស្រីកែ។

**លោកស្រី ធុច ផាន់ដារ៉ា-សះ**

**ឆ៖** លោកមេធាវី លោកច្រឡំហើយ ខ្ញុំនិយាយថាគឺក្រុមខ្មែរក្រហមអ្នកមក គឺថាមិនមែនទាហានក្រុមផ្សេងទេ គឺជាទាហានខ្មែរក្រហមតែម្ដង។ ហើយខ្ញុំដឹងហ្នឹងដោយសារតែឯកសណ្ឋានខ្មៅហ្នឹងហើយ ហើយនិងមានកាន់កាំភ្លើង។ អត់មានក្រុមផ្សេងណាទេ គឺមានតែក្រុមទាហានខ្មែរក្រហមតែមួយទេ។

**លោក សុន អរុណ៖**

ខ្ញុំអរគុណ។ ខ្ញុំមានតែសំណួរតែពីរទេ។ ខ្ញុំស្ដាប់ច្រឡំអម្បាញ់។ បើសិនជាថា ខ្ញុំស្ដាប់ទៅវាចម្លើយរបស់អ្នកស្រីអ៊ីចឹង ខ្ញុំនឹងមានសំណួរត។ ប៉ុន្តែឥឡូវខ្ញុំអស់សំណួរហើយ សហភាគារបស់ខ្ញុំនឹងសួរអ្នកស្រីបន្ត។ សូមអរគុណលោកប្រធាន។

[១០:៤៦:០២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរខ្លីៗពីរបីទេ ទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រីបាននិយាយថា បងប្អូនជីដូនមួយមួយដែលលោកនិយាយថាឧត្តមសេនី ថាច់ សារី អ្នកណា? ជីដូនមួយស្រីដែលប្រាប់ហ្នឹង ឈ្មោះអីដែរ?

**លោកស្រី ធុច ផាន់ដារ៉ា-សះ**

**ឆ៖** សូមអភ័យទោស លោកមេធាវី គាត់ជាបងប្អូនជីដូនមួយស្រីរបស់ខ្ញុំ។ គាត់ជាយោធាដែរ ហើយគាត់ធ្វើការឲ្យលោក ថាច់ សារី ហ្នឹង។ គាត់ស្ដាប់ បងប្អូនជីដូនមួយស្រីហ្នឹង គាត់ទើបតែស្ដាប់

រយៈពេល២ឆ្នាំហ្នឹងទេ។ កាលហ្នឹងគាត់នៅ គាត់ក៏នៅបារាំង គឺថាគាត់ស្លាប់នៅស្រុកបារាំង២ឆ្នាំមុននេះឯង។

[១០:៤៧:១០]

**ស៖** តើគាត់មានឈ្មោះអ្វីដែរ?

**ឆ៖** គាត់ឈ្មោះ យួង -- យួន១។

**ស៖** តើលោកស្រីចាំទេថា នៅពេលណាដែលគាត់បានប្រាប់រឿងហ្នឹងមកឲ្យលោកស្រីហ្នឹងនៅពេលណា?

**ឆ៖** គាត់ប្រាប់ហ្នឹងគឺថា យើងនៅភ្នំដើងទិញមកហើយទេ ដែលខ្ញុំដឹងនោះ។ ពេលហ្នឹងគឺថានៅក្នុងព្រៃ។

**ស៖** លោកស្រីអាចជម្រាបបានទេ នៅពេលណាពិតប្រាកដនោះ?

**ឆ៖** នៅពេលដែលយើងនៅជុំគ្នាហ្នឹង គឺគ្រួសារយើងប្រាំមួយគ្រួសារហ្នឹងនៅជុំគ្នានៅភ្នំដើងទិញហ្នឹងឯង។

**ស៖** តើលោកស្រីអាចជម្រាបបានទេ នៅខែណា? ឆ្នាំណាដែរ?

**ឆ៖** បើតាមខ្ញុំចាំហ្នឹងគឺខែសីហា ដែលជារដូវមូសុងហ្នឹង គឺថាកូនក្មេងហ្នឹងគឺថាឈឺពិបាកខ្លាំងគឺថាពេលហ្នឹងគឺខែវស្សា គឺថានៅដើមខែសីហា បើតាមខ្ញុំចាំនោះ។

[១០:៤៨:៥៤]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកស្រី។ ខ្ញុំអស់សំណួរហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសសួរដេញចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

សូមអញ្ជើញ!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការទាំងមូល។ ក្នុងនាមលោក ខៀវ សំផន និងសហការីរបស់ខ្ញុំលោកមេធាវី អាកទួរ វ៉ែកគែន ពុំមានសំណួរសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនេះ

ទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអរគុណលោកស្រី ធុច ផាន់ដារា ការស្តាប់សក្ខីកម្មរបស់លោកស្រីអំពីទុក្ខសោកវេទនា ស្ថានភាពព្យសនកម្ម និងសក្ខីកម្មរបស់លោកស្រីរហូតដល់ពេលនេះបានចប់ហើយ។ វត្តមានរបស់លោកស្រីនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ សក្ខីកម្មរបស់លោកស្រីដែលរៀបរាប់អំពីសេចក្តីទុក្ខសោកវេទនា ពីស្ថានភាពព្យសនកម្មទាំងឡាយ និងសក្ខីកម្មរបស់លោកស្រីនឹងអាចរួមវិភាគទានក្នុងការស្វែងការពិតនៃរឿងក្តីនេះ។ ហើយលោកស្រីអាចវិលត្រឡប់ទៅវិញបានហើយ ហើយសូមលោកស្រីមានសុខភាពល្អ ជួបតែសំណាងល្អ និងបានសេចក្តីសុខ សេចក្តីចម្រើន។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកស្រី ធុច ផាន់ដារា វិលត្រឡប់ទៅទីកន្លែងដែលគោលដៅដែលគាត់មានបំណងចង់ទៅឬក៏ទៅកាន់លំនៅរបស់គាត់បានហើយ។

ហើយអង្គជំនុំជម្រះសូមជម្រាបជូនថា ជាបន្តនេះ អង្គជំនុំជម្រះនឹងស្តាប់នូវសេចក្តីថ្លែងទុក្ខសោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀតដែលមានរហស្សនាម TCCP-7។ ហើយឥឡូវនេះដល់ពេលសម្រាកហើយ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាក១៥នាទី គឺចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោយឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៥១ នាទី ដល់ម៉ោង១១:០៨ នាទី)*

[១១:០៨:០៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី TCCP-7 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលមកកាន់បន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី តើលោកស្រីឈ្មោះអី?

**លោកស្រី ចាន់ សុជាតិ៖**

**ឆ៖** ចាស នាងខ្ញុំឈ្មោះ ចាន់ សុជាតិ។

**ស៖** បាទ អរគុណលោកស្រី ចាន់ សុជាតិ។ តើលោកស្រីមានអាយុប៉ុន្មាន?

**ឆ៖** សព្វថ្ងៃនេះ ខ្ញុំមានអាយុ ៥៦ឆ្នាំហើយ។

**ស៖** បាទ អរគុណ។ ហើយលោកស្រី សុជាតិ ពេលដែលលោកស្រីឆ្លើយតបទៅនឹងសំណួរទាំងឡាយរបស់អង្គជំនុំជម្រះ ឬក៏ភាគីពាក់ព័ន្ធនេះ សូមលោកស្រីបង្អង់បន្តិច រង់ចាំរហូតដល់ក្បាលមីក្រូហ្វូនហ្នឹងឲ្យភ្លើងសញ្ញាក្រហមដែលនៅទីនេះ ឬក៏នៅខាងប៊ូតុងដែលសម្រាប់ចុចនេះ នេះបញ្ជាក់ថាក្បាលមីក្រូហ្វូននៅចំពោះមុខលោកស្រីហ្នឹងចាប់ផ្តើមប្រតិបត្តិការហើយ អ៊ីចឹងសំឡេងរបស់លោកស្រីនឹងចូលទៅប្រព័ន្ធហ្នឹង។ ហើយដើម្បីពន្យារពេលបន្តិច ដើម្បីមូលហេតុគឺទុកឲ្យលទ្ធភាពអ្នកបកប្រែភាសាហ្នឹងបានបកប្រែភាសាហ្នឹងបានត្រឹមត្រូវ ហើយបានពេញលេញ។

លោកស្រីមានទីកន្លែងកំណើតនៅទីកន្លែងណា?

**ឆ៖** ចាស នាងខ្ញុំមានទីកន្លែងកំណើតនៅសង្កាត់លេខ៥ ក្រុងភ្នំពេញ។

**ស៖** បាទ អរគុណ។ ចុះទីលំនៅសព្វថ្ងៃៗនេះ តើលោកស្រីរស់នៅទីកន្លែងណា?

**ឆ៖** ទីលំនៅសព្វថ្ងៃរបស់នាងខ្ញុំរស់នៅភូមិចំការចេកខាងត្បូង សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។

[១១:១០:៥៩]

**ស៖** អរគុណ។ តើលោកស្រីប្រកបមុខរបររកស៊ីធ្វើអ្វី?

**ឆ៖** ចាស រាល់ថ្ងៃនេះខ្ញុំគឺជាកសិករ ហើយក៏ជាបម្រើការងារនៅក្នុងសង្កាត់។

**ស៖** បាទ អរគុណ។ តើលោកស្រីអាចប្រាប់ដល់អង្គសវនាការបានដែរទេ អំពីឈ្មោះបង្កើតរបស់ -- ឈ្មោះរបស់ឪពុករបស់លោកស្រី ឪពុកបង្កើតរបស់លោកស្រី ហើយនិងម្តាយបង្កើតរបស់លោកស្រី?

**ឆ៖** ចាស ឪពុកនាងខ្ញុំឈ្មោះ ចាន់ ស៊ីន និងម្តាយនាងខ្ញុំឈ្មោះ អ៊ុយ យ៉ែម។

**ស៖** បាទ អរគុណ។ ចុះប្តីរបស់លោកស្រីគាត់ឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ប្តីខ្ញុំ ប្តីនាងខ្ញុំឈ្មោះ ឌៀ យ៉ន ហើយសព្វថ្ងៃខ្ញុំមានកូនប្រាំនាក់។

[១១:១២:០៦]

**ស៖** លោកស្រី សុជាតិ ក្នុងនាមលោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការនេះ អង្គជំនុំជម្រះផ្តល់ឱកាសជូនទៅលោកស្រីដើម្បីអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការអំពីស្ថានភាពទុក្ខសោកវេទនា ស្ថានភាពព្យសនកម្ម ឬក៏ផលប៉ះពាល់ដែលបានកើតមានចំពោះលោកស្រីជាអាទិ៍ដូចជាការខូចខាតខាងផ្នែកផ្លូវចិត្ត ខាងរូបកាយ ឬក៏សម្ភារៈ ជាព្យសនកម្ម ឬក៏ផលប៉ះពាល់ផ្ទាល់ខ្លួនដែលជាបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋដែលបានកើតមានពិតប្រាកដរហូតដល់សព្វថ្ងៃនេះ ដែលនាំឲ្យលោកស្រីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីនេះ ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ចំពោះជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន។ ហើយដែលបានប៉ះពាល់ចំពោះលោកស្រីនៅក្នុងរបប ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ គឺគិតចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ៦ ខែមករា ឆ្នាំ១៩៧៩។ នេះជាសិទ្ធិរបស់លោកស្រី។

មេធាវី តើមេធាវីណាមួយទទួលសិទ្ធិនៅក្នុងរឿងក្តីនេះ ហើយសូមលោកបង្ហាញនូវសរុបតែម្តងបានន័យថាលើកតែលើកនេះអាចនិយាយរួមក្នុងពេញមួយថ្ងៃនេះតែម្តងទៅ ក្នុងការផ្ទេរសិទ្ធិជូនទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនោះ។

[១១:១៣:២៦]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន សម្រាប់ថ្ងៃនេះ ដើមបណ្តឹងរដ្ឋប្បវេណីដែលនៅសល់គឺ TCCP លេខ 7 គឺលោកស្រីដែលមានវត្តមាននៅទីនេះ គឺលោកស្រីមេធាវី គ្រីស្ទីន ម៉ាទីណូ ដែលនឹងលើកសំណួរសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់។ ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណី TCCP លេខ 13 ដែលនឹងធ្វើសក្ខីកម្មតាមរយៈវីដេអូលីង គឺលោកមេធាវី ប៉ាស្កាល់ អូប៊ែង នឹងលើកជាសំណួរក្នុងនាមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ហើយដើមបណ្តឹងរដ្ឋប្បវេណី TCCP-198 ដែលជាដើមបណ្តឹងរដ្ឋប្បវេណីចុងក្រោយសម្រាប់ថ្ងៃនេះនឹងត្រូវលើកសំណួរពីខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដោយលោកស្រីមេធាវី ទី ស្រីនណា។ សូមលោប្រធានជ្រាបបាទ។

ជាដំបូងសូមលោកប្រធានអនុញ្ញាតឲ្យលោកស្រី គ្រីស្ទីន ម៉ាទីណូ គាត់ចាប់ផ្តើមលើកពីឯកសារ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! សូមអញ្ជើញលោកស្រីមេធាវី!

[១១:១៤:៣៣]

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព! ជម្រាបសួរភាគីទាំងអស់ជាទីគោរព! មុននឹងអ្នកស្រី ចាន់ សុជាតិ និយាយ ខ្ញុំសូមផ្តល់ជូននូវភាគីនូវយោងនៃឯកសារទាំងពីរនេះ ដែលជាកំណត់ហេតុស្តាប់ចម្លើយរបស់គាត់។ ឯកសារទី១ គឺមានលេខកូដ D22/3258/1 -- 3858/1 ឯកសារទី២ គឺឯកសារដែលមានលេខកូដ D22/358.1។ ខ្ញុំ -- លេខ ERN ជាភាសាអង់គ្លេស និងភាសាខ្មែរ អត់មានជាភាសាបារាំងទេ។ ឯកសារទី១ អត់មានជាភាសាបារាំងទេ ERN ជាភាសាខ្មែរ គឺ 00584794 រហូតដល់98។ មានតែបីទំព័រទេ អ៊ីចឹងខ្ញុំគិតថា បើយើងនិយាយពីទំព័រតែម្តងស្រួលជាង។ ឯកសារទី១ គឺ D22/358 -- 3858.1 ERN គឺ 00571178 ដល់ 93, អង់គ្លេសគឺ 00571175 ទៅដល់ 77។

អ្នកស្រី ចាន់ សុជាតិ បានផ្តល់សក្ខីកម្មនៅ ខែឧសភា ឆ្នាំ២០១០ ហើយនិងបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាទទួលស្គាល់ ដែលចុះថ្ងៃទី១០ កញ្ញា ឆ្នាំ២០១០។

[១១:១៦:៥៥]

ខ្ញុំសូមផ្តល់វេទិកាទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានឆ្លងកាត់របស់ខ្មែរក្រហមទាំងស្រុងតែម្តង កាលណោះគាត់មានអាយុ១៨ឆ្នាំ នៅឆ្នាំ៧៥ ហើយគាត់បានឆ្លងកាត់សោកនាដកម្មទាំងអស់នេះ ហើយគាត់នឹងរៀបរាប់សោកនាដកម្មនេះជូនតុលាការ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ! អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅលោកស្រី ចាន់ សុជាតិ!

**លោកស្រី ចាន់ សុជាតិ៖**

ចាស សូមគោរពលោកតុលាការ! សូមគោរពលោកសហមេធាវីជាតិ អន្តរជាតិ។ នាងខ្ញុំសូម

ជម្រាបជូនថា ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្ញុំនិងប្រជាជនក្រុងភ្នំពេញត្រូវបានខ្មែរក្រហមជម្លៀសចេញដោយភ្លាមៗពីក្រុងភ្នំពេញ។ ពេលនោះខ្ញុំមានបងប្អូនបង្កើត១៣នាក់ រួមឪពុកម្ដាយ ១៥នាក់ ហើយគ្រួសារខ្ញុំមានប្អូនតូចៗច្រើន។ ការជម្លៀសចេញមានការលំបាក សង្គ្រាមបានបញ្ចប់ ខ្ញុំគិតថា សន្តិភាពនឹងកើតមាន។ ប៉ុន្តែផ្ទុយទៅវិញម៉ោងប្រហែលជាប្រាំបួនព្រឹក យោធាខ្មែរក្រហមបានស្ពាយកាំភ្លើងចូលទៅដល់ផ្ទះនាងខ្ញុំ ហើយបានប្រាប់ឲ្យគ្រួសារខ្ញុំចាកចេញពីផ្ទះរយៈពេល៣ថ្ងៃ ដោយសារគេចង់បោសសម្អាតខ្មាំង។ ពេលនោះឪពុកម្ដាយក្រុមគ្រួសារខ្ញុំបានរៀបចំដាំបាយទឹកហូប បាយមិនទាន់បានហូបផងស្រាប់តែមានយោធាម្នាក់ទៀត ស្ពាយកាំភ្លើងមកហើយដេញថា "ប្រញាប់ឡើងចេញឲ្យរហ័សព្រោះអាមេរិកាំងនឹងមកទម្លាក់គ្រាប់បែក"។

[១១:១៩:០៦]

ពួភាសានេះ គ្រួសារខ្ញុំមានការភ័យខ្លាចណាស់ ក៏យកអីវ៉ាន់ចេញមកមានតែកង់មួយ ម៉ូតូមួយដឹកអីវ៉ាន់បានបន្តិចបន្តួច បាយដែលដាំហើយមិនទាន់បានហូបរួមទាំងបំពង់ទឹកក្ដៅ ទឹកដោះគោសម្រាប់ប្អូនតូចៗ ពីព្រោះខ្ញុំ ក្រុមគ្រួសារខ្ញុំមានក្រុមគ្រួសារកូនតូចៗច្រើន បោរហូតទៅបួននាក់។ មកដល់តាមផ្លូវស្ថានភាពកាន់តែតានតឹង។ ខ្ញុំឡើងដើរផ្លូវមុនីវង្ស ខ្ញុំឃើញស្ថានភាព ខ្ញុំតក់ស្លុតណាស់ ដោយសារឃើញមនុស្សច្រើន។ ខ្លះរុញរទេះមានអ្នកឈឺព្យួរសេរ៉ូមនៅដៃ ខ្លះដេកស្លាប់តាមផ្លូវ ខ្លះស្រែកយំហៅរកកូនចៅបែកគ្នា ចំណែកគ្រួសារខ្ញុំប្រមូលកូនប្រមូលចៅដើរឆ្លងដល់ស្ពានមុនីវង្សគ្រួសារបានស្នាក់នៅវត្តនិរោធរយៈ៣ថ្ងៃ។ ដោយសារគ្រួសារខ្ញុំមានស្ថានភាពកូនតូចច្រើន រង់ចាំការវិលត្រឡប់ចូលភ្នំពេញវិញ ប៉ុន្តែពាក្យសម្ដី ដែលគេនិយាយគឺជាពាក្យបោកប្រាស់កុហក គេមិនឲ្យយើងវិលត្រឡប់ចូលភ្នំពេញវិញ។ ហើយគេបន្តដំណើរដេញយើងឲ្យយើងធ្វើដំណើរទៅមុខទៀត។ គ្រួសារខ្ញុំបានមកស្នាក់នៅស្រុកកៀនស្វាយ។

[១១:២០:៤៦]

ក្នុងរយៈពេល៦ខែនេះ សម្រាប់គ្រួសារខ្ញុំផ្ទាល់ នាងខ្ញុំផ្ទាល់មានទុក្ខវេទនាខ្លាំងណាស់។ ទី១ ដោយសារការអត់ មានអាហារហូបចុកគ្រប់គ្រាន់ ដោយយើងមិនបានត្រៀមលក្ខណៈស្បៀង។ ទី២ ការចែកអាហារឲ្យហូបចុកគឺមានតែអង្ករនិងពោត គ្មានត្រីសាច់អ្វីទេ ធ្វើឲ្យក្រុមគ្រួសារខ្ញុំដែលមានកូនតូចៗស្គមរីងរៃ ហើយប្អូនស្រីមួយដែលបៅទឹកដោះគោអត់ទឹកដោះ ហូបទឹកបបរលាយស្ករឡែមៗក៏បានរាករូស ដាក់ថ្នាំអត់គ្រូវហើយក៏បានស្លាប់។ គ្រួសារខ្ញុំអត់មានទ្រព្យរបស់អីមកទេ មានតែលុយ

កាក់បន្តិចបន្តួច ទីផ្សារសេរីក៏គេអត់លក់ លុយក៏គេឈប់ចាយ។ វាជាទម្ងន់មួយសម្រាប់ខ្ញុំ និងឪពុកខ្ញុំ។ ៦ខែក្រោយមក ប្រធានអង្គការនៅទូនេះគេបានប្រកាសឲ្យអ្នកដែលចេញពីភ្នំពេញត្រូវចូលទៅនៅភ្នំពេញវិញ។

[១១:២២:០២]

ឪពុកខ្ញុំគាត់ត្រេកអរណាស់ព្រោះគាត់គិតថា គាត់គឺជាវិស្វករម្នាក់ អ៊ីចឹងនៅពេលដែលប្រទេសចប់សង្គ្រាម គេត្រូវការអ្នកចេះដឹងដើម្បីយកទៅរៀបចំ ទោះបីអ្នកនៅទីនោះគេខ្សឹបប្រាប់ថា គេ -- យើងចាញ់បោកគេ ទោះគេបោកប្រាសយ៉ាងណាក៏គាត់នៅតែមានគំនិតមួយថាគាត់នឹងត្រូវតែចេញទៅភ្នំពេញដោយស្ថានភាព ការរស់នៅរបស់ខ្ញុំ ក្រុមគ្រួសារប្អូនៗខ្ញុំវេទនាណាស់។ ការចូលមកភ្នំពេញវិញវាអាចកែប្រែនូវស្ថានភាពយ៉ាប់យ៉ឺននេះឲ្យបានដូចសាដើមវិញ។

ថ្ងៃឡើងកប៉ាល់ម៉ោងប្រាំល្ងាច មនុស្សជិះកប៉ាល់ណែន រាប់រយគ្រួសារណែនណាន់តាន់តាប់ កប៉ាល់ចេញមកដល់មុខវាំង អ្នកក្នុងកប៉ាល់ទាំងខ្ញុំរួបនាងខ្ញុំផ្ទាល់បែរ មុខទៅលិចឃើញភ្លើងភ្លឺមុខបរមរាជវាំងត្រេកអររំភើបចិត្តដោយដឹងថាខ្លួនបានមកដល់ភ្នំពេញហើយ។ មនុស្សអរពេញកប៉ាល់ មានបុរសម្នាក់អាយុប្រហែលជា៣០ឆ្នាំគាត់ស្រែកថា “ជយោ! យើងដល់ភ្នំពេញហើយ”។ ពេលនោះបុរសម្នាក់នោះត្រូវខ្មែរក្រហមហៅចេញមកក្រៅ មួយសន្ទុះក្រោយមកឮសូរសម្លេងបាញ់ផាំងៗ ពីរគ្រាប់ប្រូង បុរសនោះធ្លាក់ទៅក្នុងទឹក ឃើញសភាពការណ៍បែបនេះមនុស្សនៅក្នុង កប៉ាល់ស្ងាត់ឈឹងសូម្បីតែកូនក្មេងក៏អត់ហ៊ានយំដែរ។

[១១:២៤:០១]

ភ្លឺឡើងស្រាងៗ កប៉ាល់បានឡើងមកដល់កំពង់ឆ្នាំង គេបានឲ្យយើងយកអីវ៉ាន់ចេញ ហើយគេចែកអង្ករឲ្យយើងហូបម្នាក់បីកំប៉ុង ម្នាក់មួយកំប៉ុងបីនាក់រង់ចាំឡានដឹកចេញ។ យើងឡើងឡានចេញពីកំពង់ឆ្នាំងមកចុះនៅក្នុងខេត្តពោធិ៍សាត់នៅផ្លូវរថភ្លើងបំបែកលាជ។ បន្តឡើងរថភ្លើងពីផ្លូវបំបែកលាជទៅចុះនៅភូមិអូរក្រៀត ស្ថិតនៅស្រុកមោងឫស្សី។ ពេលនោះស្ថានភាពគ្រួសារខ្ញុំក៏ដូចជាអ្នកដទៃពិសេសគ្រួសារខ្ញុំតែម្តងដែលមានកូនតូចច្រើនដើរអត់រួច គេឲ្យធ្វើដំណើរដោយថ្មើរជើងចេញពីអូរក្រៀតទៅរស់នៅក្នុងព្រៃនៅភូមិព្រៃទទឹង ផ្តែខាំប្រើស។ ស្ថានភាពមិនគួរឲ្យរស់នៅ មើលទៅឃើញសុទ្ធតែព្រៃមិនមានផ្ទះសម្បែងអ្វីទាំងអស់។ នៅខាងត្បូងផ្លូវមានតែចង្រុកស្រូវចាស់មួយ និងផ្ទះឃោធាសហករណ៍គេបីផ្ទះ។

កាលមកដល់ទីនោះ គេឲ្យយើងកាប់ឆ្ការព្រៃធ្វើរោងធ្វើផ្ទះនៅដោយខ្លួនឯង។ ហើយគេបានប្រជុំថា ការមករស់នៅទីនេះ គឺការរស់នៅតាមរបៀបជាសមូហភាព ការហូបរួម និងធ្វើការរួម។ ខ្ញុំនិងបងស្រី គេបានឲ្យទៅនៅកងយុវនារីអន្លង់គោក។ បងប្រុសស្រីកុមារអាចធ្វើការបាន គេឲ្យយកទៅនៅមន្ទីរកុមារ។ ចំណែកតូចៗធ្វើការអត់កើត គេឲ្យរស់នៅជាមួយឪពុកម្ដាយនៅផ្ទះ។

[១១:២៥:៥០]

ឪពុកខ្ញុំកាប់ឆ្ការ គេឲ្យអ្នកដែលនៅផ្ទះកាប់ឆ្ការព្រៃឫស្សីរាស់ ដាំបន្លែងដូចជាល្ពៅ ត្រឡាច។ ខ្ញុំកងយុវនារី ខ្ញុំទៅធ្វើការនៅអន្លង់គោក គេឲ្យខ្ញុំលើកភ្លឺស្រែ លើកប្រឡាយ គេវាស់ដីឲ្យ៥គូបក្នុង១ថ្ងៃ។ ហើយដោយឲ្យបបរហូបតែមួយវែកសុទ្ធតែទឹក។ ពេលនោះ ខ្ញុំវេទនាណាស់ ហូបអត់ឆ្អែត ធ្វើការខ្លាំងក្លា។ ខ្ញុំបានឈឺជាទម្ងន់។ ឪពុកខ្ញុំបានសុំគេយកខ្ញុំមកផ្ទះ។ មកដល់ផ្ទះស្ថានភាពរឹតតែយ៉ាប់យឺនថែមទៀត តែប្អូនតូចៗខ្ញុំស្គមស្គាំង ខ្លះហើម ដោយការហូបចុកនៅទីនោះពិបាកជាងខ្ញុំនៅឯណោះទៅទៀត។ ខ្ញុំនៅទីនោះ ហូបបបរមួយវែកសុទ្ធតែទឹក ប៉ុន្តែមានជាតិអង្ករ ចំណែកប្អូនម៉ែឪ ប្អូនខ្ញុំនៅឯក្រោយហូបបបរកន្ទក់សុទ្ធតែខ្ទួតឲ្យខ្មៅលាយនឹងត្រកួន។

[១១:២៧:១៤]

ទោះយកមកច្នៃធ្វើឲ្យស្ងួតក៏ធ្វើម៉េចក៏ហូបអត់កើតដែរ។ ហើយយើងមិនអាចមានលទ្ធភាពទៅរយកអ្វីហូបបានទេ។ ព្រោះកន្លែងនោះ គឺជាព្រៃ ហើយបើយើងទៅរកអីគេចាប់បាន គេថាយើងជាខ្មាំង។ បងប្អូនខ្ញុំហូបបាយអត់ឆ្អែក យប់ឡើងដេកអង្គុយត្រមោង ហើយគាត់និយាយថា ខ្ញុំខ្លោចចិត្តអាណិតប្អូនខ្ញុំណាស់។ គាត់ឃ្លានបាយណាស់ បើសិនជាបានបាយហូបជាមួយអំបិលមិនដឹងជាឆ្ងាញ់យ៉ាងណាទេ។ ឪពុកម្ដាយខ្ញុំ រួមរូបខ្ញុំអង្គុយសម្រក់ទឹកភ្នែក ដោយគ្មានលទ្ធភាពទៅរកបាយឲ្យកូននិងប្អូនហូប។ ភ្លឺឡើងប្អូនខ្ញុំស្លាប់អស់ពីរនាក់។ អត់ដឹងថាគាត់ដាច់ខ្យល់ស្លាប់ពីថ្មើរម៉ាន ហើយបន្តស្លាប់រហូតដល់អស់។ ប្អូនស្រីចុងក្រោយគេ ស្លាប់ពេលថ្ងៃម៉ោងបាយ ពេលដែលគេឲ្យបបរកន្ទក់មក ហូបអត់កើត។ ស្រែកសុំបាយមួយម៉ាត់មក ឲ្យបាយខ្ញុំហូបមួយម៉ាត់មក ស្រែករហូតដល់ដាច់ខ្យល់ស្លាប់។

[១១:២៨:៤៨]

នេះគឺជាសោគនាកម្មមួយដ៏ព្រៃផ្សៃនៃរបប ប៉ុល ពត ដែលខ្ញុំមិនអាចបំភ្លេចបាន។ ហើយគេយកក្រុមគ្រួសារខ្ញុំទៅអត់បាយ ឲ្យហូបដូចជាសត្វធាតុ។ កន្លះខែក្រោយមក ឪពុកខ្ញុំក៏ស្លាប់ទៀត។ ភ្លឺហើយខ្ញុំឃើញឪពុកខ្ញុំសម្រាន្តអត់ងើប ខ្ញុំទៅដាស់គាត់ គាត់ថាគាត់បើកភ្នែកមើលខ្ញុំ គាត់សួរខ្ញុំម៉ោងប៉ុន្មាន

ហើយ? ខ្ញុំថាម៉ោងជិតប្រាំពីរហើយ ខ្ញុំងើយមើលមេឃ។ គាត់បិទភ្នែកទៅវិញ គាត់ដាច់ខ្យល់ស្លាប់។ ឪពុកខ្ញុំគាត់ស្លាប់ដោយសារការឈឺចាប់របស់គាត់ដែលមិនអាចជួយកូនបាន។ ម្តាយខ្ញុំឈឺជាទម្ងន់ ពេលនោះខ្ញុំដាច់ចិត្តទៅស្នើសុំប្រធានសហករណ៍ឲ្យគេយកម្តាយខ្ញុំទៅមន្ទីរពេទ្យ។ ដោយគេមកឃើញជាក់ស្តែងពីជំងឺម្តាយខ្ញុំ ដែលគាត់ដេកអត់ដឹងខ្លួន គេក៏បានធ្វើសំបុត្រមួយឲ្យ ហើយឲ្យគាត់ទៅសម្រាកនៅមន្ទីរពេទ្យមោង។ ខ្ញុំទៅដល់នោះ ខ្ញុំអរណាស់ ដោយនៅមន្ទីរពេទ្យហ្នឹង គេបានចាប់ថ្នាំ ហើយពិសេសគឺគ្រាប់បាយដែលគេឲ្យយើងហូប បាយគេចំហុយឲ្យសក្បុស។ ខ្ញុំបានបាយ ខ្ញុំនឹកឃើញដល់បងប្អូនខ្ញុំស្លាប់ថា បើសិនជាបងប្អូនខ្ញុំដែលស្លាប់បានបាយហូប ប្រហែលជាបងប្អូនខ្ញុំមិនស្លាប់ទេ ពីព្រោះបងប្អូនខ្ញុំស្លាប់ដោយដាច់ពោះ មិនមែនស្លាប់ដោយជំងឺឡើយ។

ម្តាយខ្ញុំបានស្រួលគ្រាន់បើ គេបញ្ជូនមកវិញ ហើយគេឲ្យក៏ខ្ញុំទៅនៅ ដកសំណាបនៅអន្លង់កួប។ ទៅដល់ពេលនោះ ខ្ញុំជួបបងស្រីខ្ញុំ ខ្ញុំភើបចិត្តណាស់ ដូចខ្ញុំឃើញបងស្រីខ្ញុំឈឺស្គមហើម ដើរអត់រួច។ នៅទីនោះគេបង្ខំឲ្យធ្វើការ គេឲ្យដកសំណាបដូរបបរហូប អ្នកណាដែលដកបានមួយផ្លូន គេឲ្យបបរមួយវែករាវសុទ្ធតែទឹក។ ពីរផ្លូនពីរវែក បីផ្លូនបីវែក តែបងខ្ញុំ គាត់ដកមិនបានទេ ហើយសម្រាប់នាងខ្ញុំមិនអាចទ្រាំទ្របាន ដោយខ្ញុំស្គមដូចគាត់ដែរ។

[១១:៣១:២០]

ពេលដកអត់បាន បបរគេអត់ឲ្យហូប គេវ៉ៃ គេដាក់ផ្ទុកភ្លឺស្រែ។ ឃើញភាពវេទនានឹងភ្នែកយ៉ាងនេះ ខ្ញុំក៏សម្រេចចិត្តពីរនាក់បងប្អូនកុហកមេកងថា ផ្ទះខ្ញុំមានអាវចាក់ ព្រោះគេត្រូវការអាវហ្នឹងយកមករុះក្រងធ្វើខ្សែអង្រឹង។ ខ្ញុំគ្រាន់តែប្រាប់គេភ្លាម គេឲ្យខ្ញុំអង្ករខ្ញុំបីកំប៉ុង។ ព្រលឹមឡើងខ្ញុំឲ្យគេខ្ញុំចេញខ្ញុំបាននិយាយជាមួយបងស្រីខ្ញុំហើយ ថាគាត់ខ្លាចគេ ខ្ញុំចង់ឲ្យគាត់ចេញមុនខ្ញុំ នៅពេលដែលខ្ញុំទៅធ្វើការខ្ញុំត្រូវគេចតាមក្រោយ។ តែបងខ្ញុំ គាត់អត់ហ៊ានមក គាត់អេះអុញ ដោយសារគាត់ធ្លាប់ដើរកាត់ព្រៃ គាត់ធ្លាប់ជាន់មីនម្តងមកហើយ ធ្វើឲ្យគាត់មានការភ័យខ្លាច អត់ហ៊ានមក។ គេបានសម្លុតខ្ញុំថា មិត្តឯងផ្ញើរម៉ានទៅ ខ្ញុំក៏ទាញអង្ករ ហើយខ្ញុំដើរមក។ បានអង្ករបីកំប៉ុង ដើរមកដល់ក្នុងព្រៃពាក់កណ្តាលផ្លូវ ដើរងាកៗរង់ចាំមើលផ្លូវបង។ តែចាំបាត់ៗ អត់ឃើញបងខ្ញុំមកទេ។ យប់ឡើង ខ្ញុំឡើងដេកលើចុងដង្កោខ្លាចឆ្កែចចក។ ស្អែកឡើងចាំបងមួយថ្ងៃទៀត ខ្ញុំដេកនៅក្នុងព្រៃរយៈពេលមួយយប់ពីរថ្ងៃ ដើរចាំបងនៅតែអត់ឃើញ ក៏សម្រេចចិត្តចូលមកភូមិ។ មកដល់អត់ឃើញមានម្តាយនៅផ្ទះទេ ខ្ញុំបានអង្ករ ខ្ញុំដាំបាយហូប នៅសល់អង្ករប្រហែលមួយកំប៉ុង អស់ជម្រើស សម្រេចថាខ្ញុំនឹងសរសេរក្រដាសថ្លែងសំបុត្រ

ខ្ញុំចូលទៅដេកមន្ទីរពេទ្យ ពេលទៅដល់ឃើញម្ដាយខ្ញុំនៅទីនោះ ខ្ញុំស្លុតចិត្តណាស់ ដែលឃើញម្ដាយខ្ញុំហើមពោរ ដើរអត់រួច។ ខ្ញុំបានយកអង្ករដាំបាយឲ្យម្ដាយហូបជាលើកចុងក្រោយ។ ពីរបីថ្ងៃក្រោយមកមេកងគេក៏ទៅរកខ្ញុំ ខ្ញុំបានគេចចេញពីមន្ទីរពេទ្យ ហើយខ្ញុំមកនៅកៀនមន្ទីរពេទ្យៗ ដោយលាក់ខ្លួន។ ខ្ញុំអត់មានអីហូប ខ្ញុំហូបតែក្តិបល្ពៅ ក្តិបត្រឡាច ដល់ពេលខ្ញុំឃ្លានពេក ដើរលែងរួច ខ្ញុំដាច់ចិត្តចូលទៅក្នុងការដ្ឋាន ដើម្បីទៅលួចរបស់គេហូប។ តែពេលចូលទៅ អត់មានឃើញអីទាំងអស់។ ខ្ញុំឃើញឆ្អឹងប្រហុកគេដែលគេគោះចោលកៀនចង្ក្រាន ខ្ញុំកើបយកមកលាងទឹក ហាលថ្ងៃស្ងួត ខ្ញុំយកមកវេចខ្ចប់នឹងជាយសំពត់ ហើយដំអកហូប។

[១១:៣៤:២០]

ខ្ញុំគិតថា ខ្ញុំនឹងស្លាប់ ខ្ញុំក៏សម្រេចចិត្តក្លែងសំបុត្រទៀត ទៅនៅកងតាម៉ុក អូរវែង ប៉ុន្តែខ្ញុំមិនដែលស្គាល់មុខគាត់ទេ។ ខ្ញុំដើរពីហ្នឹងមកដល់អូរវែង ថ្ងៃត្រង់ ហួសពេលបាយគេហើយ។ មកដល់ការដ្ឋានហុចក្រដាសទៅ គេអត់ចាប់អារម្មណ៍ទេ គេគ្រាន់តែមើលហើយ គេស្រែកហៅកូនកងគេថា "មិត្តណាមកយកកូនកងខ្លួនឯង កូនកងខ្លួនឯងមកពីពេទ្យវិញហើយ"។ គេចេញមកបីបួននាក់ ហើយគេឈរមើលមកខ្ញុំ គេថា "គេអត់ស្គាល់ខ្ញុំទេ អត់ដឹងនៅឯណាទេ ហើយក៏គេអត់ទទួលស្គាល់ដែរ"។ ខ្ញុំអស់សង្ឃឹម ស្រាប់តែ តាម៉ុក គាត់ជិះកង់មកពីកើត មួរជើងខោ ពាក់មួកកន្ទិប ហើយគាត់សួរថា "មានការអីមិត្តអើយ?" មេកងអស់នោះគេឆ្លើយថា "មិត្តនេះមកពីពេទ្យ ហើយថានៅកងយើងអត់ដែលស្គាល់ទេ" តាម៉ុក គាត់ឆ្លើយថា "អង្គការតែមួយនៅត្រង់ណាក៏ដូចត្រង់ណាដែរ ឲ្យគេនៅទៅ" ហើយគាត់សួរខ្ញុំថា "ខ្ញុំហូបបាយហើយឬនៅ?" ខ្ញុំប្រាប់គាត់ថា "ខ្ញុំអត់ទាន់បានបាយហូបទេ"។ គាត់ឲ្យខ្ញុំទៅតាមគាត់ គាត់ចង្អុលឆ្នាំងបាយ ឆ្នាំងសម្លរឲ្យខ្ញុំហូប។ ខ្ញុំបើកបាយ ឃើញបាយពេញឆ្នាំង បើកសម្លឃើញសម្លម្ជូរសាច់គោពេញឆ្នាំង ខ្ញុំស្រក់ទឹកភ្នែកអាណិតម្ដាយបងប្អូនខ្ញុំដែលដាច់ពោះស្លាប់គ្មានអីហូប។ ហេតុអ្វីបានជាគេយកពួកខ្ញុំមកបង្អត់អាហារ ហើយពួកគេហូបឆ្ងាញ់។ បើតាមការអត់បាយ និងឃ្លាន ខ្ញុំត្រូវហូបអស់មួយឆ្នាំងហ្នឹង ប៉ុន្តែខ្ញុំហូបអត់បានទេដោយការអរ ទី១ ខ្ញុំអរថាខ្ញុំបានមករស់នៅ គេទទួលស្គាល់រស់ឡើងវិញ។ ខ្ញុំហូបបានមួយដុំផ្អែត ហើយខ្ញុំបន្តដំណើរធ្វើការជាមួយគេរហូតនៅកងនោះតាំងពីស្ទូងរហូតដល់ច្រូត នៅរដូវច្រូតកាត់ថ្ងៃមួយ ពេលបាយថ្ងៃត្រង់ខ្ញុំបានទៅដួសទឹកប្រឡាយស្រាប់តែឃើញប្អូនខ្ញុំដេកដួលនៅមាត់ប្រឡាយហើមមុខមើលអត់ស្គាល់សោះ ប្អូនខ្ញុំឈឺហើមនៅមណ្ឌលកុមារ គ្មានអ្នកណាមើលថែ ខ្ញុំបោកគក់ក្រណាត់កន្ទប ងូតទឹកឲ្យ ដួសទឹកហើយ ក្រៀរប្អូនទៅដាក់រោង ប្អូនខ្ញុំប្រាប់ថា

ប្អូនស្រីម្នាក់ទៀតដែលនៅជាមួយត្រូវបានស្លាប់ដោយសារទៅផ្ទះ ធ្លាក់ពីលើផ្ទះត្រូវផ្តែចបស្លាប់។

ខ្ញុំរន្ធត់ចិត្តណាស់។ ខ្ញុំបាត់បង់បងប្អូនម្តងមួយៗ។ ហើយដល់ម៉ោងខ្ញុំក៏មកច្រូតឲ្យគេវិញ ពេលឡើងពីច្រូត ខ្ញុំត្រូវទៅសាក្រណាត់យកទៅឲ្យប្អូនខ្ញុំនៅរោង ទៅដល់រោងបាត់ប្អូន ខ្ញុំសួរគេៗថាប្អូនខ្ញុំស្លាប់ ហើយគេបានយកទៅកប់ហើយ។ ជួបប្អូនថ្ងៃត្រង់ពេលល្ងាចស្លាប់ គេយកទៅកប់ ដោយមិនបានឃើញមុខ សួរថាចំពោះអស់លោក លោកស្រីតើមានអារម្មណ៍យ៉ាងណាដែលទិដ្ឋភាពគួរឲ្យខ្លោចផ្សានេះ? ខ្ញុំប្រឹងពង្រឹងស្មារតី ខំធ្វើការងារឲ្យគេ តែទឹកចិត្តគ្មានព្រលឹងនៅក្នុងខ្លួនទេ អស់ហើយក្តីសង្ឃឹមក្នុងជីវិតដោយសារការព្រាត់ប្រាស់នេះ។

[១១:៣៨:២៦]

បាន១ថ្ងៃ២ថ្ងៃ មានអ្នកមកពីតាមភូមិ គាត់ចាស់ៗដែលគេបញ្ជូនឲ្យគាត់មកច្រូតនៅកន្លែងខ្ញុំ គេបានប្រាប់ខ្ញុំថា "ម្តាយខ្ញុំឈឺធ្ងន់ណាស់" ព្រលឹមឡើងខ្ញុំក៏សុំគេ ថាមិត្តឲ្យខ្ញុំសុំសម្រាកមួយព្រឹកដើម្បីទៅមើលម្តាយខ្ញុំ ព្រោះគេប្រាប់ថាម្តាយខ្ញុំឈឺធ្ងន់។ គេឆ្លើយថា "មិត្តឯងពេទ្យ? មិត្តឯងទៅមើលម៉ែមិត្តឯងម៉ែមិត្តឯងជា?" គេអត់ឲ្យខ្ញុំទៅទេ ពេលនោះហើយដែលខ្ញុំអត់លែងឃើញមុខម្តាយចាប់ពីពេលនោះមក។ ហើយខ្ញុំត្រូវបំលាស់ទីជាច្រើនលើកច្រើនសាពីមួយកន្លែងទៅមួយកន្លែង។ ចូលដល់ឆ្នាំ៧៧ របបអាហារហូបចុក អ្នកដែលច្រូតនៅកងឈានមុខ ពួកខ្ញុំគេឲ្យខ្ញុំហូប ១០នាក់បាយ បីកំប៉ុងដាំឲ្យជ្រាយចាក់ដាក់ចានដែក សម្លរមួយចាន ចាក់ចូលគ្នាព្រោះក្រុមខ្ញុំ អត់មានចាន អត់មានឆ្នាំងទេ មានតែស្លាបព្រាមួយជាប់នឹងចង្កេះ ដួសហូបម្នាក់មួយម៉ាត់ៗ រហូតអស់នាំគ្នាដើរចេញ ផឹកទឹកប្រឡាយដើរចេញ។

ពេលនោះ អង្គការបានកំណត់ថា "ក្នុងមួយខែឲ្យយើងសម្រាកមួយថ្ងៃ ដើម្បីទៅលេងគ្រួសារ" ខ្ញុំទៅដល់ភូមិម៉ែខ្ញុំស្លាប់ ខ្ញុំទៅរកបងស្រីខ្ញុំស្លាប់ ខ្ញុំទៅរកបងស្រីខ្ញុំនៅដំណាក់រុន គេថាបងស្រីខ្ញុំស្លាប់យូរហើយ។ នេះជាលើកចុងក្រោយ អស់ក្រុមគ្រួសារឪពុកម្តាយ បងប្អូន ដែលខ្ញុំរស់នៅតែម្នាក់ឯងដោយភាពឯកោហើយធ្វើការយ៉ាងធ្ងន់ធ្ងររង់ចាំថ្ងៃស្លាប់។ គេដាក់ទណ្ឌកម្មឲ្យយើងលើកប្រឡាយក្នុងទឹក បើមិនគ្រប់ផែនការទេ គេថាយើងជាខ្មាំងយួន ចិន-យួនគេឃើញសម្បុរយើងស គេថាយើងជាពួកសក្តិភូមិ គេប្រមាថវ៉ៃក្បាលចោលនឹងត្បូងចប។ ខ្ញុំប្រឹងណាស់ធ្វើទាំងត្រដរដើម្បីយកបាយហូបកំដរពោះរស់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកស្រីមេធាវី!

[១១:៤១:២១]

E1/198.1

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

**ស៖** អ្នកស្រី សុជាតិ ខ្ញុំគិតថា ជាការលំបាកខ្លាំងណាស់ដែលរំឭករឿងរ៉ាវទាំងអស់នេះឡើងវិញ គឺថាអ្នកស្រីបាត់បង់គ្រួសារ១៥នាក់ ហើយឪពុកម្ដាយ -- ឪពុកក៏ស្លាប់ដែរនៅពេលដល់ពោធិ៍សាត់ ហើយបាត់ដំបងនោះ ហើយបន្ទាប់មកទៀតនោះ បងស្រីទាំងប៉ុន្មាន ហើយប្អូនប្រុស ហើយនិងបងស្រីម្នាក់ទៀតនោះ ថាគាត់ស្លាប់ដែរ។ អ៊ីចឹងការរំឭករឿងនេះឡើងវិញនេះ គឺថាជាការ -- ជាភាពគួរឲ្យរន្ធត់ណាស់។ អ៊ីចឹង គឺអ្នកស្រីមកទីនេះចង់និយាយប្រាប់តុលាការថា ហេតុអីបានជាអ្នកស្រីមកផ្ដល់សក្ខីកម្ម ហើយហេតុអីបានដាក់ពាក្យបណ្ដឹង។ អ៊ីចឹង គឺដាក់បណ្ដឹងដើម្បីប្រឆាំងនឹងមេដឹកនាំរបបខ្មែរក្រហមនេះ។

អ៊ីចឹងបើសិនជាអ្នកស្រីអាចធ្វើការបញ្ចប់ ឬសេចក្ដីសន្និដ្ឋានមួយ ដោយសារអ្នកស្រីពិបាកក្នុងការនិយាយ ព្រោះថា ខ្ញុំដឹងថា អ្នកស្រីចង់និយាយអំពីអាកប្បកិរិយាដែលមេដឹកនាំខ្មែរក្រហមនេះ ថ្នាក់ដឹកនាំខ្មែរក្រហមនេះគេបានប្រព្រឹត្តទៅលើលោកសម័យនោះ តើអ្នកស្រីចង់និយាយអ្វីខ្លះបន្ថែមទេ?

[១១:៤២:៥៧]

**លោកស្រី ចាន់ សុជាតិ៖**

**ឆ៖** ចាស សូមគោរពលោកតុលាការ សូមគោរពលោកស្រីសហមេធាវីជាតិ អន្តរជាតិជាទីគោរព។ នាងខ្ញុំមានសំណួរមួយចង់សួរចំពោះជនជាប់ចោទថា ខ្ញុំឆ្ងល់ណាស់ថា ហេតុអ្វីបានជារបប ៣ឆ្នាំ ៨ខែ ២០ថ្ងៃនេះមានភាពសាហាវ ឃោរឃៅម្ល៉េះ? ហើយគេធ្វើដើម្បីអ្វី? ដោយសារខ្ញុំមានការឈឺចាប់នេះហើយបានជាខ្ញុំដាក់ពាក្យបណ្ដឹង ហើយនិងដាក់តាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីសុំឲ្យតុលាការលោករកយុត្តិធម៌ជូនគ្រួសារនាងខ្ញុំ ក៏ដូចជាប្រជាជនទូទាំងប្រទេសដែលបានស្លាប់ទៅស្ទើរផុតពូជ ហើយអ្នកដែលបានរស់នៅមិនមានលទ្ធភាពក្នុងការដាក់ពាក្យបណ្ដឹងមកតុលាការ។ ពេលនេះ ខ្ញុំគឺជាសាក្សីម្នាក់ដែលមានរស់រានមានជីវិតពីរបបយង់ឃ្នងនេះ ហើយបានឃើញ និងឆ្លងកាត់នៅសោក-នាដកម្មជាហូរហែដូចប្រជាពលរដ្ឋដទៃទៀត។ ខ្ញុំសង្ឃឹមថា សក្ខីកម្មនៃជីវិតរបស់ខ្ញុំក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ នឹងអាចជួយជាជំនួយ និងជាប្រយោជន៍សម្រាប់តុលាការស្វែងរកការពិត។ ហើយ

នៅចុងបញ្ចប់នៃគោលដៅពេលនេះ នាងខ្ញុំសូមឲ្យជនជាប់ចោទ លោកសារភាព និងថ្លែងនៅទោសកំហុស សូមទោសចំពោះវិញ្ញាណក្ខន្ធប្រជាពលរដ្ឋទូទៅពិសេសក្រុមគ្រួសារនាងខ្ញុំផ្ទាល់ដែលស្លាប់ទាំង១៤នាក់ នៅសល់តែខ្ញុំម្នាក់ស្ទើរផុតពូជ ដើម្បីឲ្យគាត់បានស្ងប់ចិត្ត។

[១១:៤៤:៥៤]

**ស៖** អ្នកស្រីបាននិយាយអំពីកូនរបស់អ្នកស្រីដែលបានកើតក្រោយឆ្នាំ៨០ ដែលមិនបានស្គាល់របបខ្មែរក្រហមនេះទេ ហើយពួកគេទាំងអស់គ្នាចោទសំណួរទៅអ្នកស្រីជាច្រើនដង អ្នកស្រីបានប្រាប់ខ្ញុំហើយពួកគេសួរថាតើបងប្អូនទាំងអស់ហ្នឹងស្លាប់អស់ហើយម៉េចក៏ម៉ាក់នៅរស់? ហើយកាលនោះ អ្នកស្រីឆ្លើយថា អ្នកស្រីពិបាកណាស់ក្នុងការឆ្លើយទៅនឹងសំណួរនេះ។ អ៊ីចឹងឥឡូវខ្ញុំសូមឲ្យអ្នកស្រីផ្តល់ចម្លើយទៅតុលាការពីព្រោះខ្ញុំគិតថាវាសំខាន់ណាស់ក្នុងការដឹងថាតើអ្នកស្រីអាចរស់រានមានជីវិតនេះតាមរបៀបណា? ហើយភាពក្លាហានរបស់អ្នកស្រីនេះយ៉ាងម៉េចដែរនៅក្នុងរបប ៣ឆ្នាំ ៨ខែ ២០ថ្ងៃនេះ ហើយលោកស្រីបានពន្យល់ទៅកូនចៅរបស់លោកស្រីនេះយ៉ាងម៉េចដែរ?

**ឆ៖** ចាស សូមគោរពលោកតុលាការ។ សូមគោរពលោកស្រីសហមេធាវីអន្តរជាតិជាទីគោរព។ កូនខ្ញុំ--នាងខ្ញុំសូមឆ្លើយនូវសំណួររបស់លោកស្រីដូចជាសំណួរដែលកូនខ្ញុំបានឆ្ងល់ថា បើតាមការរៀបរាប់និងទុក្ខវេទនានេះមិនអាចរស់នៅបានទេបើយើងអត់បាយម្លឹងតើហេតុអីបានជាម៉ែនៅរស់។ ដូចជាខ្ញុំបានជម្រាបខាងដើមថា ជីវិតខ្ញុំខ្លោចផ្សាឈឺចាប់ណាស់។ ខ្ញុំបានរត់ពីមួយកន្លែងទៅមួយកន្លែង លួចគេហូបផង លួចគេក៏មិនបានហូប ដើរយកនេះយកនោះហូបតែក្តិបល្ពៅ ក្តិបត្រឡាចផ្លាស់ពីមួយកន្លែងទៅមួយកន្លែងប្រឹងត្រដររស់ដោយនឹកឃើញថា បើវាសនារស់កំដរចាំថ្ងៃស្លាប់ ប៉ុន្តែរស់នៅក្នុងការភ័យខ្លាចពីមួយថ្ងៃទៅមួយថ្ងៃដោយសារឃើញទិដ្ឋភាពជាក់ស្តែងនៅនឹងភ្នែក។ ពេលខ្លះកំពុងតែស្ទូង គេហៅថាអ្នកឯងត្រូវទៅជួយធ្វើការនៅការដ្ឋាន ដូចឧទាហរណ៍ស្ត្រីមួយដែលជានៅជាមួយកងខ្ញុំ គេថាឲ្យមីងឯងឡើងទៅជួយធ្វើការនៅការដ្ឋាន។ ស្ត្រីនោះលាងដៃដើរទៅតាមគេបាត់។ ល្ងាចឡើងពួកខ្ញុំឡើង ពីស្ទូងដើរកាត់ទួលនោះស្រាប់តែឃើញសាកសពគាត់ត្រូវបានគេកប់អត់ជិត ឃើញចេញសក់ ចេញដៃ មានដំបងគេកាប់ដើមក្រសាំងរើគាត់ធ្វើឲ្យខ្ញុំរឹតតែតក់ស្លុតថែមទៀត។ នេះហើយជា--បានជំរុញផ្លូវ ចិត្តឲ្យខ្ញុំកាន់តែប្រឹងឡើង ហើយខ្ញុំត្រូវធ្វើការឲ្យគេដោយគ្មានឈប់ឈរ។ ទោះឈឺក៏ខ្ញុំអត់ហ៊ានឈប់ដែរ ព្រោះខ្លាចគេថាខ្ញុំខ្មាំងសក្តិភូមិ។

[១១:៤៥:០០]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះអង្គជំនុំជម្រះផ្តល់ឱកាសទៅជនជាប់ចោទ ដើម្បីឆ្លើយតបទៅនឹងសំណួរ។ លោក ខៀវ សំផន តើលោកឆ្លើយតបនឹងសំណួរដែលសួរឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងដូចម្តេច? អង្គជំនុំជម្រះបញ្ជូនសំណួរនេះទៅលោកដើម្បីឆ្លើយតប ហើយទី១។ ហើយទី២ សំណូមពររបស់គាត់សុំឱ្យលោកជនជាប់ចោទ ទាំងអស់ហ្នឹងសំដែងនូវការសុំអភ័យទោសពីជនរងគ្រោះដែលបានរងគ្រោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យជាពិសេសគ្រួសាររបស់លោក។ នេះគឺជាបញ្ហាពីរខុសគ្នា។

**ប្រធានអង្គជំនុំ៖**

ឲ្យបើកក្បាលមីក្រូហ្វូនផង។

[១១:៤៨:៥៣]

**លោក ខៀវ សំផន៖**

សូមគោរពអង្គសវនាការទាំងមូល! សូមជម្រាបលោកស្រី ចាន់ សុជាតិ។ ខ្ញុំស្តាប់លោកស្រីមានប្រសាសន៍អំពីទុក្ខសោកវេទនារបស់លោកស្រីដែលលោកស្រីបានជួបប្រទះស្លាប់បាត់បង់ឪពុកម្តាយកូនជាទីស្រលាញ់។ ខ្ញុំរន្ធត់ចិត្តណាស់។ ខ្ញុំស្តាប់យ៉ាងនេះទៅ នឹកថាអ្នកដែលធ្វើបាបលោកស្រី និងសាច់ញាតិលោកស្រីយ៉ាងនេះ មិនមែនជាមនុស្សធម្មតាទេគឺជាស្តេចត្រាញ់គេហៅថា ស្តេចត្រាញ់សង្គ្រាមគ្មានធម៌មេត្តាដល់មនុស្សមិនគិតដល់អាយុជីវិតមនុស្ស មិនគិតដល់អ្នកធ្លាប់ធ្វើ ឬក៏មិនធ្វើ។ ទុកពេលវេលាឲ្យម្នាក់ៗមានពេលសម្របខ្លួន ខំពីមិនធ្លាប់ទៅធ្លាប់។ ការពិតវាត្រូវធ្វើយ៉ាងនេះ។ ប៉ុន្តែបើយើងបង្ខំពេលឈឺអីទៅបង្អត់បាយថាគ្នាធ្វើពុត អាហ្នឹងមនុស្សអ៊ីចឹងជាមនុស្ស ហៅថាស្តេចត្រាញ់ ឃោឃៅមនុស្សដែលឃោឃៅដល់កម្រិតហ្នឹង ខ្ញុំមិនរួមជាមួយទេ។ ហើយពិតមែនតែខ្ញុំមិនមែនជាអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យសម្រេចអំពីនយោបាយដែលនាំឲ្យអស់លោកស្រី សាច់ញាតិលោកស្រីជួបប្រទះនឹងទុក្ខសោកវេទនាក៏ដោយ ក៏ខ្ញុំសូមលើកដៃអភ័យទោស សូមទោសលោកស្រី សូមទោសបងប្អូនរួបរួមជាតិទាំងអស់។ ដូចខ្ញុំបានជម្រាបពីព្រឹកមិញដែលបានត្រូវរងគ្រោះដោយអំពើឃោឃៅព្រៃផ្សៃៗនេះ ខ្ញុំយល់ឃើញថាមិនមែនជាមនុស្សធម្មតាទេ ជាស្តេចត្រាញ់សង្គ្រាម ជាសក្តិភូមិ។ បាទ សូមអស់។

[១១:៥១:៣៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្ត អង្គជំនុំជម្រះផ្តល់ផ្ទេរសំណួរ និងសំណើសំណូមពររបស់ដើមបណ្តឹង

រដ្ឋប្បវេណីដែលបានលើកឡើងអម្បាញ់មិញនេះ ជូនទៅជនជាប់ចោទ នួន ជា ដើម្បីមានឱកាសឆ្លើយតបទៅនឹងសំណួរដែលបានសួរ ឬក៏និងសំណើដែលបានស្នើសុំចុងក្រោយរបស់គាត់។

**លោក នួន ជា៖**

សូមគោរពអង្គប្រជុំ សូមគោរពលោកប្រធាន។ ខ្ញុំ នួន ជា សូមបញ្ជាក់ដូចតទៅនេះ៖ ចំពោះសំណួររបស់អ្នកស្រី សុជាតិ។ ខ្ញុំសូមបញ្ជាក់ហើយបញ្ជាក់ទៀត ដូចខ្ញុំបានបញ្ជាក់ជម្រាបហើយ គឺថាកម្ពុជាប្រជាធិបតេយ្យ មិនមានមាគ៌ានយោបាយណាទៅសម្លាប់ប្រជាជនឯង ទៅបង្អត់បាយ បង្អត់ទឹកប្រជាជនឯងនោះទេ។ ម្នាក់ៗសុខចិត្តលះបង់មកតស៊ូដើម្បីរំដោះជាតិ រំដោះប្រជាជន។ ផុតពីចក្រពត្តិអាមេរិក ដល់ប្រទេសមួយទៀតដែលនៅជិតខាតយើង គឺយួនឈ្លានពានកម្ពុជា។ ដូច្នោះកម្ពុជាប្រជាធិបតេយ្យត្រូវទទួលតស៊ូរំដោះជាតិពីចក្រពត្តិឈ្លានពាន ហើយពីយួន ដែលមានមហិច្ឆតាឈ្លានពានវាទីលេបទឹកដីយើង។

ដូច្នេះក្នុងឱកាសនេះ ខ្ញុំសូមគោរពម្តងទៀត នូវវិញ្ញាណក្ខន្ធរបស់អ្នកស្នេហាជាតិទាំងអស់ ជាពិសេសរបស់លោកស្រី សុជាតិ។ ខ្ញុំបានបញ្ជាក់ពីលើកមុនផងហើយ ត្រង់នេះខ្ញុំសូមបញ្ជាក់ម្តងទៀតថាកម្ពុជាប្រជាធិបតេយ្យមានបំណងល្អចំពោះជាតិ ចំពោះប្រជាជន។ ដូចខ្ញុំម្នាក់ៗលះបង់តស៊ូដើម្បីជាតិដើម្បីប្រជាជនរបស់ខ្លួន។ ខ្ញុំសូមបញ្ជាក់ហើយបញ្ជាក់ទៀត ហើយក្នុងឱកាសនេះ ខ្ញុំសូមគោរពហើយគោរពទៀតដោយចិត្តស្មោះត្រង់រំភើបញ្ជាប់ញ័រចំពោះវិញ្ញាណក្ខន្ធរបស់អ្នកដែលបាត់បង់ទៅ។ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង ហើយម្តងទៀត។ សូមប៉ុណ្ណឹងចុះ។

[១១:៥៤:០៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក នួន ជា។ បាទ ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើដើមបណ្តឹង -- បើសិនជាតំណាងសហព្រះរាជអាជ្ញាមានបំណងធ្វើដូច្នេះ។ សូមអញ្ជើញ!

**លោក ឃីត វេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** សូមជម្រាបសួរលោកស្រី ចាន់ សុជាតិ។ ខ្ញុំសូមសួរលោកស្រីនូវសំណួរមួយចំនួន ហើយនិងខ្ញុំចាប់ផ្តើមសំណួរដូចខាងក្រោមនេះ អំពីពេលវេលាដែលគេបញ្ជូនលោកស្រីចេញពីភ្នំពេញទៅដល់កៀនស្វាយ។ តើត្រូវដែរឬទេ លោកស្រីនៅកៀនស្វាយនោះអស់រយៈពេលប្រហែលជា៦ខែ? តើអ៊ីចឹងឬក៏មិនមែន?

**ឆ៖** ចាស ពិតមែន។

**ស៖** នៅក្នុងរយៈពេល៦ខែនោះ តើសមាជិកក្រុមគ្រួសារបងប្អូនបង្កើតរបស់លោកស្រីហ្នឹងមានអ្នកណាស្លាប់ទេ?

**ឆ៖** នៅក្នុងការរស់នៅរយៈពេល៦ខែនោះ ខ្ញុំបានស្លាប់ប្អូនស្រីមួយ។

**ស៖** តើប្អូនស្រីនោះឈ្មោះអ្វី? ហើយគាត់ស្លាប់ដោយជំងឺអ្វី? ហើយស្លាប់ដោយរបៀបណា?

[១១:៥៥:៤០]

**ឆ៖** ប្អូនស្រីនេះឈ្មោះ គាត់ស្លាប់ដោយជំងឺដាច់ទឹកដោះ ដោយសារថាគាត់នៅតូច។ គាត់ត្រូវបោះទឹកដោះគោ ប៉ុន្តែនៅពេលដែលទីផ្សារសេរីគេឈប់លក់ ហើយនៅទីនោះ យើងមានលុយមិនអាចទីផ្សារសេរីអត់លក់។ មានលុយមិនអាចទិញបាន ហើយគ្មានលទ្ធភាពទៅរកទឹកដោះគោឯណាទេ។ អ៊ីចឹង គាត់ត្រូវការបោះបបរលាយជាមួយនឹងស្ករស ធ្វើឲ្យគាត់មានការរាករុះព្យាបាលឥតជារហូតដល់ស្លាប់។

**ស៖** តើមនុស្សមានប៉ុន្មាននាក់ដែលបានស្លាប់នៅកៀនស្វាយនោះ នៅក្នុងក្រុមគ្រួសាររបស់លោកស្រី ឬក៏អ្នកដែលលោកស្រីបានសង្កេតឃើញផងដែរ?

**ឆ៖** ពេល នៅរយៈពេលនៅកៀនស្វាយ ខ្ញុំមិនយកចិត្តទុកដាក់ចំពោះអ្នកដទៃទៀត ពីព្រោះថាខ្លួនខ្ញុំ និងក្រុមគ្រួសារជួយតែខ្លួនឯងអត់រួចផង។ អ៊ីចឹងរយៈពេលនៃការស្នាក់នៅនោះ គឺប្អូនស្រីរបស់នាងខ្ញុំផ្ទាល់តែម្នាក់គត់ដែលបានស្លាប់។

**ស៖** ដល់ពេលមួយដែលលោកស្រីបានរៀបរាប់ថា បានជិះលើកប៉ាល់ លើកាណូតហ្នឹង គឺថាបានមកដល់ភ្នំពេញ។ បន្ទាប់មកធ្វើដំណើរតាមទូក តាមកាណូតនោះដែលទីបំផុតទៅដល់ភូមិហៅថាអូរក្រៀត។ ថាតើចេញពីភ្នំពេញទៅកំពង់ឆ្នាំងហ្នឹង លោកស្រីអាចបញ្ជាក់ដោយសង្ខេបពីដំណើរហ្នឹងធ្វើដំណើររបៀបម៉េច បានដែរឬទេ?

[១១:៥៦:០០]

**ឆះ** ចាស សូមជម្រាបលោកសហមេធាវី ការចេញដំណើរពីភ្នំពេញទៅកាន់ខេត្តកំពង់ឆ្នាំងតាមរយៈកប៉ាល់។ អ៊ីចឹងគេយើងជាប្រជាពលរដ្ឋថ្មីដែលមានឈ្មោះត្រូវទៅនៅភ្នំពេញ ឡើងកប៉ាល់តាំងពីព្រឹករហូតដល់ល្ងាចម៉ោងប្រាំ ទើបអស់ ដាក់អីវ៉ាន់គ្រប់។ កប៉ាល់បានចេញដំណើរពីវត្តចំប៉ា មកកាន់តាមទន្លេមកដល់ភ្នំពេញ។ ហេតុការណ៍មួយដែលគួរឲ្យរន្ធត់ ហើយភ័យខ្លាចសម្រាប់នាងខ្ញុំរហូតដល់សព្វថ្ងៃ គឺខ្មែរក្រហមបានហៅបុរសម្នាក់មកបាញ់សម្លាប់ នៅពេលដែលបុរសនោះ ត្រេកអរនឹងការវិលត្រឡប់របស់ខ្លួនមកដល់ភ្នំពេញ។ គ្រាន់តែស្រែកថា "ជយោ! យើងមកដល់ភ្នំពេញហើយ" គេក៏ហៅបុរសនោះទៅបាញ់សម្លាប់ទម្លាក់ទឹកទន្លេ។

**សះ** ចាតើលោកស្រីចេញពីកំពង់ឆ្នាំងទៅដល់អូរក្រៀតហ្នឹង ធ្វើដំណើរតាមវិធីអ្វីដែរ? តាមមធ្យោបាយអ្វីដែរ?

[១១:៥៨:៥៣]

**ឆះ** ពេលដែលខ្ញុំឡើងកប៉ាល់នៅកំពង់ឆ្នាំង គេចែកអង្ករឲ្យពួកខ្ញុំហ្នឹង រង់ចាំឡាន។ ឡើងឡានចេញពីកំពង់ឆ្នាំងមកដល់ពោធិ៍សាត់ ឈប់ម្តុំផ្លូវបំបែកលៀច ផ្លូវរថភ្លើង។ ហើយគេបន្តដំណើរឲ្យយើងឡើងរថភ្លើងចេញពីផ្លូវបំបែកលាចក្នុងខេត្តពោធិ៍សាត់ ឆ្ពោះទៅកាន់ភូមិអូរក្រៀត នៅក្នុងស្រុកមោងឫស្សី។

**សះ** តើការធ្វើដំណើរតាមរថភ្លើងដូចម្តេចដែរ ការជិះ? ការហូបចុក? មានទឹក ឬក៏ជីវិតនៅលើរថភ្លើងនោះដូចម្តេចដែរ?

**ឆះ** ការធ្វើដំណើរទៅតាមរថភ្លើង។ រថភ្លើងនោះគឺជាទូដែលគេដឹកសត្វ វ៉ាហ្គុង វាធំៗដូចជាកុងតឺន័រ គេឲ្យយើងដាក់អីវ៉ាន់ឡើង។ ចំណែកការហូបចុក និងទឹក គឺគេមិនបានផ្តល់ឲ្យយើងទេ យើងត្រូវទទួលខុសត្រូវដោយខ្លួនឯង។ នៅពេលដែលយើងឈប់សម្រាក ចុះពីឡាន យើងត្រូវរត់ទៅរកដងទឹកដាក់ប៊ីដុង ដាក់ដប ដាក់ធុង សម្រាប់ហូបចុកទទួលខុសត្រូវដោយខ្លួនឯង។ ឯអង្ករ គេដល់មួយដំណាក់ គឺគេចែកឲ្យយើងមួយដំណាក់។

[១២:០០:១៨]

**សះ** តើលោកស្រីអាចមានជម្រើសថា ត្រូវជិះរទេះភ្លើងហ្នឹងទៅកន្លែងហ្នឹង ឬក៏មិនជិះ អាចសម្រេចខ្លួនឯងអ៊ីចឹងបានទេ?

**ឆះ** ខ្ញុំមិនអាចមានជម្រើសទេដោយសារថា នៅពេលដែលគេតម្រូវឲ្យយើងទៅ គឺយោធាគេ

រុញឲ្យយើងទៅ បើយើងមិនទៅគឺយើងត្រូវតែស្លាប់ ព្រោះគេមានកាំភ្លើងនៅនឹងដៃ។ យើងគ្មានជម្រើសថាយើងត្រូវតែនៅ ឬក៏យើងគ្មានជម្រើសថា យើងមិនទៅ គឺអត់ដាច់ខាត តែគេឲ្យឡើងគឺឡើង ឲ្យទៅគឺទៅ ដោយសារការភ័យខ្លាចនៃសេចក្ដីស្លាប់ ដែលយើងបានឃើញកន្លងមកគ្រាន់តែការត្រេកអរនៃការវិលត្រឡប់ចូលមកភ្នំពេញ បុរសម្នាក់ត្រូវបានគេបាញ់សម្លាប់ភ្លាមៗចំពោះមុខ។

**ស៖** នៅពេលដែលលោកស្រីបានទៅដល់ព្រៃអូរគ្រាតនៅក្នុងស្រុកមួយនៅបាត់ដំបងនោះ តើអ្នកណាដែលស្លាប់មុនគេ បន្ទាប់ពីទៅដល់តំបន់ព្រៃនោះដំបូងនោះបាទ?

[១២:០១:៣១]

**ឆ៖** បន្ទាប់ពីបានទៅដល់ព្រៃនៃភូមិព្រៃទទឹង គេហៅថា "ឆ្កែខាំប្រុស" នោះ ប្អូនប្រុសៗនាងខ្ញុំពីរនាក់បានស្លាប់មុនគេ ដោយសារការអត់អាហារ។

**ស៖** នៅពេលដែលលោកស្រីទៅដល់កន្លែងនោះ ក្រៅពីប្អូនៗរបស់លោកស្រី តើលោកស្រីអាចជម្រាបតុលាការដោយសង្ខេបបានទេថា តើអ្នកដែលស្លាប់ដោយអត់អាហារហ្នឹងចំនួនប្រហែលប៉ុន្មាន? ហើយអស់រយៈពេលដែលនៅហ្នឹងគឺស្លាប់មួយថ្ងៃៗប៉ុន្មានជាដើម?

**ឆ៖** ខ្ញុំសូមជម្រាបជូនថា រយៈនៃការរស់នៅទីនោះ គឺវេទនាបំផុត មិនថាគ្រួសារខ្ញុំ មិនថាគ្រួសារគេគឺជាប្រជាជនថ្មី ដែលគេជម្លៀសទៅ ហើយដែលគេកំណត់មុខសញ្ញាថា ជាពួកសក្ដិភូមិចិនយួន ឬក៏គឺជាអ្នកថ្មីដែលគេយកឲ្យទៅនៅព្រៃនៅក្នុងភូមិឆ្កែខាំប្រុសនោះ ស្លាប់ស្ទើរផុតពូជ ខ្លះស្លាប់មួយថ្ងៃចង់អស់ រយៈពេលតែមួយសប្ដាហ៍ប៉ុណ្ណោះ គ្រួសារខ្ញុំស្លាប់អស់ប្រាំមួយប្រាំពីរនាក់ដោយសារការអត់អាហារ។ ហើយគ្មានរកអ្វីបានហូបទេ អត់មានអ្វីទាំងអស់ មានតែគេហៅថា "ផ្ទីចិន ឬក៏ផ្ទីថ្ម" យកស្ងោរហូប ហើយរឹតតែរាគរូស ធ្វើឲ្យរឹតតែធ្ងន់ធ្ងរហែមទៀត។

**លោក ឃីត រេយ៉ន័រ៖**

សូមអរគុណលោកស្រី។ ខ្ញុំមិនមានសំណួរអ្វីទៀតទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញា។ ជាបន្ត អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

[១២:០៣:៤៩]

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន! ក្រុមមេធាវីការពារលោក នួន ជា ពុំមានសំណួរទៅលោកស្រី សុជាតិ នេះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន!

[១២:០៤:១០]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំមានសំណួរមួយសម្រាប់អ្នកស្រី សុជាតិ ទាក់ទងទៅនឹងលោកស្រីបានឃើញទាហានខ្មែរក្រហមបាញ់សម្លាប់បុរសម្នាក់នៅពេលដែលធ្វើដំណើរតាមកប៉ាល់មកដល់ភ្នំពេញ។ អ្នកស្រីឃើញក្នុងចម្ងាយណា នៅលើកប៉ាល់ជាមួយគ្នា? ជាកប៉ាល់ធំប៉ុនណា លោកស្រីអាចរៀបរាប់ពីស្ថានភាពកប៉ាល់នោះបានទេ?

**ឆ៖** ចាស អរគុណចំពោះលោកមេធាវីចុងចោទ។ លោកដឹងហើយថាកប៉ាល់គឺមានទំហំធំ ហើយពេលដែលគ្រួសារនៅក្នុងកប៉ាល់នោះរាប់រយគ្រួសារ ប៉ុន្តែជាក់ស្តែងខ្ញុំផ្ទាល់នៅជិតមាត់ផ្លូវតែម្តង ដោយឃើញបុរសនោះស្រែក បុរសនោះអង្គុយជិតខ្ញុំ ខ្ញុំអង្គុយបែរខ្នង ហើយខ្ញុំមើលទៅលិចឃើញគាត់ស្រែកមុន “នោះមុខវាំង ដល់ហើយជយោ! យើងដល់ហើយ”។ ខ្ញុំងាកទៅឃើញភ្លឺខ្ញុំក៏អរដែរ ខ្ញុំក៏រំភើបដែរ ដោយគិតថា ខ្ញុំបានមកដល់ភ្នំពេញវិញហើយ ស្រាប់តែខ្មែរក្រហមមកឈរនៅមាត់ទ្វារកប៉ាល់ហ្នឹង ហៅបុរសហ្នឹងចេញទៅក្រៅ។ គ្រាន់តែឈរអត់ដឹងថា គេសួរភាសាអីផង ដោយសារកប៉ាល់នោះវាឮសូរង្ហូងពេក ស្រាប់តែវាបាញ់ផ្ទូងៗទម្លាក់ឮសូរប្រូងនៅចំពោះមុខៗតែម្តង។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីអាចបញ្ជាក់ពីពេលវេលាបានទេថា ចាប់ពីពេលដែលបុរសម្នាក់គាត់បានស្រែកហ្នឹងរហូតដល់ពេលដែលបុរសនោះត្រូវគេបាញ់មានរយៈពេលប៉ុន្មានប្រហែលប៉ុន្មាននាទីដែរ?

[១២:០៥:៥៨]

**ឆ៖** ចាស ខ្ញុំសូមជម្រាបជូនថា ពេលយើងចេញដំណើរពីវត្តចំប៉ា ឡើងកប៉ាល់មកហ្នឹងមក ប្រាំល្ងាច។ អ៊ីចឹងខ្ញុំអត់មាននាឡិកាមើលម៉ោងទេ ប៉ុន្តែនៅពេលដែលខ្ញុំងាកទៅក្រោយថ្ងៃបាក់រសៀល គងព្រៃអ៊ីចឹងពេលហ្នឹងភ្លើងភ្លឺហើយនៅមុខវាំង ភ្លឺរន្ទាល ហើយរយៈពេលនៃការធ្វើដំណើរពីនោះរហូត ចេញសន្លឹមៗចាក់ភ្នែកលែងយល់រហូតដល់ភ្លឺស្រាំងៗទើបយើងធ្វើដំណើរទៅដល់កំពង់ឆ្នាំ។

**ស៖** សូមទោសអ្នកស្រី។ ខ្ញុំសួរអំពីរយៈពេលពីបុរសម្នាក់ដែលបានស្រែកថា គាត់បានមកដល់ភ្នំពេញហើយ ជយោអំមិញហ្នឹងណ៎ះ ហើយរហូតដល់ពេលដែលគេបាញ់គាត់ហ្នឹង តើមានរយៈពេលពីស្រែកដល់បាញ់ហ្នឹងមានរយៈពេលប៉ុន្មាននាទី?

**ឆ៖** ចាស សូមគោរព។ ខ្ញុំសូមជម្រាបជូនថា ខ្ញុំមិនបានគិត និងផ្ទៀងផ្ទាល់ពីពេលវេលាទេ ដោយសារពេលនោះ ខ្ញុំមានអារម្មណ៍ភ័យខ្លាចណាស់។ ប៉ុន្តែនៅគ្រាន់តែពេលគាត់ស្រែកថា ជយោ យើងដល់ភ្នំពេញហើយ។ ចប់ មនុស្សផ្អើលពេញកប៉ាល់ នាំគ្នាអើតមើលស្រាប់តែយោធាម្នាក់នុំងហៅគាត់ចេញមកដល់មុខមាត់ទ្វារឈរនៅលើគែមទូក ហើយស្រាប់តែអត់ដឹងថា គេនិយាយជាមួយបុរសនោះថា ម៉េចទេ ដោយសារស្តាប់អត់ឮ ស្រាប់តែគេបាញ់ភ្លាមៗនោះតែម្តង។ តែខ្ញុំមិនគិតថា ប៉ុន្មាននាទីទេ ព្រោះខ្ញុំអត់ប៉ាន់ស្មានបាន។ សូមមិនឆ្លើយពីពេលវេលា និង -- ខ្ញុំសូមមិនឆ្លើយពីនាទី ព្រោះខ្ញុំមិនអាចប៉ាន់ស្មានបាន។

[១២:០៧:៣៤]

**ស៖** លោកស្រីអាច ខ្ញុំអាចថា តិចជាង ៥នាទី តើអ៊ីចឹងអាចត្រឹមត្រូវទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** សូមអ្នកស្រីឆ្លើយម្តងទៀត ដោយសារអត់ទាន់បើកក្បាលមីក្រូ។

**ឆ៖** ចាស ប្រហែលជាខ្ទង់ ៥នាទីហ្នឹង។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីមានបានសង្កេតមើលថា អ្នកដែលចាប់បុរសម្នាក់នោះ គាត់បានមាន ឧទាហរណ៍ថា ធ្វើទំនាក់ទំនងទៅថ្នាក់ណា ទៅកន្លែងណាផ្សេងទៀតបានទេ ដូចជាប្រើវិទ្យុទាក់ទង ឬក៏អ្វីដើម្បីទំនាក់ទំនងទៅខាងក្នុងកប៉ាល់ ឬក្រៅចេញទៅក្រៅកប៉ាល់?

**ឆ៖** ចាស បើនិយាយពីស្ថានភាព ខ្ញុំអត់ដឹងថា អ្នកនោះមានឋានៈតួនាទីជាអ្វីទេ។ ប៉ុន្តែគ្រាន់តែដឹងថា អ្នកហ្នឹង គឺជាយោធាដែលឲ្យយើងឡើងកប៉ាល់ហើយ ស្រែកបញ្ជាឲ្យកប៉ាល់ចេញដំណើរ ហើយគាត់ឈរនៅលើក្បាលកប៉ាល់នោះ។

[១២:០៩:០១]

**ស៖** បាទ សូមអរគុណ។ លោកស្រីដឹងឋានៈរបស់គាត់ទេ?

**ឆ៖** ចាសខ្ញុំមិនបានដឹងទេ។ ព្រោះគេមិនបានប្រាប់យើងទេថាគាត់មានឋានៈតួនាទីជាអ្វី គ្រាន់តែយើងដឹងថា គាត់គឺជាយោធាខ្មែរក្រហមដែលទទួលខុសត្រូវក្នុងការដឹកជញ្ជូនយើងចេញតែប៉ុណ្ណោះ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណអ្នកស្រី ខ្ញុំអស់សំណួរហើយ។

លោកប្រធាន ខ្ញុំសូមអស់សំណួរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី ចាន់ សុជាតិ ការស្តាប់សេចក្តីថ្លែងការណ៍ ថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម សក្ខីកម្មរបស់លោកស្រីរហូតដល់ពេលនេះបានចប់ហើយ វត្តមានរបស់លោកស្រីនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ សក្ខីកម្មរបស់លោកស្រី សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងព្យសនកម្មរបស់លោកស្រីនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនៅរឿងក្តីនេះ។ លោកស្រីអាចវិលត្រឡប់ទៅវិញបានហើយ សូមលោកស្រីមានសុខភាពល្អ ជួបតែសំណាងល្អ ហើយបានសេចក្តីសុខសេចក្តីចម្រើន។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុង ការជូនដើមបណ្តឹងរដ្ឋប្បវេណីរូបនេះវិលត្រឡប់ទៅកាន់ទីកន្លែងគោលដៅណាដែលគាត់មានបំណងចង់ ទៅឬក៏លំនៅដ្ឋានគាត់វិញហើយ។

នៅរសៀលនេះអង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា ស្ថានភាពព្យសនកម្ម និងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូបគឺ TCCP-13 តាមមធ្យោបាយសោតទស្សន៍ពីប្រទេសបារាំងហើយនិង TCCP-198 ដែលគាត់នឹងចូលរួមសវនាការដោយផ្ទាល់។ ហើយសវនាការនៅរសៀលនេះនឹងចាប់ផ្តើមពី ម៉ោងមួយ និងម្ភៃនាទី។

ហើយឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយ និងម្ភៃនាទី សូមអញ្ជើញចូលវិញ។ សូមភាគីនៃរឿងក្តីបុគ្គលិកជំនួយស្មារតីដើមបណ្តឹងរដ្ឋប្បវេណីនិងសាធារណជនជ្រាប។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួន គាត់ត្រឡប់មកចូលសវនាការនៅក្នុងបន្ទប់

សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយ និងម្ភៃនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:១១ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣៣:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្តទៅនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម ឬផលប៉ះពាល់ដើម្បីបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-13 តាមមធ្យោបាយសោតទស្សន៍ពីប្រទេស។ ហើយសូមជម្រាបជូនភាគី និងសាធារណជនផងដែរ ដោយសារបច្ចេកទេសនៃការភ្ជាប់ប្រព័ន្ធសោតទស្សន៍ធ្វើឲ្យអង្គជំនុំជម្រះមានការយឺតយ៉ាងជាពេលបានកំណត់ព្រឹកមិញ១៥នាទី។ ព្រឹកមិញ អង្គជំនុំជម្រះមានបំណងធ្វើសវនាការម៉ោងមួយម្ភៃនាទី ប៉ុន្តែដោយសារបច្ចេកទេសសោតទស្សន៍ គឺយើងយឺតរហូតដល់១៥នាទី។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ តើលោកស្រីឈ្មោះ ឆេន អេងលី អ៊ីចឹងមែនដែរទេ? សួស្តីដើមបណ្តឹងរដ្ឋប្បវេណី! តើលោកស្រីឈ្មោះ ឆេង អេងលី អ៊ីចឹងពិតមែនទេ?

**លោកស្រី ឆេង អេងលី៖**

**ឆ៖** ចាស ខ្ញុំឮច្បាស់។

**ស៖** បាទ អរគុណ។ តើលោកស្រីឈ្មោះ ឆេង អេងលី អ៊ីចឹងពិតមែនទេ?

**ឆ៖** ចាស មែនលោកប្រធាន។

**ស៖** បាទ អរគុណ លោកស្រី អេងលី។ តើលោកស្រីមានអាយុប៉ុន្មានឆ្នាំ?

**ឆ៖** ខ្ញុំមានអាយុ៦០ឆ្នាំហើយ ចាស។

**ស៖** បាទ អរគុណ លោកស្រី អេងលី។ ហើយតើលោកស្រីមានទីកន្លែងកំណើតនៅទីកន្លែងណា?

[១៣:៣៦:០០]

**ស៖** បាទ អរគុណ ហើយទីលំនៅរបស់លោកស្រីសព្វថ្ងៃនេះ នៅទីកន្លែងណា?

**ផ៖** ខ្ញុំសព្វថ្ងៃនៅទីក្រុងបារីស លេខ១៩ ផ្លូវអេតង់ដឺឡាត្លូ នៅត្រាំឬយីឡូ។

**ស៖** បាទ អរគុណ ហើយចុះលោកស្រីប្រកបមុខរកស៊ីធ្វើអ្វីដែរ?

**ផ៖** ខ្ញុំជាឱសថការីនៅបារីស។

**ស៖** បាទ អរគុណ។ ហើយលោកស្រីអាចប្រាប់ដល់អង្គសវនាការអំពីឈ្មោះឪពុកលោកស្រីបង្កើត ហើយនិងម្តាយលោកស្រីបង្កើត តើគាត់ឈ្មោះអី?

**ផ៖** លោកឪពុកឈ្មោះ ឆេង សេងកែវ គាត់ស្លាប់ហើយ។

**ស៖** ចុះម្តាយបង្កើតរបស់លោកស្រី?

**ផ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** លោកស្រី អេងលី ឮខ្ញុំនិយាយទេ តើម្តាយបង្កើតរបស់លោកស្រីគាត់ឈ្មោះអី?

[១៣:៣៧:២២]

*(មានបញ្ហាបច្ចេកទេស)*

[១៣:៣៨:២៧]

**ស៖** ម្តាយរបស់លោកស្រីគាត់ឈ្មោះអី?

**ផ៖** គាត់ឈ្មោះ សុខ អេង គាត់ស្លាប់ហើយដែរ ចាស។

**ស៖** បាទ អរគុណ។ តើលោកស្រីសព្វថ្ងៃនេះ នៅលីវ ឬក៏រៀបការហើយ?

**ផ៖** ចាស ខ្ញុំមានគ្រួសារ មានប្តីហើយ ចាស។

**ស៖** ប្តីលោកស្រីឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ផ៖** ប្តីខ្ញុំឈ្មោះ ឆាយ ហុកផេង។ ខ្ញុំមានកូនទាំងអស់៥នាក់។

[១៣:៣៩:០០]

**ស៖** បាទ អរគុណលោកស្រី ឆេង អេងលី ក្នុងនាមលោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការនេះ អង្គជំនុំជម្រះសាលាដំបូងផ្តល់ឱកាសជូនលោកស្រីថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការអំពីស្ថានភាពទុក្ខសោកវេទនា ស្ថានភាពព្យសនកម្ម ឬក៏ផលប៉ះពាល់ដែលបានកើតមានចំពោះលោកស្រីមានជាអាទិ៍៖ ការខូចខាតខាងផ្លូវចិត្ត ផ្លូវកាយ និងសម្ភារៈ ហើយជាព្យសនកម្ម ឬក៏ប៉ះពាល់ដោយផ្ទាល់

ខ្លួនដែលជាបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋ និងបានកើតមានពិតប្រាកដរហូតដល់ពេលបច្ចុប្បន្ននេះ ដែលនាំឲ្យលោកស្រីតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីនេះ។ ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទចំនួនពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកស្រីក្នុងរបបកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុងពេលចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ៧៩។ សូមអញ្ជើញ!

**ឆៈ** ពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំមិនបាច់រៀបរាប់ទេ អស់លោកប្រាកដជាជ្រាបហើយ ទាំងអស់គ្នាប្រជាជនខ្មែរយើង ដែលរងគ្រោះដោយរបបប្រជាធិបតេយ្យហ្នឹងបានជម្រាបដូចដដែលៗហើយ ប៉ុន្តែចំពោះខ្លួនខ្ញុំផ្ទាល់ដែលទុក្ខសោកវេទនា ពិបាកនៅក្នុង--

*(មានបញ្ហាបច្ចេកទេស)*

[១៣:៤១:០៦]

**ប្រធានអង្គជំនុំ៖**

បាទ សូមជម្រាបជូនភាគី និងសាធារណជនថាយើងដំណើរការរអាក់រអួលដោយសារមូលហេតុប្រព័ន្ធអ៊ីធើណេតមានការរអាក់រអួលម្ដងដាច់ ម្ដងមាន។

*(មានបញ្ហាបច្ចេកទេស)*

[១៣:៤៤:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ សូមជម្រាបថាមានបញ្ហាដាច់ប្រព័ន្ធអ៊ីនធឺណេតនៅឯប្រទេសបារាំង ហើយត្រូវការចំណាយប្រហែលជាពេល ពេលវេលា៥នាទីក្នុងការរៀបចំឡើងវិញនៅទីនោះ។ អ៊ីចឹងយើងសូមបង្អង់នៅទីនេះដើម្បីរង់ចាំការរៀបចំឲ្យបានល្អឡើងវិញក្នុងរយៈពេលតែ ៥នាទីទេ។

*(មានបញ្ហាបច្ចេកទេស)*

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥២:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ ដោយសារយើងបានចំណាយពេលវេលាច្រើនហើយ ហើយការភ្ជាប់ប្រព័ន្ធអ៊ីនធឺណេតនៅឯទីក្រុងប៉ារីសនៅតែមានបញ្ហា។ ហើយក្រោយពីបានពិភាក្សាគ្នាទៅអង្គជំនុំជម្រះយល់ឃើញថា មិន

គប្បីទុកពេលវេលាឲ្យរបៀបនេះទេគឺអង្គជំនុំជម្រះសម្រេចប្តូរមកជំនួសវិញនៅពេលនេះដោយការស្តាប់នូវសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-198 ហើយចំណែកឯដើមបណ្តឹងរដ្ឋប្បវេណីអំបាញ់មិញនេះ គឺទុកលទ្ធភាពឲ្យអ្នក បច្ចេកទេស រៀបចំនូវប្រព័ន្ធអ៊ីនធឺណេតឲ្យបានល្អប្រសើរ ហើយយើងនឹងធ្វើការងារនេះបន្តបន្ទាប់ពីស្តាប់នូវសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-198 ចប់។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីTCCP-198 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តី លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ តើលោកស្រីឈ្មោះអី?

[១៣:៥៥:០០]

**លោកស្រី ហូ ចន្ថា៖**

**ឆ៖** នាងខ្ញុំឈ្មោះ ហូ ចន្ថា។ ស្រុកកំណើតនៅផ្សារកំពង់សឹង្ហ ឃុំកំពង់សឹង្ហ ស្រុកបាភ្នំ ខេត្តព្រៃវែង។ បច្ចុប្បន្ននៅភូមិពកឫស្សី ឃុំពកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។

**ស៖** អរគុណលោកស្រី ចន្ថា។ តើលោកស្រីមានអាយុប៉ុន្មាន ហើយលោកស្រីប្រកបមុខរបររកស៊ីធ្វើអ្វីដែរសព្វថ្ងៃនេះ?

**ឆ៖** នាងខ្ញុំលក់ដូរបន្តិចបន្តួច ហើយសព្វថ្ងៃហ្នឹងនាងខ្ញុំនៅស្រុកខាងប្តី ពកឫស្សី ចាស។

**ស៖** លោកស្រីមានអាយុប៉ុន្មានឆ្នាំ? លោកស្រី ចន្ថា រង់ចាំ បង្អង់ចាំបន្តិចនៅពេលដែលមានសំណួរ រង់ចាំរហូតដល់ក្បាលមីក្រូហ្វូននៅមុខលោកស្រីហ្នឹងប្រតិបត្តិការដោយឲ្យភ្លើងសញ្ញាក្រហមដូចនេះ ហើយនិងមើលប៊ូតុងវាហ្នឹងមានសញ្ញាភ្លើងពណ៌ក្រហមចេញ សូមលោកស្រីចាំផ្តើមនិយាយទើបសំឡេងរបស់លោកស្រីបានចូលទៅក្នុងប្រព័ន្ធនៃការចែកចាយសំឡេងទាំងការជូនសំឡេងរបស់លោកស្រីទៅអង្គភាពបកប្រែភាសាដើម្បីបកប្រែភាសាទៅជាភាសាបារាំង និងភាសាអង់គ្លេសផង។ លោកស្រីឆ្លើយម្តងទៀត។ តើលោកស្រីអាយុប៉ុន្មាន?

[១៣:៥៦:៣៥]

**ឆ៖** នាងខ្ញុំអាយុ៦០ឆ្នាំហើយលោក។

**ស៖** អរគុណ ហើយឪពុកបង្កើតរបស់លោកស្រី គាត់ឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកស្រីគាត់ឈ្មោះអី?

**ឆ៖** ឪពុកនាងខ្ញុំឈ្មោះ ហូ ហាង នៅផ្សារកំពង់សីល្ក។ ម្ដាយខ្ញុំឈ្មោះ កោក ង៉ោ នៅស្រុកកំណើតគាត់នៅកំពង់សីល្កហ្នឹងដែរចាស។

**ស៖** អរគុណ ចុះម្ដាយរបស់លោកស្រី គាត់ឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ប្ដីនាងខ្ញុំឈ្មោះ ធួន សាអឹម។ គាត់ជាគ្រូបង្រៀន ហើយនាងខ្ញុំមានកូនប្រាំនាក់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី លោកស្រី ហូ ចន្ថា ក្នុងនាមលោកស្រីជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសវនាការនេះ អង្គជំនុំជម្រះផ្ដល់ឱកាសជូនលោកស្រីអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការអំពីស្ថានភាពទុកវេទនា ស្ថានភាពព្យសនកម្ម ឬផលប៉ះពាល់ដែលកើតមានឡើងចំពោះលោកស្រី ជាអាទិ៍ការខូចខាតខាងផ្លូវចិត្ត ផ្លូវកាយ ឬសម្ភារៈ ព្យសនកម្ម ឬក៏ផលប៉ះពាល់ផ្ទាល់ខ្លួនដែលជាបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋដែលបានកើតពិតប្រាកដរហូតដល់បច្ចុប្បន្ននេះដែលនាំឲ្យលោកស្រីប្ដឹងតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលបានត្រូវចោទប្រកាន់ទៅលើជនជាប់ចោទចំនួនពីររូបលោកនួន ជា និងលោក ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកស្រីក្នុងរបបកម្ពុជាប្រជាធិបតេយ្យអំឡុងពេលចាប់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ សូមអញ្ជើញ!

[១៣:៥៨:៣៧]

**លោកស្រី ហូ ចន្ថា៖**

សូមគោរពតុលាការកូនកាត់ជាគោរព--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ថ្លែងអីលោកស្រី។ លោកស្រីមេធាវីរបស់លោកស្រី គាត់ឡើងមានបញ្ហាអី គាត់ឡើងងើបឈរហើយ។ សូមអញ្ជើញលោកស្រីមេធាវី។

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន។ ជាបឋមនាងខ្ញុំគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ ដោយសារតែកូនក្ដីនាងខ្ញុំរូបហ្នឹង គាត់មានបំណងចង់អាននូវអត្ថបទដែលគាត់បានរៀបចំឡើងដោយផ្ទាល់ខ្លួននូវប្រវត្តិទុក្ខវេទនាដែលគាត់បានជួបប្រទះក្នុងរបបកម្ពុជាប្រធិបតេយ្យនិង

ការបាត់បង់ឪពុកម្តាយ សាច់ញាតិបងប្អូនរបស់គាត់ហ្នឹង ហើយនិងឯកសារទាំងហ្នឹងគឺគាត់រៀបចំដោយផ្ទាល់របស់គាត់មុននឹងគាត់មកកាន់នូវសាលសវនាការនេះ។ ហើយនិងបន្ទាប់ពីគាត់អានចប់ បើសិននៅសេសសល់ពេលវេលា នាងខ្ញុំនឹងធ្វើការសាកសួរគាត់នៅសំណួរមួយចំនួនតូច។ ហើយចុងក្រោយនេះដែរ នាងខ្ញុំសូមជម្រាបជូនលោកប្រធានថា នៅពេលដែលចុងបញ្ចប់នៃការអានរបស់គាត់ហ្នឹង គាត់ក៏មានសំណួរមួយចំនួនទៅកាន់ជនជាប់ចោទផងដែរ។ អ៊ីចឹងនាងខ្ញុំ ស្នើសុំអនុញ្ញាតពីលោកប្រធានដើម្បីឲ្យគាត់បានអាន និងបានសួរសំណួរដល់ជនជាប់ចោទ។ សូមអរគុណ។

[១៣:៥៩:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញលោកស្រី ចន្ថា!

**លោកស្រី ហ៊ូ ចន្ថា៖**

ជាបឋមនាងខ្ញុំ សូមអរគុណតុលាការដែលបានអនុញ្ញាតឲ្យនាងខ្ញុំថ្លែងរៀបរាប់ពីទុក្ខវេទនាក្នុងប្រវត្តិដ៏ល្វីងជូរចត់ក្នុងរបបខ្មែរក្រហម ហើយបន្សល់ទុក្ខវេទនាដល់កូនៗ និងរូបខ្ញុំផ្ទាល់ទាល់សព្វថ្ងៃ។ កាលពីសម័យ លន់ នល់ ឪពុកម្តាយរបស់នាងខ្ញុំមានជីវភាពធូរធារបង្គួរ ពួកគាត់មានមុខរបរលក់ចាប់ហួយនៅផ្សារកំពង់សឹង។ ខ្ញុំមានបងប្អូនប្រាំបួននាក់។ នាងខ្ញុំជាកូនទី៤។ បងៗនាងខ្ញុំបីនាក់មានគ្រួសារអស់ហើយ សុទ្ធតែជាមន្ត្រីរដ្ឋការជំនាន់ លន់ នល់។ ហើយពួកគាត់មានដីមានផ្ទះសម្បែង មានម៉ូតូ មានគ្រឿងអលង្ការសមល្មមនៅក្រុងភ្នំពេញ។ ក្នុងឆ្នាំ១៩៧២ នាងខ្ញុំបានរៀបការរួចមករស់នៅជាមួយម្តាយក្មេក នៅក្បែរផ្សារក្បាលមាន់ចែ។ កាលនោះប្តីរបស់ខ្ញុំធ្វើជាគ្រូបង្រៀន។ ស្ថានភាពជីវភាពរបស់ពួកយើងខ្ញុំធូរធារ ហើយពួកយើងមានម៉ូតូ មានគ្រឿងអលង្ការ មានផ្ទះសម្បែងជាៗទ្រព្យរបស់ខ្លួនផ្ទាល់ មិនយ៉ាប់ដូចបច្ចុប្បន្ននេះទេ។

កាលណោះ ខ្ញុំមាន-- ខ្ញុំមិនដែលស្គាល់ការលំបាកនោះឡើយ។ លុះដល់ថ្ងៃ១៦ មេសា ១៩៧៥ ជាថ្ងៃអវសាននៃរបប លន់ នល់។ សូរកាំភ្លើងគ្រាំគ្រេងនៅជ្រុងពោធិ៍ចិនតុង និងជុំវិញទីក្រុងភ្នំពេញ។ តាំងពីព្រលប់រហូតដល់ភ្លឺ។ លុះព្រឹកឡើងម៉ោងប្រាំបីនៅថ្ងៃទី១៧ មេសា ឆ្នាំដដែល ក៏ឃើញប្រជាជនក្បែរខាងគេឈររើកទង់ជ័យស។ គ្រួសារនាងខ្ញុំក៏ឈរអបអរស្រែកជយឃោសតាមគេដែរ ថាចប់ហើយសង្គ្រាម សន្តិភាពនឹងមានឡើងវិញហើយ។ ពេលនោះ ឃើញទាហានខ្មែរក្រហមស្លៀកពាក់ឈុតខ្មៅ ក្មេងៗដើរតាមផ្លូវបន្តបន្ទាប់។ គេមិន គេមិនស្វាគមន៍ពួកយើងអ្នកស្រែកជ័យឃោសនោះទេ ព្រោះ

គេពួកគេនៅស្ងៀមទឹកមុខមាំ។ ការធូរស្បើយក្នុងចិត្តមិនទាន់បានប៉ុន្មានម៉ោងផង ក៏ស្រាប់តែទាហានឈុតខ្មៅនេះ ស្ទៀយកាំភ្លើងស្រែកប្រាប់ថា "ចេញ!ៗ មិនឲ្យនៅក្រុងទេ។ គេបោសសម្អាតទីក្រុង ៣ថ្ងៃ"។ គ្រួសារខ្ញុំ គេឲ្យចេញតាមផ្លូវពោធិ៍ចិនតុង។ ភ្លាមៗនោះ គ្រួសារខ្ញុំរត់រកគ្នាច្របូកច្របល់មិនដឹងយកស្អីទុកស្អី ដឹកជញ្ជូនយ៉ាងម៉េច។ ពេលនោះ ទាហានខ្មែរក្រហមចេះតែដើរគំរាមឲ្យចេញឆាប់ៗ ដោយៗមានបាញ់កាំភ្លើងគំរាមឡើងលើទៀតផង។

[១៤:០៣:២៦]

សភាពការណ៍មិនបានដឹងមុននេះ ធ្វើឲ្យក្រុមគ្រួសាររបស់ខ្ញុំភ័យតក់ស្លុតញ័រដៃញ័រជើងអស់ហើយ។ ខ្ញុំវិលមុខ ក្នុងចិត្តគិតមិនចេញ យកមួយស្ដាយមួយ យកទាំងអស់ទៅពុំរួច ភ្លេចមុខភ្លេចក្រោយ នឹកស្ដាយរបស់ទ្រព្យខ្លាំងណាស់។ ណាខ្លាចគេមិនឲ្យចូលវិញ ណាខ្លាចបែកឪពុកម្ដាយ ព្រោះចេញផ្លូវខុសគ្នា។ តាមដងផ្លូវនាងខ្ញុំឃើញប្រជាជនណែនពេញផ្លូវ។ ខ្លះបើកឡានតិចៗ ខ្លះបើកម៉ូតូ ខ្លះបណ្ដើរកង់ ខ្លះរែក ខ្លះទូល។ ទិដ្ឋភាពគួរឲ្យសង្វេគបំផុត គឺអ្នកជំងឺមានសេរ៉ូមជាប់នឹងដៃ ជិះពីលើកង់ពីក្រោយគ្រួសារបណ្ដើរកង់។ ស្ត្រីទើបកើតកូនថ្មីៗ កូនក្រហមរងាលត្រូវគេឲ្យចេញ ដើរហាលភ្លៀងផ្គរ។ ជនពិការ តាយាយចាស់ៗដើរយ៉ាងហេវហត់ ស្ទើរលើកជើងពុំរួច។ កុមារាកុមារី យំទ្រហឹងទារឲ្យម្ដាយពរ ព្រោះឈឺជើង។ តាមសងខាងផ្លូវឃើញខ្មោចទាហាន លន់ នល់ ដេរស្លាប់រដូករណែលគួរឲ្យអាសូរខ្មែរខ្លាំងណាស់។ គ្រួសារខ្ញុំនិងម្ដាយក្មេងធ្វើដំណើរតាមព្រែកព្នៅសំដៅស្រុក។ ដល់ផ្លូវកែងបត់ទៅព្រែកព្នៅថ្ងៃលិចល្ងាច។ យើងទាំងអស់គ្នារៀបរកកន្លែងដាំបាយហូប ខ្លះទៅរកទឹក ខ្លះទៅរកដីដុំ ធ្វើម៉ុចង្រ្កាន ខ្លះរកឧស។ យប់នោះហើយ ដែលជាយប់ដំបូងបង្អស់ដែលរូបនាងខ្ញុំជួបរឿងអកុសលដែលមិនធ្លាប់មានមិនធ្លាប់ដឹងក្នុងជីវិត។ ប្រាសខ្លួនដេកលើកន្ទេលក្រាលផ្ទាល់ដី មានដីដុំតូចៗ សែនអាសូរខ្លួន។ យប់ម្សិលមិញអញដេកលើពូកទន់ត្រជាក់ យប់នេះ អញមកដេកលើដីពិបាកខ្នង ប្រែប្រួលដេកមិនលក់ឡើយ។ តើថ្ងៃណានឹងបានកេងលើគ្រែ? អារម្មណ៍មួម៉ៅក្ដៅក្រហាយ ហេតុអ្វីក៏សង្គ្រាមចប់ហើយ បែបជាវេទនាទៅវិញ។ លុះព្រឹកឡើង នាំគ្នាបន្តដំណើរទៅទៀត ទៅដល់ព្រែកព្នៅ ថ្ងៃលិច -- ថ្ងៃរាបលិចល្ងាចនោះ ឮពួកចចាមអារាមថា លុយឈប់ចាយ។ នាងខ្ញុំឆ្ងល់ណាស់ បើមិនចាយលុយ ធ្វើម៉េចទិញបានហូបទៅ? ចុះលុយអញខំប្រឹងសន្សំ? ខំប្រឹងដឹកជញ្ជូននេះ? វាទៅជាលុយ វាទៅជាក្រដាសខ្មោចហើយឬ? ខកចិត្តធំណាស់ លុយ១០លានរៀល ខំវេចខ្ចប់ឲ្យជិតខ្លាចត្រូវទឹកភ្លៀង បែរជាអសារបង់ឥតន័យ ឥតតម្លៃទៅវិញ។

[១៤:០៦:៣៦]

ស្អែកឡើងជួលទូកចម្លងទៅត្រើយម្ខាង តាមផ្លូវមនុស្សដើរគ្រប់ច្រកល្ហក។ ដើរៗទៅថ្ងៃរសៀល ក្បែរបឹងមួយ ដែលមានទឹកល្អក់ គ្រាន់តែឃើញទឹក នាំគ្នារត់សំដៅរកទឹក ព្រោះស្រេកទឹកខ្លាំងណាស់ ព្រោះហេវហត់នឹងការធ្វើដំណើរប្រចាំថ្ងៃ ថ្ងៃក្ដៅ កណ្ដាលថ្ងៃហួតហែង ល្ងាចនោះហើយដែលនាងខ្ញុំបង្ខំចិត្តផឹកទឹកល្អក់ធុំឆ្អាបត្រី ទាំងក្អួតចង្អោរ គ្រួសារខ្ញុំក៏នាំគ្នាសម្រាកនៅទីនោះមួយយប់។ លុះស្អែកឡើង ក៏នាំគ្នាបន្តដំណើរទៅមុខទៀត រហូត១៥ថ្ងៃទើបទៅដល់ស្រុកពុកឫស្សី។

ទៅដល់ភ្លាមដីភូមិម្ដាយក្មេក សុទ្ធតែព្រៃដុះស៊ុបទ្រុប ឃើញសភាពបែបនេះ ទាំងអស់គ្នាអស់សង្ឃឹមមួយកម្រិតទៀត ព្រោះគ្មានផ្ទះសម្បែងជ្រក។ ល្ងាចនោះ គ្រួសារនាងខ្ញុំទៅជ្រកផ្ទះក្បឿងបាក់បែកមួយ មានតែដំបូលឥតជញ្ជាំងទេ ហើយយប់នោះ មានផ្គររន្ទះរន្ទះខ្លាំងណាស់ ធ្វើឲ្យសាចទទឹកគ្មានសល់ ដូចនៅកណ្ដាលវាលដែរ។ ស្អែកឡើង ក៏មិនបានឃើញប្រធានភូមិមកសួរសុខទុក្ខ ឬក៏ចាត់ចែងឲ្យធ្វើខ្ទមត្រង់ណាដែរ។ គ្រួសារនាងខ្ញុំបានស្វះស្វែងរកឫស្សី ពីងពង់ កន្ទុំថេតមកធ្វើសសរ ធ្វើជាផ្ទង់ផ្ដាន ជាដងកណ្ដប រួចទៅច្រូតស្រូវមកក្រងប្រក់ដំបូល។ មិនទាន់បានពីរថ្ងៃផង មានគេទៅហៅទៅប្រជុំ។ ពេលប្រជុំនោះ គេប្រាប់ឈ្មោះប្រធានក្រុមមានការអី ត្រូវរាយការណ៍ប្រាប់គេ។ គេហៅធ្វើអី ទៅតាមគេមិនអាចតវ៉ាបានឡើយ។ យប់មួយម៉ោងប្រាំពីរ ក្នុងខែ៦ ឆ្នាំ៧៥ គ្រួសារនាងខ្ញុំមិនទាន់ហូបបាយទេ ប្អូនថ្លៃខ្ញុំប្រុសអាយុ២៧ឆ្នាំ ទើបកិនស្រូវរួច មុជទឹករៀបចំហូបបាយ។ ពេលនោះស្រាប់តែឃើញយុវជនពីរនាក់ ដើរមកឈរមុខផ្ទះ ស្រែកហៅថា "ស៊ន១ តោះ! ទៅប្រជុំមួយភ្លែត"។

[១៤:០៩:១៦]

ប្អូនថ្លៃខ្ញុំមិនទាន់ហូបបាយផង ក៏ស្ទុះទៅតាមគេ តាំងពីយប់នោះមក បាត់ដំណឹងសូន្យឈឹងទាល់សព្វថ្ងៃ គួរឲ្យខ្លោចចិត្តណាស់។ ការរស់នៅ និងការហូបចុក បន្ទាប់ពីទៅដល់ស្រុកប្អូនប្រាំថ្ងៃ គ្រួសារខ្ញុំជិតអស់ស្បៀង ក៏រាយការណ៍តាមរយៈប្រធានក្រុម សុំបើកអង្ករហូប។ កាលណោះប្រជាជន១៧មេសា ដែលស្នាក់នៅឃុំពកឫស្សីទាំងអស់ ក៏អស់ស្បៀងដូចគ្រួសារខ្ញុំដែរ ហើយត្រូវខាងពាណិជ្ជគេបើកឲ្យគ្រួសារនាងខ្ញុំប្រាំនាក់ បានបីគីឡូអង្ករ ហើយអង្ករនោះ ធុំក្លិនផ្អូរ ហូបសឹងពុំកើត។ យូរៗគេបើកឲ្យម្ដង បានត្រឹមមួយខែដំបូងប៉ុណ្ណោះ ក្រោយមកមិនបើកឲ្យឡើយ។ គ្រួសារនាងខ្ញុំមានសារុងអាវថ្មី ក្រមា នាឡិកាដៃតាមខ្លួនបានខ្លះ ចេះតែលួចលាក់ដូរអ្នកនៅមូលដ្ឋានគេមានស្រូវអង្ករច្រើន។ ការខ្វះស្បៀងនៃគ្រួសារនាងខ្ញុំកាន់តែយ៉ាប់យឺនទៅបន្តិចម្ដងៗ ដំបូងលាយពោត ឬដំឡូង ក្រោយមកលាយ

ត្រកួន បន្តទៅទៀតបបរវាវក្លូក ទោះយ៉ាងណាខំប្រឹងធ្វើការបម្រើអង្គការដោយអត់ធ្មត់ជាទីបំផុត ដើម្បីសម្រេចផែនការមហាលោតផ្លោះរបស់អង្គការ។ ដល់ខែធ្វើស្រូវបានប្រមូលផលដាក់ជម្រុកទើបគេឲ្យហូបបាយសុទ្ធម្នាក់ពីរខាំមួយពេលប្រហែលមួយខែដំបូង រួចលាយពោតលាយដំឡូងចុងឆ្នាំបបរវាវរហូតនាំឲ្យម្នាក់ៗបាក់កម្លាំងស្ទើរស្លាប់ ស្ទើររស់ ឃើញតែក្បាលជង្គង់។

[១៤:១១:១៧]

ការរស់នៅបម្រើអង្គការ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ដំបូងគេឲ្យទៅច្រូតស្បូវ នាងខ្ញុំគ្មានស្បែកជើងពាក់ទេ បាតជើងមិនទាន់ក្រិន។ ដូច្នេះខ្ញុំមុតជញ្ជាំងស្បូវឈាមរលិស ដើរពុំទាន់គេ ប្រធានក្រុមស្តីឲ្យពីមុខពីក្រោយ គ្មានអាសូរ។ គេដេញថា "នារី១៧មេសា ទន់ជ្រាយ គ្មានចិត្តតស៊ូ"។ ថ្ងៃបន្ទាប់មកទៀត (សូមទោស) ថ្ងៃបន្ទាប់មកទៀត គេឲ្យទៅច្រូតកាត់។ ការនៅលើភក់មិនសូវខ្លាច។ ពេលក្រលេកឃើញឈ្លើងហែលផ្សារពោះខៀវ នាងខ្ញុំរន្ធត់ញាប់ញ័រស្ទើរលោះព្រលឹង ប្រធានក្រុមឃើញគេស្ទុះច្រានខ្ញុំឲ្យចុះទឹក មិនឲ្យឡើងគោកទេ បើប៊ានតែឡើងគេនឹងដាក់វិន័យ។ តើពេលនោះខ្ញុំភ័យប៉ុនណា? សូមលោកអ្នកស្តាប់គិតមើលចុះ ពេលមានផ្ទៃពោះបាន៣ខែ គេឲ្យឃ្វាលគោប្ដូន។ នាងខ្ញុំមិនដែលដឹកគោទេតាំងពីតូចមក ហើយខ្លាចគោបោសណាស់។ ថ្ងៃមួយគោបោសមែន តែសំណាងល្អមានគេជួយទាន់កុំអីគ្រោះថ្នាក់ដល់កូនក្នុងផ្ទៃ។ ក្រោយមកគេឲ្យចិញ្ចឹមជ្រូកសាច់ពីរក្បាល មួយថ្ងៃៗខំដើររកដើមចេកមកហាន់បុកលាយកន្ទក់ ជួនកាលដើរកាត់ត្រកួនមកហាន់មិនឲ្យទំនេរឡើយ រហូតដល់ពេលសម្រាកកូន។ (សូមបញ្ជាក់ថា បើជ្រូកមានជំងឺនឹងមានបញ្ហាដល់ខ្លួននាងខ្ញុំមិនខានឡើយ) ហើយជ្រូកទាំងនោះមិនដែលបានធ្វើឲ្យប្រជាជនហូបទេ មិនដឹងគេយកទៅណានោះឡើយ។

ថ្ងៃមួយប្រធានក្រុមប្រាប់ឲ្យទៅឈ្វូសពោតលាយបាយនៅមន្ទីរ។ កូនខ្ញុំកើតទើបបានពីរខែសរសៃនៅខ្ចីនៅឡើយ ប៉ុន្តែត្រូវតាមបញ្ជាគេដាច់ខាតមិនអាចប្រកែកបានឡើយ។ ហើយការឈ្វូសពីម៉ោងប្រាំពីរព្រឹកដល់ម៉ោងដប់មួយថ្ងៃត្រង់។ កូន៤ខែគេឲ្យជាន់អំបិលទុកប្រឡាក់ត្រីប្រហុកផ្អក។ កូនបាន៦ខែគេឲ្យរែងអង្ករ កូនបានមួយខួបគេឲ្យកិនស្រូវទាញត្បាល់ធំៗវាល់តៅស្រូវប្រណាំងគ្នា ទុកកូនឲ្យនៅនឹងយាយចាស់ៗ គឺគេមិនឲ្យយើងទំនេរនោះទេ ទោះបីយើងមានសរសៃខ្ចីក៏ដោយ។ ជួនកាលគេឲ្យទៅដកស្ទូងពីម៉ោងប្រាំពីរព្រឹកដល់ម៉ោងដប់មួយថ្ងៃត្រង់ទើបឡើងមកឲ្យកូនបៅ រួចចុះស្ទូងវិញ។

[១៤:១៤:៥០]

ម៉ោងដប់មួយថ្ងៃត្រង់ដល់ល្ងាចម៉ោងប្រាំ ថ្ងៃមួយគេឲ្យដាក់បាយជ្រូក។ ប្រធានជ្រូកចិត្តកាចចង់

ធ្វើបាប "គេថាខ្លួនគេរែកពេញប៉ោត នារីឯងម៉េចក៏រែកតែកន្លះអ៊ីចឹង អង្កាល់បានលាយឲ្យស៊ីទាន់វាឃ្លាន បើជ្រូកច្រើនយ៉ាងនេះ?" ថារួចគេស្ទុះមកច្រានខ្ញុំឲ្យដួលលើអាចម៍ជ្រូកស្អុយពេលខ្លួន គួរឲ្យឈឺចាប់ណាស់ដែលកម្លាំងខ្ញុំខ្សោយមិនអាចរែកពេញប៉ោតឡើងច្រាំងទន្លេបាន។ ការឈឺចាប់ផ្លូវចិត្តរងនូវការមើលងាយរើសអើងនៃពួកមូលដ្ឋានចំពោះរូបនាងខ្ញុំជាជន១៧មេសា ព្រមជាមួយរាងកាយទ្រុឌទ្រោមដោយខ្វះសារជាតិអាហារ នាងខ្ញុំស្ទើរទប់ខ្លួនពុំជាប់ ព្រោះបាត់បង់ភាពកក់ក្ដៅ បាត់បង់សេចក្ដីសង្ឃឹមទៅអនាគត។ រីឯប្ដីខ្ញុំកសិករគេឲ្យកាន់គោប្រើមួយនឹម គោមេមួយ។ រាល់ថ្ងៃមកពីភ្ជួររាស់ គាត់តែងហត់ឈរផ្អែកជញ្ជាំងផ្ទះមួយសន្ទុះបាត់ហត់ទើបងូតទឹកទៅការដ្ឋានហូបបាយ។

ឃើញប្ដីបែបនេះនាងខ្ញុំក្ដុកក្ដួលក្នុងចិត្តអាណិតប្ដីណាស់ គេប្រើហួសកម្លាំង ហូបពុំគ្រប់គ្រាន់ ដើមឆ្នាំ១៩៧៨ គេឈប់ឲ្យគាត់កាន់គោទៀតហើយ គេឲ្យទៅរែកដីលើកទំនប់ឆ្ងាយៗយូរៗមកផ្ទះម្ដង។ ប្ដីខ្ញុំជាកូនអ្នកត្រកូល -- ប្ដីខ្ញុំជាកូនត្រកូលអ្នកមាន រាងកាយគាត់ពុំធន់នឹងការងារធ្ងន់ឡើយ គាត់តែងរងការប្រមាថពីអ្នកនៅមូលដ្ឋានជានិច្ច។ ការប្រឹងប្រែងហួសកម្លាំងនេះហើយ ដែលធ្វើឲ្យគាត់មានជំងឺបេះដូងរីក ការនឹករលឹកដល់ឪពុកម្ដាយបងប្អូន អារម្មណ៍ផ្លូវចិត្តដែលនឹករលឹកឪពុកម្ដាយបងប្អូនតាយាយមិនអាចទៅរកពួកគាត់បាន មិនដឹងសុខទុក្ខយ៉ាងណានោះ។ នាងខ្ញុំសែនកន្ទះរាក្នុងជារៀងរាល់យប់ចេះតែគិត ចេះតែឆ្ងល់ថា ហេតុអ្វីបានជារបបនេះធ្វើបាបប្រជាជនមិនឲ្យហូបគ្រប់គ្រាន់ដូច្នេះ? បើផលស្រូវបានរៀងរាល់ឆ្នាំ មិនដែលខូចខាតទេ ពេលប្រជាជនឈឺ ហេតុអ្វីចែកតែថ្នាំអាចម៍ទន្សាយមួយមុខអ៊ីចឹង។

[១៤:១៧:៣៤]

ដូចជាស្អប់ខ្ពើមអ្នកជំងឺ ហើយបោះពាក្យសម្ដីថា "គ្រុនញាក់គ្រុនញ័រ គ្រុនអាត្រាក់ទ័រ គ្រុនសតិអារម្មណ៍" គ្មានគិតប្រជាជនសោះ។ ចំណែកមន្ត្រីរដ្ឋការដូចប្អូនថ្លៃខ្ញុំកំពង់កិនស្រូវមិនទាន់ហូបបាយផងគេយក -- គេមកហៅទៅប្រជុំ ស្រាប់តែបាត់ដំណឹងរហូតមក។ តើពាក្យថា យកទៅរៀនសូត្រនោះពិតជាយកទៅសម្លាប់ដូចពាក្យចចាមអារ៉ាមខ្សឹបខ្សៀវគ្នាមែនឬ? បើពិតជាសម្លាប់ទាហានមន្ត្រីរាជការទាំងអស់មានតើពួកគេមានកំហុសអីដែលត្រូវកាត់ទោសសម្លាប់? មិនគួរឲ្យជឿសោះចុះតើមេដឹកនាំរបបនេះឈ្មោះអីទៅន៎? ហើយគាត់ជាខ្មែរ ឬមិនមែន? សំណួរទាំងអស់នេះវាស្ថិតនៅក្នុងសតិសម្បជញ្ញៈខ្ញុំរៀងរាល់ថ្ងៃ រាល់ពេលសម្រាកពីកិច្ចការខ្ញុំតែងតែគិតវិភាគរកគោលដៅនៃរបបនេះ។ ថ្ងៃ០៧ មករា ១៩៧៩ មកដល់ នាងខ្ញុំសប្បាយរីករាយក្នុងចិត្តខ្លាំងណាស់ គិតថាបានទៅរកឪពុកម្ដាយ តាយាយបងប្អូនបង្កើតបានហើយ។ កាលនោះ ខ្ញុំទើបកើតកូនទី២ បាន៤ខែទេ។ ខ្ញុំនឹងប្ដីក៏សម្រេចចិត្តចាប់មាន់

ប្រាំមួយក្បាលទៅជាមួយ ដើម្បីលក់យកលុយរៀតណាមចាយវាយសម្រាប់ធ្វើដំណើរ។ គិតហើយ ស្អែកចេញដំណើរម៉ោងបួនភ្លឺ ប្តីខ្ញុំជិះកង់ ខ្ញុំអង្គុយឱបកូនពីក្រោយមានបាយកញ្ចប់ហ្នឹងទៅជាមួយផង។ ទៅដល់ស្ទឹងស្លូតបេះដូងខ្ញុំញ័រភ័យ ញាប់ញ័រព្រោះគិតថា តើគ្រួសារទាំងអស់មានអ្នកណាស្លាប់ដែរទេ? បើមានអ្នកណាស្លាប់តើអញក្តុកក្តួលចិត្តប៉ុនណា? ម៉ោងប្រាំមួយល្ងាចថ្ងៃលិចទៅដល់ផ្សារកំពង់សឹង បីកូនដើររកផ្ទះបងស្រីឈ្មោះ ញឹប ពេលនោះគេចង្អុលទៅខាងស្តាំដៃ។

[១៤:១៩:៤៥]

ខ្ញុំក្រលេកភ្នែកទៅឃើញខ្ទមស្លឹកតូចមួយ ខ្ញុំរូតរះចូលទៅភ្លាម។ បងញឹប ដែលត្រូវជាប្អូនថ្លៃបងស្រីខ្ញុំ ក៏ស្ទុះមកឱបខ្ញុំ ហើយយំខ្សឹកខ្សួលប្រាប់ថា ម្តាយខ្ញុំ និងប្អូនៗប្រាំនាក់គេយកទៅសម្លាប់ទាំងអស់គ្នាដោយសារគេចោទថា ម៉ែខ្ញុំ មានមាសច្រើនមិនដាក់សហករណ៍។ ចំណែកឪពុកខ្ញុំឈឺហើមហត់គ្មានថ្នាំព្យាបាលក៏ស្លាប់ទៅ។ ដំណឹងនេះធ្វើឱ្យខ្ញុំបាត់ស្មារតីមួយសន្ទុះធំ។ ពេលដឹងខ្លួនឡើងខ្ញុំចង់ស្លាប់ទៅតាមពួកគាត់ណាស់ ទៅតាម ពួកគាត់ខ្លាំងណាស់។ ប៉ុន្តែសំឡេងកូនយំទាររកបៅវាអង្រួនស្មារតីខ្ញុំឱ្យប្រឹងប្រែងរស់តទៅទៀតដើម្បីកូន ដើម្បីប្តី និងដើម្បីរកយុត្តិធម៌ជូនពួកគាត់។ នាងខ្ញុំសូមបញ្ជាក់ថា ខ្ញុំជាកូនទី៤ ដែលបានរួចខ្លួនរស់ជីវិតតែម្នាក់ឯងគត់ក្នុងត្រកូល ហួ ក្នុងចំណោមបងប្អូនប្រាំបួននាក់។ ឪពុកម្តាយ តា យាយ អ៊ំ ពូ និងក្មួយៗជាទីស្រលាញ់មួយចំនួនទៀតសរុប ២២នាក់។ តាយាយ និងឪពុកនាងខ្ញុំស្លាប់ដោយសារ ជំងឺហើម ហត់ ហូបពុំគ្រប់គ្រាន់គ្មានថ្នាំព្យាបាល។ ឯអ៊ំខ្ញុំនៅអង្គរជ័យស្រុកកៀនស្វាយ ឈ្មោះកុក ប្រពន្ធឈ្មោះ ស គេប្រើឱ្យទៅកាប់ព្រៃជាន់មីនស្លាប់ក្នុងព្រៃចោលកូនប្រុសស្រីបួននាក់ កំព្រាទាល់សព្វថ្ងៃ។

[១៤:២១:៥១]

ចំណែកពូខ្ញុំនៅកអណ្តើក ខេត្តស្វាយរៀង ឈ្មោះ លាង គេប្រើឱ្យធ្វើការហួសកម្លាំង។ ថ្ងៃមួយមានជំងឺរាគគ្មានថ្នាំព្យាបាលក៏ត្រូវស្លាប់យ៉ាងសង្វេគបំផុតចោលកូនប្រុសស្រី ប្រាំមួយនាក់កំព្រាទាល់សព្វថ្ងៃ។

ចំណែកបងប្រុសខ្ញុំឈ្មោះ ហួ ហានី ទាហានអាកាសចរណ៍មុនថ្ងៃ១៧ មេសា ១៩៧៥ គេចាត់ឱ្យរៀនបំពេញនៅប្រទេសថៃ។ បន្ទាប់ពីឮលោក អៀង សារី អំពាវនាវ ឱ្យមន្ត្រីរដ្ឋការនិស្សិត បញ្ញវន្តចូលមករួមគ្នាកសាងប្រទេសឡើងវិញ គាត់ក៏សម្រេចចិត្តចូលមកក្នុងប្រទេសវិញ។ ហ្នឹងមិនទាន់បានជួបមុខប្រពន្ធកូនផងក៏ត្រូវទាហានខ្មែរក្រហមចាប់យកទៅសម្លាប់ទុកកូនបីនាក់កំព្រាទាល់សព្វថ្ងៃ។

ចំណែកបងស្រីខ្ញុំទី២ ឈ្មោះ ហួ ឃីម ប្ដីឈ្មោះ នង គឹមអេង មុនថ្ងៃ១៧ មេសា ១៩៧៥ ពួកគាត់នៅផ្សារក្បាលមាន់ចែ។ បន្ទាប់គេជម្លៀសទៅនៅព្រែកញ្ចៅ ខេត្តព្រៃវែង។ បងស្រីខ្ញុំមានផ្ទៃពោះ ៤ខែ និងកូនបីនាក់ ទៀតព្រមទាំងម្ដាយក្មេក និងអ្នកស្រុកខ្លះទៀតគេឲ្យឈរតម្រៀបជួរហើយគេវាយដងចបសម្លាប់ម្ដងមួយៗសែនខ្លោចផ្សាបំផុត។ ប្ដីវិលពីនេសាទវិញដឹងថាម្ដាយ ប្រពន្ធកូន គេយកទៅសម្លាប់អស់ហើយ ក៏ស្ទុះយកកាំបិតជំពុះទង់មុតស្រួចរត់រកឃាតករ ហើយស្រែកថា អាណាសម្លាប់ម្ដាយ កូនប្រពន្ធអញ ចេញមុខមក? ពេលនោះឃាតករបាតដៃប្រលាក់ឈាមក៏បង្ហាញខ្លួន បួនទៅប្រាំនាក់ ឆាកប្រយុទ្ធស៊ីសាច់ហុតឈាមយ៉ាងសាហាវបំផុត។ បងថ្លៃខ្ញុំគួរឲ្យអាសូរណាស់។ ពេលនោះគាត់ត្រូវខ្មែរក្រហម កាប់សម្លាប់ក្នុងថ្លុកឈាមយ៉ាងអណោចអធ័មក្រៃលែង។ ទីបំផុត គាត់បិទភ្នែកលាលោក លារបបព្រៃផ្សៃមិនអាលោះអាល័យឡើយ។

[១៤:២៤:៣២]

ចំណែកបងប្រុសទី៣ ឈ្មោះ ហួ លីម ប្រពន្ធឈ្មោះស្រីមុំ មុន ១៧ មេសា ឆ្នាំ៧៥ គាត់ធ្វើគ្រូបង្រៀននៅភ្នំពេញ។ ថ្ងៃ១៧ មេសា ឆ្នាំ៧៥ គ្រួសាររបស់គាត់ត្រូវជម្លៀសទៅកោះអន្លង់ចិន តាខ្មៅ។ បន្ទាប់ពីគេចោទថាគាត់មានរបស់មានតម្លៃមិនដាក់រួមគេក៏យកគាត់ទៅគាស់ គល់ឈើនៅកន្លែងមួយ។ បងស្រីមុំជាប្រពន្ធបន្ទាប់ពីដឹងថ្ងៃនេះ គេយកប្ដីទៅសម្លាប់ហើយ ក៏ម្នីម្នានាំកូនប្រុសស្រីបួននាក់ទៅរកឪពុក ហើយសំពះសុំកុំឲ្យគេសម្លាប់ប្ដីគាត់។ សូមអាសូរកូនទាំងបួននាក់ផង។ ប៉ុន្តែគេគ្មានមេត្តា គេគ្មានមនោសញ្ចេតនាទេ រឹតតែសាហាវចាប់សម្លាប់ទាំងម្ដាយ ទាំងកូន ទាំងឪពុកស្លាប់ក្នុងថ្លុកឈាមតែមួយ។ ស្លាប់ចុះខ្មែរអើយ! សាហាវជាងសត្វតិរច្ឆាន។ ចំណែកម៉ែខ្ញុំ ចំណែកម្ដាយខ្ញុំ គេចោទថាមានមាស មិនដាក់សហករណ៍។ មានមាសច្រើនមិនដាក់សហករណ៍។ គេយកទៅដាក់គុកនៅទួលអង្គ ខាងជើងផ្សារកំពង់សឹង ប្រហែលមួយគីឡូម៉ែត្រ។

[១៤:២៦:០០]

ម្ដាយខ្ញុំឃ្លានបាយពេកក៏លួចចេញពីគុក រត់សំដៅផ្ទះអ្នកស្រុករកបាយហូប។ ពេលនោះ ប្អូនៗខ្ញុំទាំងប្រាំនាក់ នឹកម៉ែពេក ក៏រត់តាមរកម៉ែ កងឃាមគុកឃើញ ក៏ចាប់ប្រមូលទៅស្លាប់ទាំងអស់។ ទាំងអស់ប្រាំមួយនាក់ ស្លាប់ក្នុងថ្លុកឈាមតែមួយ។ សែនរន្ធត់ចិត្ត និងខ្លោចផ្សាបំផុត រកពាក្យថ្លាថ្លែងពុំបាន។ តើមេដឹកនាំជាអ្នកណា? ហេតុអ្វីគេបណ្ដាលឲ្យខ្មែរស្លាប់ខ្មែរបែបនេះ?

ការអស់សង្ឃឹមក្នុងជីវិត ចាប់តាំងពីខ្ញុំដឹងថាខ្លួនត្រូវបាត់បង់ឪពុកម្ដាយ បងប្អូនអស់រលីង នាងខ្ញុំ

មើលអ្វីៗជុំវិញខ្លួនហាក់ដូចជាក្រៀមក្រំ អស់ន័យសម្រាប់ជីវិត។ ប៉ុន្តែនាងខ្ញុំនៅសង្ឃឹមប្តី និងកូនពីរនាក់ដែលផ្តល់កម្លាំងចិត្តឲ្យខ្ញុំចង់រស់តទៅទៀត។ មិនយូរប៉ុន្មាន ប្តីខ្ញុំដែលមានជំងឺរ៉ាំរ៉ៃដោយសាររបបខ្មែរក្រហមប្រើឲ្យធ្វើការហួសកម្លាំង ក៏គាត់តែធ្វើទុក្ខខ្លាំងឡើង ខ្ញុំក៏នាំទៅពិនិត្យនៅមន្ទីរពេទ្យចិន។ ដុកទ័រប្រាប់ថា ប្តីខ្ញុំមានជំងឺបេះដូងរីក។ ពេលនោះ ខ្ញុំអស់សង្ឃឹមស្ទើរលែងចង់រស់។ ហើយក៏នឹកឃើញឈឺចាប់នឹងរបបព្រៃផ្សៃនេះដែលបង្កឲ្យគាត់មានជំងឺបែបនេះ។ ត្រង់ចំណុចខ្ញុំសូមបញ្ជាក់ថា ប្តីខ្ញុំគាត់ខំបង្រៀនផង ទៅពេទ្យព្យាបាលផង។ ចំណែកនាងខ្ញុំខំដេរខោអាវផង ចិញ្ចឹមជ្រូកមាន់ទាផង រួមផ្សំយកលុយទៅព្យាបាល។ ទីបំផុតគាត់នៅតែស្លាប់ចោលខ្ញុំនៅឆ្នាំ១៩៩៥។ អំឡុងពេល៧៩ មក ១៩៩៥ នាងខ្ញុំមានកូនបីនាក់ទៀត។ ញាតិអើយពិចារណាមើល តើស្ត្រីមេម៉ាយម្នាក់មានកូនប្រាំនាក់ បងគេអាយុ១៨ឆ្នាំ មានបញ្ហាសតិអារម្មណ៍រៀនលែងចូល ព្រោះឪពុកងាកឈឺៗ រួចស្លាប់ចោលទៀត។ ប្អូនពៅអាយុ៥ខែ មានជំងឺសួតប្រចាំកាយ ត្រូវទៅពេទ្យញឹកញាប់សឹងរាល់ខែ។

[១៤:២៩:៣២]

ក្បួនជីវិតគ្រួសារខ្ញុំត្រូវព្យុះសង្ឃរាបោកបក់កណ្តាលសាគរឥតកោះត្រើយ។ មិនដែលស្គាល់ការសប្បាយរីករាយឡើយ។ ពេលនាងខ្ញុំជួបឧបសគ្គធំៗមិនមានឪពុកម្តាយជួយដោះស្រាយ។ មិនមានបងប្អូនជួយរំលែកទុក្ខ បាត់បង់ភាពកក់ក្តៅ។ ពេលនោះអារម្មណ៍ពុំកញ្ច្រោលរោលរែក បេះដូងឈឺចាប់នឹងរបបចង្រៃអន្យតិរ្ថិយនេះខ្លាំងណាស់។ ព្រោះតែរបបនេះ គ្រួសារអញត្រូវវិនាសអន្តរាយទាំងពូជ ថែមទាំងបន្តទុក្ខវេទនាដល់កូនៗទាំងប្រាំនាក់ទៀត ឲ្យមានជីវិតឯកកោអនាថាទាល់សព្វថ្ងៃ។ ឯរូបខ្ញុំផ្ទាល់សព្វថ្ងៃមានជំងឺសរសៃប្រសាទលើសឈាម ដោយសារនាងខ្ញុំជួបនូវហេតុការណ៍ភ័យរន្ធត់តក់ស្លុតច្រើនលើកច្រើនសាបណ្តាលពីរបបឃោរឃៅនេះ។ នាងខ្ញុំខំដេរខោអាវ លក់ដូរ ចិញ្ចឹមជូនមាន់ទា ដើម្បីដោះស្រាយជីវភាពដល់លំបាកបំផុត។ ទូលផង រែកផង ទម្រាំទ្រទ្រង់គ្រួសារបាន ហើយបានមកឈរនៅទីនេះ ថ្ងៃនេះ ដើម្បីរកយុត្តិធម៌ជូនឪពុកម្តាយ បងប្អូន តាយាយ អ៊ំពូខ្ញុំ។

[១៤:៣១:០៦]

ថ្ងៃនេះ ខ្ញុំរំភើបចិត្តឥតឧបមាដោយបានតុលាការអន្តរជាតិហោះហើរឆ្លងសមុទ្រមករកយុត្តិធម៌ជូនពួកគាត់ និងជនរួមជាតិទាំងអស់ដែលស្លាប់យ៉ាងអយុត្តិធម៌ក្នុងរបបព្រៃផ្សៃឃោរឃៅ ហើយថ្ងៃនេះផងដែរ ជាថ្ងៃដែលខ្ញុំរង់ចាំ៣០ឆ្នាំហើយ ដោយចិត្តអន្ទះរា ហើយថ្ងៃនេះ ពេលនេះ កូនសូមអញ្ជើញព្រលឹងប៉ាម៉ែ តាយាយ អ៊ំពូ បងប្អូន ក្មួយៗទាំង២២នាក់ ព្រមទាំងព្រលឹងអ្នកស្លាប់ទាំងអស់ក្នុងរបប

កម្ពុជាប្រជាធិបតេយ្យមកស្ថិតនៅទីនេះ ដើម្បីស្តាប់តុលាការ បង្ហាញមុខមេខ្លោងឃាតករ ហើយរកយុត្តិធម៌ជូនអ្នកទាំងអស់ ហើយមើលមុខឲ្យជាក់ដើម្បីជម្រះបញ្ជីនៅឋានយមរាជ។

តុលាការជាទីគោរព នាងខ្ញុំសំណូមពរ លោក លោកស្រី ដែលជាតុលាការអន្តរជាតិមេត្តាកាត់ក្តីឲ្យសុក្រឹត យុត្តិធម៌ សមនឹងទម្ងន់ទោសឧក្រិដ្ឋដែលពួកគេបានប្រព្រឹត្តប្រមាថមនុស្សជាតិដោយធ្វើទារុណកម្មសាហាវព្រៃផ្សៃបំផុត។ ការបាត់បង់ជីវិតដោយអំពើឃោឃៅយ៉ាងអយុត្តិធម៌នៃគ្រួសារខ្ញុំមិនអាចមានអ្វីមកប៉ះប៉ូវបានឡើយ ទោះមាសប៉ុនល្អី ក៏ខ្ញុំមិនដូរនឹងជីវិតម្តាយខ្ញុំម្នាក់ដែរ។ កុំថាដល់ទៅជីវិតទាំង២២នាក់ ប៉ុន្តែពួកអ្នកពាក់ព័ន្ធនឹងប្រព្រឹត្តផ្ទាល់ក្នុងរឿងសម្លាប់គ្រួសារនាងខ្ញុំនឹងទទួលកម្មពារធ្ងន់ធ្ងរវេទនាបំផុតគ្រប់ៗជាតិ ដរាបរៀងទៅរយពាន់ម៉ឺនជាតិ។ មិនអាចកើតជាមនុស្សបានឡើយ។ នាងខ្ញុំសូមធ្វើសំណូមពរដល់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យទាំងពីររូប រូបលោកមានអាយុច្រើនចាស់ៗអស់ហើយ នេះជាឱកាសចុងក្រោយនៃជីវិតពួកលោក។ ដូច្នេះពួកលោកត្រូវតែក្លាហានប្រមូលស្មារតីបំភ្លឺនូវការពិតជូនរងគ្រោះទាំងអស់ និងដើមបណ្តឹងរដ្ឋប្បវេណីកំពុងស្រេកឃ្លានយុត្តិធម៌ និងចង់ដឹងការពិតដែលរបបពួកលោកដាច់ចិត្តសម្លាប់មនុស្សរង្គាលបែបនេះ។

[១៤:៣៣:៥៥]

នាងខ្ញុំសូមអំពាវនាវហើយអំពាវនាវទៀត ដល់បណ្តាអង្គការស្ថាប័នគ្រប់ប្រទេសលើពិភពលោក និងសប្បុរសជនទាំងឡាយមេត្តាជួយផ្តល់ជំនួយដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលជាជនរងគ្រោះឲ្យបានសមរម្យ និងការបាត់បង់ដ៏ធំធេង ដើម្បីផ្សះផ្សាផ្លូវដែលខ្ទេចខ្ទាំទាំងសុខភាពផ្លូវកាយ ព្រោះយើងខ្ញុំទាំងអស់គ្នាមានវ័យចាស់ៗអស់ហើយ កំពុងរោគាព្យាធិមកបៀបបៀនរាល់ថ្ងៃ។

នៅទីបញ្ចប់នាងខ្ញុំ តំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីស្រុកខ្សាច់កណ្តាល ស្រុកមុខកំពូល វិហារសួគ៌ សូមធ្វើសំណូមពរចុងក្រោយ។ សូមតុលាការកូនកាត់ដែលជាតុលាការខ្មាតអន្តរជាតិ ដែលខំចំណាយថវិកាដ៏ច្រើនលើសលប់ ដើម្បីរកយុត្តិធម៌ជូនជនរងគ្រោះកម្ពុជា មេត្តាស៊ើបអង្កេតនូវទ្រព្យសម្បត្តិដែល -- ទាំងអស់ក្នុងនិងក្រៅប្រទេសរបស់ជនជាប់ចោទ ដែលតុលារកឃើញប្រាកដថា គេទោសឧក្រិដ្ឋមែននោះ ក្នុងការសងសំណងដល់ជនរងគ្រោះទាំងអស់ ដើម្បីផ្សះផ្សាផ្លូវចិត្តដែលខ្ទេចខ្ទាំជាង៣០ឆ្នាំហើយ។ សាលាក្តីមិនអាចចប់ដោយបរាជ័យទេ ត្រូវតែពុះពារផ្តល់យុត្តិធម៌ជនរងគ្រោះឲ្យស្ងប់ចិត្តផង។

ជាចុងក្រោយនាងខ្ញុំសូមអនុញ្ញាតសួរនូវសំណួរចុងចោទបីសំណួរ។ លោកប្រធានសូមអនុញ្ញាត។

[១៤:៣៥:០០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតលោកស្រីតាំងសំណួរតាមរយៈប្រធានអង្គជំនុំជម្រះ គឺតាមរយៈរូបយើងនេះ គឺមិនអាចសួរគេផ្ទាល់បានទេ។ តាមនីតិវិធីតម្រូវឲ្យលោកស្រីសួរតាមរយៈប្រធានអង្គជំនុំជម្រះ។ សូមអញ្ជើញ!

**លោកស្រី ហួ ចន្ថា៖**

សំណួរទី១ ជូនជនជាប់ចោទទាំងពីរ ខ្ញុំចង់ដឹងថា ម៉ែខ្ញុំ បងប្រុសខ្ញុំមានមាសមិនដាក់សហករណ៍ តើច្បាប់ក្នុងរបបលោកកាត់ទោសប្រហារជីវិតទាំងគ្រួសារដូច្នេះឬ?

សំណួរទី២ លោកទាំងពីរ ក្នុងរបប៣ឆ្នាំ ៨ខែ ២០ថ្ងៃរបស់លោក រៀងរាល់រាត្រីដែលលោកកំពុងដេកឱបប្រពន្ធក្នុងម៉ាស៊ីនត្រជាក់ កង្ហារបក់បោយសោយសុខក្រោមដំបូលវិមានដ៏ស្កឹមស្កៃ តើលោកមានដែលស្រមៃឃើញប្រជាជនខ្មែរកំពុងស្រែកថ្ងូរក្នុងថ្លុកឈាម ដោយសួរធម្មជាតិថា តើខ្ញុំខុសអីបានគេសម្លាប់ខ្ញុំ? ជួយរកយុត្តិធម៌ឲ្យខ្ញុំផង? រំពងព្រៃប្រឹក្សា តើលោកមានដែលស្រមៃម្តងណាទេ?

សំណួរទី៣ លោកទាំងពីរ លោកព្យាយាមឆ្លើយព្រឹកមិញហ្នឹង លោកព្យាយាមឆ្លើយថា លោកមិនបានដឹងពីការកាប់សម្លាប់មនុស្សជាច្រើនក្នុងរបបនេះទេ។ តើលោកមានខ្មាសក្មេងជំនាន់ក្រោយដែរទេ ដែលលោកជាមេដឹកនាំកំពូលមិនបានដឹងអ្វីនោះ? សូមចប់។

[១៤:៣៧:៤៤]

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី ចន្ថា អង្គជំនុំជម្រះសូមជូននូវសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីសំណួរនេះជូនទៅលោកជនជាប់ចោទ។ ទី១ គឺលោក ខៀវ សំផន លោកឆ្លើយតបទៅនឹងសំណួរដែលសួរដោយដើមបណ្តឹងរដ្ឋប្បវេណីអម្បាញ់មិញនេះ ទាំងបីសំណួរ។ បាទ សូមអញ្ជើញ!

**លោក ខៀវ សំផន៖**

សូមជម្រាបសួរលោកប្រធាន និងអស់លោក លោកស្រីចៅក្រមទាំងអស់។ សូមគោរពអង្គសនាការ។ សូមជម្រាបសួរលោកស្រី ហួ ចន្ថា។ ខ្ញុំស្តាប់លោកស្រីមានប្រសាសន៍ ខ្ញុំក៏រន្ធត់ចិត្តណាស់ក៏ដូចជាភាគីដើមបណ្តឹងរដ្ឋប្បវេណីមុនៗ ប៉ុន្តែខ្ញុំសូមជម្រាបលោកស្រីថា ខ្ញុំមិនមែនជាអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យទេ ហើយខ្ញុំមិនយល់ហេតុអ្វីបានជារឿងអីចឹងៗវាកើតឡើង ដែលកើតនោះ។ មុននឹង

ឆ្លើយសំណួរហ្នឹង ខ្ញុំសូមជម្រាបលោកស្រីប៉ុណ្ណឹង។ ឯខ្ញុំឡើងមកធ្វើប្រមុខរដ្ឋ យើងនិយាយដោយងាយៗ អ៊ីចឹងចុះ គឺឡើងមកធ្វើជំនួសសម្ដេច នរោត្តម សីហនុ ដែលលោកជាប្រមុខរដ្ឋពីមុនខ្ញុំ។ សម្ដេច សីហនុ ពីមុនខ្ញុំ ក៏លោកអត់មានសិទ្ធិអំណាចអីខាងនីតិប្រតិបត្តិ។ ឯខ្ញុំក៏អត់ខុសពីសម្ដេច សីហនុ ដែរ។សូម ជម្រាបលោកស្រីជ្រាបប៉ុណ្ណឹង។

ឥឡូវសូមឆ្លើយនឹងសំណួររបស់លោកស្រីម្ដងមួយៗ។ តើម្ដាយលោកស្រី បងប្រុសលោកស្រី មានមាសមិនដាក់សហករណ៍ តើច្បាប់ក្នុងរបបលោកត្រូវកាត់ទោសប្រហារជីវិតទាំងគ្រួសារដូច្នេះឬទេ? ខ្ញុំក៏យល់ថាមិនត្រូវទេ។ គេត្រូវការតែ ដូចខ្ញុំបានជម្រាប ដូចជាមធ្យោបាយផលិតផល ដូចជាដីស្រែ ចម្ការ រោងចក្រអី គេយកមកធ្វើជាដាក់រួមដើម្បីកសាងប្រទេសឲ្យបានលឿន។ អានេះខ្ញុំ តាមដែលខ្ញុំ ធ្លាប់ឮគេនិយាយ គេនិយាយអ៊ីចឹង ក្នុងពេលប្រជុំមជ្ឈិមម្ដងៗ។ ហើយវាបែរទៅជារឿងមាស រឹបអូស យកមាសពេជ្រអីផ្ទាល់ខ្លួនរបស់របរដែលត្រូវការប្រើប្រាស់ផ្ទាល់ខ្លួនទៅវិញ ខ្ញុំក៏មិនយល់ដែរលោកស្រី។ សូមលោកស្រីអធ្យាស្រ័យ។ នេះចំពោះសំណួរទី១។

[១៤:៤២:០៦]

សំណួរទី២ ខ្ញុំសូមជម្រាបលោកស្រីថា ខ្ញុំគ្មានវិមានស្កឹមស្កៃអីទេ ទៅមើលចុះនៅប៉ៃលិន ហើយ ទៅសួរចុះ តើប្រពន្ធខ្ញុំហើយនិងខ្ញុំរស់នៅយ៉ាងម៉េច? ប៉ុន្តែរឿងហ្នឹងវាមិនជារឿងធំដុំអីទេ គ្រាន់តែ ជម្រាបអ៊ីចឹង។ គ្រាន់តែលោកស្រីបានលើកឡើងថា ធ្វើដឹកនាំហើយ ចេះតែថាមិនដឹងៗ មិនខ្មាស់ក្មេងៗ ជំនាន់ក្រោយទេអី? រឿងហ្នឹងដូចខ្ញុំបានជម្រាបលោកស្រីហើយ ខ្ញុំវាអត់ដឹងមែន។ ប្រមុខរដ្ឋគ្មានសិទ្ធិ អំណាចខាងនីតិប្រតិបត្តិទេ គ្រាន់តែជាតំណាងឲ្យប្រទេសកម្ពុជាមួយដែលឯករាជ្យ អធិបតេយ្យតែ ប៉ុណ្ណឹង។

ឥឡូវនិយាយរឿងមួយទៀតចុះ អំពីថាខ្ញុំជាសមាជិកមជ្ឈិម។ សមាជិកត្រៀមរហូតមកដល់ឆ្នាំ ៧០ ចុងឆ្នាំ៧៥ ដើមឆ្នាំ៧៦ បានពេញសិទ្ធិ។ ពិតមែនតែនៅក្នុងលក្ខន្តិកៈគេសរសេរថា “គណៈមជ្ឈិម គណៈកម្មាធិការមជ្ឈិមជាអង្គការកំពូលនៃបក្សទាំងមូល” គេសរសេរអ៊ីចឹងមែននៅក្នុងលក្ខន្តិកៈ ក៏ប៉ុន្តែ នៅក្នុងការពិតជាក់ស្ដែង ខ្ញុំសូមបញ្ជាក់ហើយបញ្ជាក់ទៀត ជូនលោកស្រី ជូនបងប្អូនរួមជាតិ ក៏ដូចជា ជូនទៅអង្គសវនាការទាំងមូល។ អានេះគ្រាន់តែនៅលើក្រដាសទេ ឯការពិតនៅក្នុងលក្ខន្តិកៈនោះក៏មាន និយាយដែរមជ្ឈិមប្រជុំតែពីរដងទេក្នុងមួយឆ្នាំ។ អានេះទី១។

[១៤:៤៤:៣៨]

ទី២ សមាជិកមជ្ឈិមគេផ្សេងទៀតទាំងអស់ គេទទួលខុសត្រូវខាងមូលដ្ឋាន ខាងភូមិភាគ ខាងតំបន់។ មានតែខ្ញុំម្នាក់ឯងទេដែលអត់ទទួលខុសត្រូវខាងមូលដ្ឋាន ភូមិភាគ តំបន់ ឬអង្គភាពអីដ៏តូចមួយក៏គ្មានសោះ។ គឺខ្ញុំគ្រាន់តែទទួលទាក់ទងឲ្យបានល្អ បន្តទាក់ទងឲ្យបានល្អជាមួយសម្តេចតទៅទៀត។ ហើយចែកចាយអីវ៉ាន់ អីវ៉ែអីវ៉ាន់ទៅភូមិភាគតំបន់តាមការស្នើសុំរបស់គេ ហើយតាមការអនុម័តរបស់គណៈអចិន្ត្រៃយ៍។ ដូច្នេះវាច្បាស់លាស់ណាស់ហើយថា ខ្ញុំពុំអាចដឹងនូវអ្វីៗដល់ខ្មោចផ្សាដែលកើតមានដូចលោកស្រីបានមានប្រសាសន៍អម្បាញ់មិញនេះទេ។ ហើយជា -- ម្យ៉ាងទៀត ខ្ញុំបានចូលរួមប្រជុំគណៈអចិន្ត្រៃយ៍ដែរ។ ខ្ញុំចូលរួមគណៈអចិន្ត្រៃយ៍មែន ពីព្រោះក្នុងឋានៈខ្ញុំជាប្រមុខរដ្ឋ។ ខ្ញុំត្រូវការទាក់ទងប្រទេសជាមិត្តដែលគេមក គឺមិត្ត ឬក៏ប្រមុខរដ្ឋជាមិត្តដែលគេមក ខ្ញុំត្រូវដឹងរឿងខ្លះពីរឿងការរីកចម្រើនរបស់ប្រទេសយ៉ាងនេះយ៉ាងនោះ។ ដូច្នេះគេហៅខ្ញុំប្រជុំអីចឹងមែន គេហៅថា ប្រជុំបើកទូលាយគណៈអចិន្ត្រៃយ៍ បើកទូលាយឲ្យអ្នកដែលមិនមែនជាសមាជិក។ ប៉ុន្តែខ្ញុំគ្មានសិទ្ធិសម្រេច ហើយគេប្រជុំពេលខ្លះគេអត់ឲ្យខ្ញុំដឹងទេ។ ពេលជាច្រើនគេអត់ឲ្យខ្ញុំដឹងទេ អាពីរឿងចាប់ចងស្អីៗគេអត់ឲ្យខ្ញុំដឹងទេ ហ្នឹង។ ដូច្នេះខ្ញុំចង់ជម្រាបថា ម៉េចក៏ខ្ញុំចេះតែទន្ទេញថាមិនដឹងៗ តាមពិតខ្ញុំមិនដឹងធ្វើម៉េច ខ្ញុំមិនដឹងមែននោះ។ សូមលោកស្រីជួយពិចារណាមើលចុះ ហើយបងប្អូនជនរួមជាតិក៏ជួយពិចារណាមើលចុះ។

[១៤:៤៧:១៨]

អំពីសំណួរទី៣ អំពីគំនុំវណ្ណៈ។ ខ្ញុំសូមជម្រាបថា ខ្ញុំក៏ត្រូវគេកសាងដែរ ក្នុងការប្រជុំមជ្ឈិមម្តងៗគេប្រជុំ គេឲ្យធ្វើទិតៀន ស្វ័យតិទៀន កសាង ដើម្បីកសាងគោលជំហរវណ្ណៈ គំនុំវណ្ណៈ កុំឲ្យរក្សាគោលជំហរអនុធនដូចដែលខ្លួនឯងហ្នឹងធ្លាប់បានទៅរៀនដល់ទៅទីក្រុងប៉ារីស ប៉ុន្តែខ្ញុំក៏ចេះតែខំដែរ។ ខ្ញុំប្រាប់គេថាខ្ញុំខំដែរ តែខ្ញុំធ្វើម៉េចធាតុខ្ញុំអីចឹង ដូចលោកតា – លោក នួន ជា មានប្រសាសន៍គឺថា គេកសាងធាតុគេមិនសម្លាប់មនុស្សទេ។ ខ្ញុំគេអត់ស្លាប់មែន ប៉ុន្តែខ្ញុំគេកសាងធាតុខ្ញុំ កសាងមិនបាន នៅតែធាតុអនុធនមិនដឹងធ្វើម៉េចបើវាអីចឹងទៅហើយ។ ហ្នឹងណ៎ះខ្ញុំសូមជម្រាបឲ្យអស់ទៅចុះ។ សូមលោកស្រីអធ្យាស្រ័យអត់ទោសឲ្យខ្ញុំផង ពិតរឿងទាំងអស់ខ្ញុំមិនមែនជាអ្នកសម្រេចទេ។ ខ្ញុំគ្មានសិទ្ធិសម្រេចទេ ហើយរឿងណាគេឲ្យដឹងរឿងអីគេមិនឲ្យដឹង។ អាហ្នឹងវានៅលើគេទេ។ សូម ដូចជាសូមអស់ហើយលោកស្រី។ សូមអធ្យាស្រ័យម្តងទៀត។ សូមអស់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ខៀវ សំផន។ ជាបន្តអង្គជំនុំជម្រះបញ្ជូននៅសំណួររបស់ដើមបណ្តឹងរដ្ឋ

ប្បវេណីចំនួនបីសំណួរអម្បាញ់មិញនេះជូនទៅជនជាប់ចោទ នួន ជា សូមលោកឆ្លើយតបទៅនឹងសំណួរដែលបានសួរឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីរូបនេះចំនួនបីសំណួរ។ សូមអញ្ជើញលោក នួន ជា!

[១៤:៤៩:៤២]

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ។ សូមគោរពលោកប្រធាន សូមជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមេធាវីរបស់ការពារលោក នួន ជា។ ដោយព្រឹកមិញលោក នួន ជា គាត់បានឆ្លើយទៅដើមបណ្តឹងរដ្ឋប្បវេណីពីរនាក់។ មកដល់ពេលនេះគាត់មានសុខភាពធ្វើឲ្យគាត់វិលមុខឈឺក្បាល ហើយនិងគិតអីមិនចេញ។ ម្ល៉ោះហើយគាត់មិនបានពិចារណាក្នុងរឿងអ្នកស្រីបានចោទប្រកាន់គាត់ច្បាស់លាស់ទេ។ គាត់បានប្រាប់មកថាគាត់សុំសិទ្ធិនឹងមិនឆ្លើយនៅពេលនេះ។ ពេលណាដែលគាត់មានសុខភាពល្អ ហើយពិចារណាបានល្អត្រឹមត្រូវគាត់នឹងឆ្លើយឡើងវិញ។ សូមអរគុណ។

[១៤:៥០:៣២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៥០:៥៤]

**ប្រធានអង្គជំនុំ៖**

ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក ឃីត វេយ៍ន័រ៖**

លោកប្រធានសូមអរគុណច្រើន។ យើងខ្ញុំពុំមានសំណួរសួរនោះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក សុន អរុណ៖**

ចំពោះក្រុមមេធាវីការពារលោក នួន ជា ពុំមានសំណួរទៅសាក្សីនេះទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាចុងក្រោយអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន បាទ។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការ ក្នុងនាមលោក ខៀវ សំផន និងក្រុមមេធាវីការពារយើងខ្ញុំអត់មានសំណួរសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទេ។ សូមអរគុណ។

[១៤:៥១:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយមន្ត្រីរដ្ឋបាលតុលាការយ៉ាងម៉េចទៅអំពីការរៀបចំនូវប្រព័ន្ធសោតទស្សន៍ទំនាក់ទំនងរវាងប្រទេសបារាំង និង អ.វ.ត.ក យើងនេះសម្រាប់សាក្សីដែលយើងបានផ្អាកអម្បាញ់មិញនេះ។

អរគុណលោកស្រី ហូ ចន្ថា នូវការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនាស្ថានភាពផលប៉ះពាល់ និងសក្ខីកម្មរបស់លោកស្រីរហូតដល់ពេលនេះបានចប់ហើយ។ វត្តមានរបស់លោកស្រីនៅអ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មរបស់លោកស្រី និងអាចរួមវិភាគទាននៅក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ លោកស្រីអាចវិលត្រឡប់ទៅវិញបានហើយ។ សូមលោកស្រីមានសុខភាពល្អ ជួបតែសំណាងល្អ និងបានសេចក្តីសុខ សុភមង្គល។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកស្រី ហូ ចន្ថា វិលត្រឡប់ទៅកាន់ទីកន្លែងជាគោលដៅដែលគាត់មានបំណងចង់ទៅ ឬទៅកាន់លំនៅដ្ឋានរបស់គាត់វិញបានហើយ។ ហើយអង្គជំនុំជម្រះក៏សូមជម្រាបដែរថា នៅរសៀលនេះអង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនាព្យសនកម្ម និងផលប៉ះពាល់របស់ដើមបណ្តឹងរដ្ឋប្បវេណីអម្បាញ់មិញនេះដែលពីប្រទេសបារាំងតាមរយៈមធ្យោបាយសោតទស្សន៍ដែលមិញមានការរអាក់រអួល។ ប៉ុន្តែតាមព័ត៌មានចុងក្រោយអំបាញ់មិញនេះថាបានដំណើរការល្អវិញហើយ។ ប៉ុន្តែទន្ទឹមនឹងនេះយើងដល់ពេលសម្រាកហើយដែរ។ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាក ១៥នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការ

សវនាការ។ សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៥៤ នាទី ដល់ម៉ោង ១៥:១០ នាទី)*

[១៥:១៥:២០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសកិច្ចដំណើរការនីតិវិធីសវនាការប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តទៅនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់នូវសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណី ផេង អេងលី តាមប្រព័ន្ធសោតទស្សន៍ពីប្រទេសបារាំង។ សួស្តីលោកស្រី ផេង អេងលី!

**លោកស្រី ផេង អេងលី៖**

ចាស ជម្រាបសួរ។

**ប្រធានអង្គជំនុំ៖**

លោកស្រី ផេង អេងលី ឥឡូវប្រព័ន្ធទំនាក់ទំនងតាមមធ្យោបាយសោតទស្សន៍បានដំណើរវិញហើយ។ ហើយមុននឹងផ្តល់វេទិកាជូនទៅលោកស្រី អង្គជំនុំជម្រះសូមរំឭកជូនលោកស្រីបញ្ហាមួយចំនួន៖ ទី១ លោកស្រី សូមនិយាយឲ្យបានយឺតៗដើម្បីបង្កលក្ខណៈងាយស្រួល ហើយនិងលទ្ធភាពឲ្យអ្នកបកប្រែភាសាបកប្រែភាសាទៅជាភាសាបរទេស មានភាសាបារាំង និងភាសាអង់គ្លេសបានល្អ។ ទី២ ករណីឆ្លើយតបទៅនឹងសំណួរនានា សូមលោកស្រីស្តាប់សំណួររួចសិន ហើយសឹមបង្អង់បន្តិចមុននឹងឆ្លើយដើម្បីសម្រួលដល់ការបកប្រែភាសាដែលប្រើប្រាស់នៅ អ.វ.ត.ក នេះបានល្អ បានចប់សព្វគ្រប់។ ហើយបញ្ហាចុងក្រោយ អង្គជំនុំជម្រះសូមរំឭកដល់លោកស្រីថាអង្គជំនុំជម្រះសូមឲ្យលោកស្រីចាប់ផ្តើមសាជាថ្មីឡើងវិញក្នុងការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា ព្យសនកម្ម ឬផលប៉ះពាល់ទាំងឡាយដែលលោកស្រីបានទទួលរក ដោយរកស្រីថ្លែងរៀបរាប់នូវរាល់អ្វីដែលលោកស្រីបានជួបប្រទះនៅការលំបាកឬក៏ព្យសនកម្មដែលកើតមាននៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យពីថ្ងៃ១៧ មេសា ៧៥ ដល់ថ្ងៃ០៦ មករា ៧៩ ដោយលោកស្រីចាត់ទុកថា អ្នកចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនាពេលនេះ មិនដឹងអំពីព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលលោកស្រីបានជួបប្រទះក្នុងឆាកជីវិតរបស់លោកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ។ សូមអញ្ជើញលោកស្រី!

[១៥:១៧:៤៥]

**លោកស្រី ផេង អេងលី៖**

ចាស ជាបឋមសូមអរគុណលោកប្រធាន និងអស់លោកទាំងអស់ដែលឲ្យខ្ញុំមានសម្ដីនៅក្នុងពេលនេះ។ រយៈជាង៣០ឆ្នាំកន្លងផុតមកហើយ ការរស់នៅរបស់ខ្ញុំ ខ្ញុំមិនអាចភ្លេចបាននូវការរស់នៅជំនាន់ របបខ្មែរក្រហមដែលធ្វើទារុណកម្មចំពោះប្រជាជនខ្មែរជាង២លាននាក់ មានរូបខ្ញុំជាដើម។ ពេលចេញថ្ងៃ១៧ មេសា ខ្ញុំឃើញទិដ្ឋភាពដែលគួរឲ្យ ដែលខ្ញុំមិនអាចបំភ្លេចបាន ហើយជាភាពឃោឃៅយង់ឃ្នងដែលមនុស្សលោកទាំងមូលមិននឹកស្មានដល់ គឺការហែកទារកដែលគ្នាឃ្លានបៅ ហើយដែលគ្នាវារលើទ្រូងម្ដាយសុំបៅ ទាហានខ្មែរក្រហមហែកចំពោះមុខភ្នែកខ្ញុំ។ តើអស់លោកអាចទ្រាំបាននូវទិដ្ឋភាពហ្នឹងទេ?

[១៥:១៩:០៩]

តាមផ្លូវ ខ្ញុំដើរមកឃើញមនុស្សសម្លាប់ស្លាប់រង្គាល ខ្ញុំដើរពីផ្លូវ ពីភ្នំពេញទៅតាមផ្លូវលេខ១ ឆ្លងតាម ឃើញនៅតាមទន្លេ ឃើញខ្មោចអណ្ដែតទឹកធ្វើឲ្យខ្ញុំស្លុតជាលើកទី២។ ខ្ញុំបន្តដំណើរពីកៀនស្វាយឆ្លងទន្លេ ធ្វើដំណើរទៅ បំណងទៅខេត្តបាត់ដំបង ដែលជាខេត្តរបស់ឪពុកម្ដាយខ្ញុំ ទៅតាមហ្នឹង ក្រែងលោជួបជុំបងប្អូន។ ប៉ុន្តែទៅអស់ដល់ ព្រោះម្ដាយឈឺ បងប្អូនហើមដោយសារខ្វះអាហារហូបចុក។ ពួកខ្ញុំចេញពីផ្ទះ គ្មានអីក្នុងខ្លួនទេ មានតែខោអាវមួយចង្កេះម្នាក់។ ជំនាន់ហ្នឹង នៅថ្ងៃ១៧ មេសា បានពីរបីអាទិត្យនៅចាយលុយនៅឡើយ។ ដូច្នេះអាចយកលុយហ្នឹងទិញម្ហូបចុកបាន ប៉ុន្តែបន្ទាប់មកមកដល់វកាកោង ទាក់ -- ផ្ទះ ព្រោះអត់មានដូរអីបានទេ អាហារអីគេប្រកាសថាចូលជាសហករណ៍។ ខ្ញុំរស់នៅក្នុងរបៀបអត់អាហារ។ គេចែករបប។ ពាក្យថា "របប" គឺថាគ្មាននរណាលើសជាងនរណាទេចំពោះប្រជាជនថ្មី ខ្ញុំមិនដឹងថាប្រជាជនចាស់ គេបែងចែកប្រជាជនថ្មីគឺអ្នកចេញពីភ្នំពេញ១៧ មេសា ហើយនិងប្រជាជនចាស់ដែលគេអ្នកនៅស្រុកហ្នឹងតែម្ដង។ គេចែកទាំងអស់គ្នាឲ្យរបបបបរវាវបីវែក មានតែអង្ករបីបួនគ្រាប់ ហើយនិងអំបិល។ ខ្ញុំអត់ចង់រំឭក ប៉ុន្តែខ្ញុំមិនអាចបំភ្លេចបានការរស់នៅយ៉ាងវេទនារបស់ខ្ញុំ និងគ្រួសារ និងជនជាតិខ្មែរទាំងអស់។ ជនជាតិខ្មែរ ជាជាតិប្រជាជនថ្មី ដែលគេហៅថាថ្មីទាំងអស់ទេ។ មិនអាចបំភ្លេចសោះ។

[១៥:២១:៣៦]

រស់គ្មានសេរីភាព សើចមិនបាន យំមិនបាន និយាយអីមិនបាន។ ព្រឹកម៉ោងប្រាំទៅធ្វើការរហូត

ដល់ថ្ងៃត្រង់។ គេចែកបបរបីវែក។ ថ្ងៃចាប់បន្តទៅទៀតរហូតដល់ថ្ងៃលិចបបរបីវែងទៀត។ យប់មិនដឹងម៉ោងប៉ុន្មាន រហូតដល់ម៉ោងដប់ ម៉ោងមួយដណ្តប់ ខ្ញុំមិនដឹងទេ អត់មានម៉ោងពេល។ គឺថាការងារនោះធ្ងន់ធ្ងរ គ្មានហូបចុក យប់ដើរមើលអត់ឃើញ ដួលខំងើបតទៅទៀត។ អត់ស្បែកជើង អត់អីទាំងអស់។ ខោអាវតែខ្មៅមួយចង្កេះ ស្លៀកស្អុយតាំងពីព្រឹកដល់ថ្ងៃ រហូតដល់យប់។ ឈឺគ្មានថ្នាំ បើឈឺខ្លាំង សុំគេៗឲ្យគ្រាប់ គេហៅគ្រាប់ទន្សាយអ៊ីចេះ គឺអង្ករលីកជាមួយស្ករ ខ្ញុំមិនដឹងថាមានអីក្នុងហ្នឹងខ្លះទេ។ ចេះតែប្រឹងលេបទៅ ព្រោះមានជាតិផ្អែមៗ។ ការរស់ដោយគ្មានសេរី តើអស់លោកស្មានបានទេ តើពិបាកយ៉ាងណា? ដួលហើយខ្ញុំទូលល្អីអង្ករ ស្រូវ ពោត។ នៅជំនាន់នោះខ្ញុំមានអាយុប្រហែល២១ឆ្នាំ ផ្អឹងនៅដុះនៅឡើយ ហើយទូលអង្ករ តើវាស្រុតផ្អឹងយ៉ាងម៉េចរហូតដល់សព្វថ្ងៃ។ ពាក្យបារាំងថា *“ប៉ាសឺម៉ង់ ដឺកូឡូន ស៊ែកវឺកាល់” (តាមសូរស័ព្ទ)* – ឈឺចាប់ ឈឺណាស់។ អាហ្នឹងហើយដែលជាផលដែលទូលអង្ករពីជំនាន់មុន ហើយដួលឈឺចង្កេះ។ ពិសេសខ្ញុំរស់នៅជាមួយមិត្តម្នាក់ មិនមែនជាមិត្តទេ ប៉ុន្តែអ្នកចេញពីភ្នំពេញទៅជាមួយគ្នា។ គ្មានសេរីភាពនឹងនិយាយ។ ខ្ញុំនឹកឡើងហួសចិត្ត ដែលគាត់និយាយជាមួយខ្ញុំថាគាត់នឹកម្តាយ -- មិនមែនថានឹកទេ គាត់នឹកថាមិនដឹងជាប្អូនស្រីគាត់ទាំងពីរទៅដល់ណា។ គ្រាន់តែពាក្យប៉ុណ្ណឹង សូមអស់លោកទាំងអស់ជួយស្តាប់ និងជួយគិតតើវាសមទេ? ស្អែកភ្លឺមិនដឹងម៉ោងប៉ុន្មាន ពួកទាហានខ្មៅពីរនាក់មក ហៅខ្ញុំពីរនាក់ចេញពីផ្ទះទាំងស្រាងៗដើរកាត់ភ្លឺស្រែ ទៅដល់កន្លែងមួយដែលខ្ញុំមិនដឹងថាស្អីជាឈ្មោះអី ស្រុកអី។ គេថាឲ្យបងដែលគាត់ឈ្មោះ មុយ ជីកដីទទឹងប្រហែលខ្លួនគាត់ បណ្តោយវែងប្រហែលប្រវែងគាត់ ជម្រៅប្រហែល៥០សង់ទីម៉ែត្រ។ អស់លោកគិតមើលដែលអត់មានស្អីទទួលទានសោះ ហើយជីកយ៉ាងហ្នឹង តើកម្លាំងបាក់ប៉ុនណា។ ដល់ពេលមួយគាត់ហេវគាត់ គាត់គ្មានកម្លាំងបន្តទៅទៀត ទាហានខ្មែរទាំងពីរសួរគាត់ថា “ម៉េចហើយ?” ខ្ញុំចាំច្បាស់ណាស់សម្តីហ្នឹង។ វារុញគាត់ទម្លាក់កប់ទាំងស្រស់ ទាំងរស់ ហើយវាចេញពាក្យថា “ហ្នឹងហើយជូនទៅឲ្យជួបបងប្អូន”។

[១៥:២៥:៣២]

ខ្ញុំចាំមិនភ្លេចនូវទិដ្ឋភាព ខ្ញុំមិនចង់យំ តែខ្ញុំនៅនឹងឃើញនៅនឹងភ្នែក។ តើអស់លោកស្មុតទេ នេះកប់ទាំងរស់ វាកប់ហើយវាងាកមកប្រាប់ខ្ញុំថា មិត្តឃើញទេ តោះទៅធ្វើការ។ ខ្ញុំយំក៏មិនប៊ានយំ ស្អីក៏មិនប៊ានទាំងអស់ ខំលេប ព្រោះនឹកឃើញថាយំ វាច្បាស់សម្លាប់ទៀត ខ្ញុំមានតែម្តាយចាស់ ខ្ញុំត្រូវអត់ធ្មត់ វាហៅខ្ញុំមកធ្វើការស្ទូងស្រូវវិញ។ យកកម្លាំងចិត្តខ្លាំង ខំតស៊ូ ខំធ្វើស្ងួត មកដល់កន្លែងធ្វើការអត់ប៊ានប្រាប់អ្នកធ្វើការដូចគ្នាថាយ៉ាងម៉េចទេ ខំស្ងួង ប៉ុន្តែអាទិដ្ឋភាពដែលវាច្រានសម្លាប់មនុស្សទាំងរស់

ធ្វើឲ្យខ្ញុំស្គុត ខ្ញុំដួល។ ប៉ុន្តែនៅកន្លែងធ្វើការហ្នឹង អ្នកដូចគ្នាហ្នឹងគេអាណិត គេសែងយកមកដាក់ភ្លឺស្រែហ្នឹងទៅ ច្របាច់គក់ថា ខ្ញុំខ្យល់គ ឬពាក្យជំនាន់ហ្នឹងគេថា ខ្ញុំគាំងបេះដូងអី គេថាម៉េចថាចុះ ខ្ញុំមិនថាទេ មិនប៉ានមាត់។

ខ្ញុំដឹងថា ខ្ញុំដំបូងខ្ញុំបាត់ស្មារតី ដោយសារខ្ញុំស្គុតនៅថ្ងៃទី១ ខ្ញុំឃើញពេទ្យគេមកមែន ប៉ុន្តែមិនដឹងជាពេទ្យថ្នាំចាក់ស្អី ឃើញមានដបទឹកក្រូចហ្វាន់តា គេតម្រង់ចាក់ខ្ញុំ ប៉ុន្តែហេតុតែសំណាងខ្ញុំមាន ខ្ញុំដឹងខ្លួនឡើងខ្ញុំប្រឹងប្រមូលអារម្មណ៍ទាំងអស់ ខ្ញុំថាខ្ញុំអត់អីទេ ខ្ញុំមានកម្លាំងទៅធ្វើការវិញ មិនបាច់ចាក់ទេ។ គឺថាប្រមូលកម្លាំង ប្រមូលអារម្មណ៍ គ្មានអ្វីដែលធំជាងកម្លាំងចិត្ត ខ្ញុំស្ទុះទៅស្ទូងស្រែដូចដើមវិញ តែអារម្មណ៍ខ្ញុំក្នុងពីរបីថ្ងៃខ្ញុំត្រូវដួលអ៊ីចឹងម្តង ព្រោះទិដ្ឋភាពដែលគេសម្លាប់ បងមុយ ទាំងរស់ នៅចំពោះខ្ញុំជានិច្ច។

[១៥:២៧:៤៣]

មានពេលខ្លះ ខ្ញុំចង់លោតទឹកសម្លាប់ខ្លួន ព្រោះខ្ញុំនៅរកាកោងតាមមាត់ទន្លេ។ ពេលរៀបឈានជើងលោត ព្រោះខ្ញុំអត់ចេះហែលទឹកទេអស់លោក បើខ្ញុំលោតទៅច្បាស់ជាស្លាប់។ ខ្ញុំរៀបនឹងឈានជើងសម្លាប់ខ្លួន ព្រោះខ្ញុំនឹកថាខ្ញុំរស់គ្មានន័យ និយាយមិនបាន យំមិនបាន ធ្វើអីក៏មិនបាន ការហូបចុកខ្វះទៀត គ្មានកម្លាំងកំហែង ខ្ញុំដើរឡើងជណ្តើរ ខ្ញុំដើរទាំងជើងទៀតទាំងដៃទៀតបានខ្ញុំឡើងជណ្តើរពីរកាំរួច។ តើអស់លោកស្មានដល់ទេ កម្លាំងដល់ប៉ុណ្ណឹង ហើយធ្វើការហួសកម្លាំង។

ម្តាយខ្ញុំនៅជាមួយ ខ្ញុំថាបើខ្ញុំស្លាប់ទៅមានអ្នកណាមើល ជួយគាត់ ព្រោះខ្ញុំឆ្លៀតទៅធ្វើការបោចត្រកួន បោចស្មៅទាំងអស់ដាក់ចូលក្នុងបបរ ហើយដែលគេចែកអំបិលតិចតួចមកផ្សំទុកមកជូនគាត់នៅផ្ទះឲ្យគាត់ពិសា ព្រោះគាត់ចូលវ័យចាស់។ ដោយសារនឹកឃើញគុណម្តាយ បានខ្ញុំដកជើងមិនលោតទឹកសម្លាប់ខ្លួន។ ប៉ុន្តែអ្វីៗដែលខ្ញុំរស់ជំនាន់ ប៉ុល ពត ខ្មែរក្រហម ខ្ញុំមិនអាចភ្លេចបាន ខ្ញុំវេទនាក្នុងអារម្មណ៍ វេទនាក្នុងកាយណាស់។ ខ្ញុំចោលការសិក្សា ខ្ញុំស្តាយ ខ្ញុំតាំងចិត្តថាខ្ញុំនឹងរស់ដើម្បីមើលតទៅទៀត។ តើរបបរបស់ ប៉ុល ពត ខ្មែរក្រហមយើងនេះមានជំហានវែងទៅដល់ណាទៀត?

សូមអស់លោកជ្រាប ខ្ញុំក្តុកក្តួល និងឈឺចាប់ចំពោះអំពើព្រៃផ្សៃដែលធ្វើសម្លាប់មនុស្សរាប់លាននាក់ គ្មានអនាម័យ គ្មានសម្លៀកបំពាក់ គ្មានថ្នាំ មនុស្សណាម្នាក់កើតចៃ កើតរមាស់ពេញខ្លួន។ ខ្ញុំសូមបញ្ចប់ត្រឹមហ្នឹងចុះ។ បើអស់ លោកមានចម្ងល់អីអាចសួរខ្ញុំទៀត។ ប៉ុន្តែបញ្ជាក់ហើយបញ្ជាក់ទៀតថា ការរស់នៅជំនាន់ ប៉ុល ពត ធ្វើឲ្យខ្ញុំវេទនារហូតដល់សព្វថ្ងៃ។ មានអារម្មណ៍មិនសុខទេ ខ្ញុំភ័យខ្លាច

ខ្ញុំអត់បានមើលភាពយន្តណាដែលមានកាប់សម្លាប់ មិនបានមើលស្អីនឹងឈាម ហើយពិសេសខ្ញុំធ្វើនៅក្នុងមុខវិជ្ជាខ្ញុំជាឱសថការី មានមើលឃើញមើលអី ខ្ញុំខ្លាចណាស់ មិនសមជាខ្ញុំធ្វើជាឱសថការី ទៅផ្សះផ្សាមើលថ្នាំ មើលឈាមទេ ខ្ញុំខ្លាច។ ពេលមានរបួសបន្តិចបន្តួចអ្នកជំងឺមកធ្វើ មកជួយឲ្យខ្ញុំលាងរុំសអី ខ្ញុំឲ្យអ្នកធ្វើការជាមួយខ្ញុំមើលជំនួសខ្ញុំ ព្រោះខ្ញុំមិនអាចនឹងមើលឈាមទេ។

[១៥:៣១:០៧]

ភាពយន្តមានការកាប់សម្លាប់ក៏ខ្ញុំមិនមើលដែរ ហើយខ្ញុំស្លុតណាស់ពេលឮសំឡេងខ្លាំង ឮខ្លួងខ្លាំង ឮសំឡេងដែលគេស្រែកបោាអី។ ខ្ញុំមិនអាចនៅជិតបានទេ រហូតទើសសព្វថ្ងៃហ្នឹង។ ជាមួយប្តីខ្ញុំអីចឹងដែរ ខ្ញុំអត់ចង់ឮឲ្យគាត់និយាយខ្លាំង អត់ចង់ឲ្យគាត់ឮស្រែកឡូឡា មិនចង់ឲ្យគាត់ធ្វើអាស្អីដែលធ្វើឲ្យខ្ញុំស្លុត។ ហ្នឹងហើយជាផលដែលការរស់នៅ ផលវិបាករបស់ខ្ញុំតាំងពីជំនាន់នោះរហូតដល់ឥឡូវ។ សូមអស់លោកជ្រាប។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី អេងលី។ ឥឡូវនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទទួលសិទ្ធិឲ្យមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

[១៥:៣២:០៥]

**លោក ប៉ាស្កាល់ អូប៊ីង៖**

ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីជាទីគោរព ជម្រាបសួរភាគីទាំងងស់ជាទីគោរព ហើយនិងសាធារណជនជាទីគោរព។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ប៉ាស្កាល់ អូប៊ីង៖**

**ស៖** អ្នកស្រីដើមបណ្តឹងរដ្ឋប្បវេណីជាទីគោរព! តើអ្នកស្រីឮខ្ញុំទេ?

**លោកស្រី ឆេង អេងលី៖**

**ឆ៖** ចាស។

**ស៖** បាទ ខ្ញុំមិនដឹងថា ចំពោះអ្នកស្រីជាការលំបាកណាស់ក្នុងការចងចាំរបបកម្ពុជាប្រជាធិប-តេយ្យនេះ។ តើទន្ទឹមនឹងនោះ ឥឡូវនេះអ្នកស្រីអាចបញ្ជាក់បានទេ អំពីលក្ខខណ្ឌដែលអ្នកស្រីបានចូល

បានមើលឃើញ ឧទាហរណ៍ដូចជា ក្មេងដែលថា គេចាប់ហែកចេញពេលដែលគេជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនោះ ហែកជើងនោះ? សូមអ្នកស្រីជួយបំភ្លឺចំណុចនេះបន្តិចបានទេ?

[១៥:៣៣:០៤]

**ឆ៖** ខ្ញុំជម្រាបអំមិញថា ពេលចេញពីភ្នំពេញការធ្វើដំណើរពីភ្នំពេញទៅតាមផ្លូវជាតិលេខ១ ផ្លូងស្ពានមុនីវង្ស ខ្ញុំឃើញទារកម្នាក់យំ ហើយវារនៅលើទ្រូងម្ដាយដែលស្លាប់ពីអង្កាល់ខ្ញុំមិនដឹង។ ខ្ញុំចិត្តចង់ទៅលើកព្រោះអាណិតក្មេង ចិត្តចង់ទៅហើយ ប៉ុន្តែរយៈចិត្តពេលដែលខ្ញុំចង់ និងពេលខ្ញុំឃើញទាហានទៅលើកហ្នឹងវាយឹតពេលពេក។ ខ្ញុំឃើញទាហានម្នាក់លើកក្មេងហ្នឹងឡើង ចាប់ហែកជាពីរ ហើយបោះខ្ចោចផ្សាណាស់ គ្មានអាណិតក្មេងដែលគ្នាគ្មាន មិនគិតថា តើកូនគេកូនយើង ថាតើវាឃ្លានអីចឹង វារកដោះទេ? ហើយបើវាឃ្លានអីចឹងតើវារកស៊ីញ៉ាំទេ ទទួលទានទេ ម៉េចក៏វាធ្វើអីចឹង? អាហ្នឹងហើយខ្ញុំស្លុតពេក ប៉ុន្តែខ្ញុំគ្មានៗ -- ខ្ញុំមិនប៊ានទេខ្លាចវាសម្លាប់បន្តទៅទៀត។ ដូច្នេះអាក់ចិត្តដោយខំធ្មេចភ្នែកធ្វើដំណើរទៅមុខទៀតជាមួយម្ដាយនិងបងៗ។

[១៥:៣៤:៥៣]

**ស៖** បាទ សូមអរគុណដែលបានឆ្លើយ។ បាទ នៅពេលដែលអ្នកស្រីទៅដល់សហករណ៍ តើជាដំបូងនោះអ្នកស្រីបានឃើញអ្វីដែរនៅទីនោះ?

**ឆ៖** សុំទោស មានសំណួរថាទៅដល់សហករណ៍ ពេលទៅដល់រកាកោងហើយហ្នឹងឬអីលោក?

**ស៖** បាទ ហ្នឹងហើយនៅពេលដែលអ្នកស្រីទៅដល់សហករណ៍នោះឯង។ នៅពេលដែលលោកឃើញអ្នកដែលបះបោរនោះខ្ញុំចង់ដឹងថាអ្នកដែលបះបោរនោះជាអ្នកណា? ហើយសូមអ្នកស្រីបំភ្លឺចំណុចនេះបន្តិច?

**ឆ៖** ចាស ខ្ញុំភ្លេចជម្រាប។ ពេលខ្ញុំទៅដល់រកាកោងថ្ងៃទីពីរ ប្រហែលជាយប់មិនដឹង ជាម៉ោងប៉ុន្មានខ្ញុំមានបងប្អូនខ្មែរយើងអ្នកភ្នំពេញបបួលគ្នាថាយប់នេះទៅធ្វើការបះបោរដើម្បីសុំឱ្យបានត្រឡប់ចូលទៅភ្នំពេញវិញ ហើយឱ្យបានមានការហូបចុក និងមានលុយកាក់ចាយដូចដើមវិញ។ ហើយក៏ស្ងាត់ទៅប្រហែលស្រាងៗឡើងខ្ញុំឃើញអស់លោកសុទ្ធតែប្រុសៗទាំងអស់មួយស្ទូប្រហែលខ្ទង់ ២០ប្លាយនាក់ដែរខ្ញុំមិនអាចរៀបរាប់ចំនួនបាន ហើយចង -- មិនមែនយកខ្សែព្ធួរទេលោក យកអំបោះដេរយើងហ្នឹងចងជាមួយស្ទូ មួយចង្វាយដើរទៅ ហើយមានទាហានខ្មៅយើងកាន់កាំភ្លើងម្នាក់ពីរដើរពីក្រោយអមហ្នឹង ហើយដែលស្រែកថា មានបងប្អូនណាទៀតប៊ានតែកម្រើកនឹងបាញ់សម្លាប់។ លោកគិតមើលវាព្រមានដល់

ប៉ុណ្ណឹងហើយវាចងនឹងខ្សែអំបោះ តើវាសាហាវដល់ប៉ុនណា ហើយប្រជាជនយើងនៅក្នុងផ្ទះគ្រប់គ្នាអត់ហ៊ានមាត់ទេ មិនដឹងជាវាយកទៅណា? ខ្ញុំថាច្បាស់ជាយកទៅសម្លាប់ហើយ។ ព្រោះអ្នកទាំងអស់គ្នាដែលនៅក្នុងចំណោមហ្នឹងមានម្នាក់នៅក្នុងក្រុម ព្រោះនៅជំនាន់ខ្ញុំទៅដល់រកាកោងនៅផ្ទះហ្នឹងមួយមានចំនួនគ្រួសារ បួនគ្រួសារ។ មានគ្រួសារខ្ញុំហ្នឹងមួយ ហើយនិងគ្រួសារបីទៀតសុទ្ធតែអ្នកមកពីភ្នំពេញទាំងអស់។ ហើយនៅក្នុងចំណោមគ្រួសារបួនហ្នឹង មានក្មេងម្នាក់បាត់ ប្រហែលជាទៅក្នុងក្រុមហ្នឹងដែរ ហើយអត់ឃើញត្រឡប់មកវិញ។ ដូច្នេះបានសេចក្តីថា អ្នកដែលវាចងទាំងខ្សែហ្នឹងមិនអាចត្រឡប់មកជួបជុំគ្រួសារទេ ច្បាស់ជាយកទៅសម្លាប់ចោលហើយ។ សូមជ្រាបចាស។

[១៥:៣៨:២៥]

**ស៖** បាទ សូមអរគុណដែលបានឆ្លើយ។ តើលោកស្រីអាចជម្រាបជូនតុលាការបានដែរទេថា ការដែលអ្នកស្រីឃើញនេះវាជះឥទ្ធិពលយ៉ាងដូចម្តេចខ្លះទៅលើរូបអ្នកស្រី?

**ឆ៖** ចាស ពេលឃើញវាបណ្តើរបងប្អូនខ្មែរយើងប្រុសៗទាំងស្ន ធ្វើឲ្យខ្ញុំស្លុត ហើយនឹកស្មានថា មិនអាចច្បាស់ជាមានស្អីមួយដែលមិនអាចវិលត្រឡប់ទៅរកភាពដើម។ បានន័យថា មិនអាច -- យើងខ្ញុំទាំងអស់គ្នាហ្នឹងមិនអាចត្រឡប់ចូលទៅទីលំនៅដើមរបស់យើងវិញបានទេ ហើយនិងនឹកក្នុងចិត្តថា ប្រហែលជានឹងមានការកាប់សម្លាប់ ហើយនិងបំបិទសិទ្ធិសេរីភាព។ ឧទាហរណ៍ជាក់ស្តែងគឺវាយកចងទាំងខ្សែអំបោះ ហើយនិងប្រកាសថាអ្នកណាហ៊ានកម្រើកនឹងសម្លាប់ចោល។ អានេះជា -- បង្ហាញថាអំណាចផ្តាច់ការ មួយហើយដែលត្រូវសម្លាប់ចោលអត់មានយកទៅពិចារណា។ សូមទោស គឺអ៊ីចឹងហើយចាស។

**ស៖** សូមអរគុណ។ នៅពេលដែលអ្នកស្រីនៅសហករណ៍ហ្នឹង អ្នកស្រីបានពន្យល់ថាលក្ខខណ្ឌការងារហ្នឹងអាក្រក់អាក្រីណាស់។ តើទំនាក់ទំនងជាមួយនឹងប្រធានកងរបស់អ្នកស្រីហ្នឹងយ៉ាងម៉េចដែរ អ្នកស្រី ហើយនិងប្រធានកងអ្នកស្រី?

**ឆ៖** ចាស ការរស់នៅជំនាន់នោះគេបែងចែកជាបីក្រុម គឺក្រុមវ័យចាស់ វ័យកណ្តាល វ័យកុមារ។ ខ្ញុំចូលនៅក្នុងវ័យកណ្តាល។ ហើយនៅក្នុងក្រុមនីមួយៗមានចំនួនប្រហែល២០នាក់ ដោយមានមេកងស្រីម្នាក់ អ្នកនាំ *(ឮមិនច្បាស់)* ស្ទូងនៅកន្លែង--

**ស៖** ខ្ញុំចង់និយាយថា នែ៎ប្រធានកង មេកងហ្នឹងៗគាត់ចិត្តល្អជាមួយលោកស្រីទេ?

[១៥:៤១:៤៥]

**ឆ៖** ចិត្តល្អអត់មានទាល់តែសោះលោក។ បើថាចិត្តជាយក្ខិនី ចិត្តជាឃាតករសម្តី អាហ្នឹងមាន ចាស។ ព្រោះព្រលឹមឡើងសម្តីចេញមក គឺថាជេរស្តី មិនមែនលួង មិនមែននិយាយថា អ្នក! ឥឡូវ បងប្អូនអើយទៅធ្វើការម៉ោងព្រឹកហើយ អត់ទេ។ ចេញមក ពួកអ្នក១៧ មេសា ត្រូវទៅធ្វើការ, ពួក ពីហ៎ាងឯងថា-- គឺសម្តី មិនធ្លាប់ឮទេ ខ្ញុំអត់ចង់រំឭកពាក្យយង់ឃ្នង ពាក្យអសុរស ដែលមិនមែនជាស្រី ខ្មែរ។ ស្រីខ្មែរមានសម្តីទន់ភ្លន់។ មិនមែនសាហាវយង់ឃ្នង សម្តីអសុរសអ៊ីចឹងទេ។ សូមលោកជ្រាប។ ជាសម្តីយក្ខិនី ជាសម្តីខ្មោច ជាសម្តីព្រាយបិសាច បើថាខ្មែរយើងនិយាយអ៊ីចឹង។

**ស៖** បាទដូច្នេះ បើខ្ញុំយល់មិនច្រឡំទេ អ្វីដែលអ្នកស្រីនិយាយជូនតុលាការនេះ គឺថាកាលដែល អ្នកស្រីជាប្រជាជនថ្មី គឺថាធ្វើឲ្យគេជេរប្រទេចអ្នកស្រីជារៀងរាល់ថ្ងៃ គឺថាមេកងហ្នឹងជេរប្រទេច អ្នកស្រីជារៀងរាល់ថ្ងៃ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស អ៊ីចឹងហើយលោក អត់ខុសគេ។ គឺថាបើកភ្នែកឡើងជួបមុខគ្នាឡើង--

**ស៖** បាទ អ្នកស្រីក៏បានលើកឡើងផងដែរថា នៅពេលព្រហាមមួយនោះ បានមើលឃើញការ សម្លាប់មិត្តអ្នកស្រីដែលជាគ្រូបង្រៀនហ្នឹង ឃើញហ្នឹងភ្នែកតែម្តង។ តើអ្នកស្រីអាចជម្រាបជូនតុលាការ បានទេអំពីផលវិបាកនៃការឃើញនេះចំពោះលោកនោះលោកស្រី។ តើលោកស្រីទទួលឥទ្ធិពលយ៉ាងម៉េច ខ្លះសូមជម្រាបជូនតុលាការ?

[១៥:៤២:០០]

**ឆ៖** ចាស ពេលខ្ញុំឃើញគេកប់ បងមុយ ទាំងស្រស់ ដែលគ្មានកំហុសអីមួយធ្ងន់ធ្ងរក្រៅពីនិយាយ ថា ប្អូនស្រីទាំងពីរមិនដឹងនៅឯណា? ធ្វើឲ្យខ្ញុំស្លុត ដែលខ្ញុំមិនដែលឃើញគេស្លាប់មនុស្សទាំងស្រស់ គេកប់មនុស្សពេលមនុស្សស្លាប់។ ប៉ុន្តែពួកទាហានខ្មែរក្រហមសម្លាប់មនុស្ស -- កប់មនុស្សទាំងរស់ ដែលក្នុងសតវត្សរ៍ណាក៏ដោយក៏មិនដែលមានដែរ។ ដូច្នេះហើយធ្វើឲ្យខ្ញុំស្លុត ពេលខ្ញុំត្រឡប់មកធ្វើការ វិញ ខ្ញុំគ្នាត់កម្លាំងកំហែង ខ្ញុំចង់និយាយប្រាប់ម្តាយ ប្រាប់បងពីការឃើញ ប៉ុន្តែនិយាយមិនកើត។ ដូច្នេះ ស្អីដែលបៀមទុកនៅក្នុងខ្លួន ហើយនិយាយមិនចេញ គ្មានសិទ្ធិនឹងនិយាយ និងគ្មានសិទ្ធិនឹងរ៉ាយរ៉ាប់ តើលោកគិតមើល៍ តើវាពិបាកយ៉ាងណា? មនុស្សម្នាក់ៗដែលមានទុក្ខ បើបាននិយាយបន្តិចទៅក៏វា ស្រួលក្នុងចិត្ត ហើយបើបាននិយាយពីការពិតរឹតតែល្អទៅទៀត។ តែនេះគ្មាននិយាយបានទៀត បើសិន ជាខ្ញុំប៉ានិយាយ ខ្ញុំនឹងស្លាប់ខ្លួន ដោយការសម្លាប់របស់ទាហានខ្មៅទាំងអស់។ ព្រោះវាបំបិទសិទ្ធិមិន ឲ្យនិយាយ មិនឲ្យយំ មិនឲ្យសើច។ បាទ សូមលោកជ្រាប។

**ស៖** សព្វថ្ងៃនេះ អ្នកស្រីរស់នៅប្រទេសបារាំងតាំងពីយូរឆ្នាំមកហើយ តើអ្នកស្រីអាចជម្រាបជូនតុលាការបានដែរឬទេថា អ្នកស្រីនៅតែទទួលរងពីការប៉ះទង្គិចនេះដោយសារតែរបបកម្ពុជាប្រជាធិបតេយ្យ? បាទសូមជម្រាបជូនតុលាការ។

*(មានបញ្ហាបច្ចេកទេស)*

[១៥:៤៦:២៧]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីមានបញ្ហាដាច់ប្រព័ន្ធអ៊ីនធឺណេតទៀតហើយ។

*(មានបញ្ហាបច្ចេកទេស)*

[១៥:៤៧:១៥]

**ប្រធានអង្គជំនុំ៖**

សូមបន្តលោកមេធាវី!

**លោក ប៉ាស្កាល់ អូប៊ីង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក ប៉ាស្កាល់ អូប៊ីង៖**

**ស៖** អ្នកស្រី នេះជាសំណួរចុងក្រោយរបស់ខ្ញុំ។ សព្វថ្ងៃនេះអ្នកស្រីរស់នៅប្រទេសបារាំង ហើយរាប់ជាច្រើនឆ្នាំមកហើយនៅប្រទេសបារាំងនេះ។ តើអ្នកស្រីអាចជម្រាបជូនតុលាការអំពីការប៉ះទង្គិចដែលកើតចេញពីរបបកម្ពុជាប្រជាធិបតេយ្យនេះបានទេ?

**ឆ៖** សូមជម្រាបសួរលោក លោកចង់មានប្រសាសន៍ថា ប៉ះទង្គិចខាងផ្លូវចិត្ត ខាងផ្លូវកាយ ឬយ៉ាង -- បើថាប៉ះៗទង្គិចទាំងអស់លោក។ ទាំងផ្លូវចិត្ត ទាំងផ្លូវកាយ។ ផ្លូវកាយគឺខ្ញុំមានការចុកចាប់ក្នុងការខ្ញុំទូលល្អីស្រូវ ហើយនិងពោតវាធ្ងន់ពេក ធ្វើឲ្យស្រុតឆ្អឹងក មានការឈឺចាប់រហូតដល់សព្វថ្ងៃហ្នឹង។ អាហ្នឹងខាងផ្លូវកាយ។ ឯផ្លូវចិត្ត ខ្ញុំមិនអាច ដូចខ្ញុំជម្រាបពីដើមហើយ ខ្ញុំមិនអាចមើលភាពយន្តឬក៏មើលឃើញទិដ្ឋភាពណាដែលសាហាវ មានការវាយដំ មានការកាប់សម្លាប់។ ខ្ញុំអត់អាចមើលបានទាល់តែសោះ។ ខ្ញុំអត់ចង់ឃើញ ខ្ញុំអត់ចង់មើល។ ខ្ញុំស្លុត ហើយនិងឮសំឡេងស្រែកខ្លាំងឡូឡា ខ្ញុំក៏អត់ចង់ឮទៀត។ ដូច្នេះ សព្វថ្ងៃខ្ញុំដូចទៅជាមនុស្សដែលខ្វះៗការយកចិត្តទុកដាក់មើលចំពោះ -- មើលៗពេលគេមានរបួសមានអី ខ្ញុំដូចខ្វះកន្លែង។ ខ្ញុំដឹងខ្លួនថាខ្ញុំគ្មានសមានចិត្ត គ្មានចិត្តក្លាហាននឹងទៅជួយ ទៅមើល

ប៉ុន្តែមកពីខ្ញុំបាក់ស្បាត។ ពាក្យថាបាក់ស្បាត មិនអាចធ្វើអ៊ីចឹងបានចាស។ សូមទោស។

[១៥:៤៩:៥១]

**លោក ប៉ាស្កាល់ អូប៊ីង៖**

លោកប្រធាន ខ្ញុំសួរចប់ហើយ។ អ្នកស្រី ខ្ញុំសូមអរគុណច្រើនដែលមកផ្តល់សក្ខីកម្មនៅទីនេះ។ ខ្ញុំដឹងថានេះជាពេលដែលលំបាកណាស់ ដែលរំឭករឿងដើមនេះឡើងវិញ។ អ៊ីចឹងខ្ញុំសូមអរគុណដែលអ្នកស្រីបានមកផ្តល់សក្ខីកម្មនៅទីនេះ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** បាទ សូមអរគុណលោកប្រធាន។ ជាបឋមសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ ហើយក៏សូមជម្រាបសួរលោកស្រីជាដើមបណ្តឹងនេះ ហើយក៏សូមជម្រាបសួរលោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ លោកស្រីខ្ញុំមកពីការិយាល័យសហព្រះរាជអាជ្ញានៃសាលាក្តីខ្មែរក្រហមដែលហៅកាត់ហ្នឹង។ មានសំណួរមួយចំនួនតូចចង់ឱ្យលោកស្រីជួយបញ្ជាក់។ លោកស្រីបានជម្រាបជូនអង្គសវនាការអម្បាញ់មិញថា លោកស្រីបានធ្វើដំណើរចេញពីផ្ទះចេញទៅខាងរកាកោង។ ខ្ញុំចង់ឱ្យលោកស្រីជួយបញ្ជាក់អំពីព្រឹត្តិការណ៍មុននឹងលោកស្រីធ្វើដំណើរទៅរកាកោងហ្នឹង តើមានព្រឹត្តិការណ៍អ្វីខ្លះដែលធ្វើឱ្យលោកស្រីចេញទៅរកាកោងហ្នឹងបាទ? សូមលោកស្រីរៀបរាប់អំពីព្រឹត្តិការណ៍មួយចំនួនដែលតម្រូវឱ្យលោកស្រីចេញដំណើរ?

[១៥:៥១:៣៩]

**លោកស្រី ឆែង អេងលី៖**

**ឆ៖** ចាស សូមជម្រាបថា ថ្ងៃ១៧ មេសាដែលប្រកាសថាមានសន្តិភាពហើយ ប៉ុន្តែផ្ទុយទៅវិញពេលហ្នឹងក៏មានទាហានស្លៀកពាក់ខ្មៅដេញពួកខ្ញុំចេញពីផ្ទះ។ ខ្ញុំនៅភ្នំពេញធ្វើដំណើរតាមគេតាមឯងទេ អត់មានទីដៅឆ្ពោះទៅណាទេ ឆ្លងស្ពានក្បាលថ្នល់ធ្វើដំណើរទៅមុខ ចេះតែធ្វើទៅអត់មានទីដៅ ប៉ុន្តែខ្ញុំទៅដល់កៀនស្វាយ នៅពេលនុំងដូចអស់ស្បៀងអស់អីហើយ ប៉ុន្តែនៅសល់ គេនៅចាយលុយ

បន្តិចបន្តួចដែរ និងមាន -- ខ្ញុំសូមបញ្ជាក់ប្រាប់ថា ខ្ញុំមានខោអាវសល់ពីប្អូនប្រុសខ្ញុំ ព្រោះវាបម្រុងបានមករៀននៅស្រុកបារាំង។ វាមានខោអាវបម្រុងទៅស្រុកបារាំង ដូច្នេះវាយកមកតាមខ្លួន ដោយសារបានខោអាវប្អូនហ្នឹងហើយដែលអាចដូរតាមផ្លូវបាន។ ហើយម្ដាយខ្ញុំគាត់ថា បើសិនជានៅគៀនស្វាយតទៅទៀត ច្បាស់ជាដាច់ពោះស្លាប់ ដូច្នេះមានបងប្អូន--

**ស៖** លោកស្រី ខ្ញុំសូមអភ័យទោស សូមកាត់លោកស្រី។ ខ្ញុំចង់ឲ្យលោកស្រីជួយបញ្ជាក់អំពីព្រឹត្តិការណ៍ដែលមុននឹង ដែលជំរុញឲ្យលោកស្រីចេញទៅ។ លោកស្រីបានបញ្ជាក់អម្បាញ់មិញហើយថាមានទាហានពាក់ឈុតខ្មៅ នៅថ្ងៃ១៧ មេសា ហ្នឹងបានដេញលោកស្រីឲ្យចេញពីភ្នំពេញ។ អ៊ីចេះសំណួរតទៅទៀតហ្នឹងគឺចង់ដឹងថាទាហានពាក់ឈុតខ្មៅហ្នឹងបានដេញលោកស្រីយ៉ាងម៉េចខ្លះ លោកស្រីអាចជួយជម្រាបជូនបានទេបាទ?

[១៥:៥៣:២៤]

**ផ៖** ចាស គាត់មកដល់-- ខ្ញុំនៅគីឡូលេខ៦ ខ្ញុំមានរ៉ុក្កែតធ្លាក់ខ្លាំងពេក ក៏ឃើញគេជ្រួលទាំងអស់គ្នា ខ្ញុំក៏ជ្រួលចេញមកដល់ភ្នំពេញមកផ្ទះម្ដាយមីងខ្ញុំ។ ម្ដាយធំខ្ញុំនៅផ្សារថ្មី មកដល់ផ្សារថ្មីពីរបីថ្ងៃទាហានខ្មៅដេញចុះពីផ្ទះថាត្រូវចេញទាំងអស់គ្នា ព្រោះនឹងមានធ្លាក់គ្រាប់បែកគ្រាប់អី ឲ្យចេញទៅសិនទៅ។ ខ្ញុំក៏ភ័យព្រួសតែគ្រាប់បែក ព្រោះធ្លាក់បាក់ស្បាតនឹងធ្លាក់រ៉ុក្កែតប៉ុន្មានខែប៉ុន្មានឆ្នាំមកហើយ ក៏ផ្អើលទាំងម្ដាយមីង ទាំងម្ដាយទាំងអីចេញពីផ្សារថ្មី ធ្វើដំណើរ *(គ្មានការបកប្រែ)* -- សូមទោសដោយសារវាដេញថានឹងមានធ្លាក់គ្រាប់បែកគ្រាប់អីហ្នឹងបាននាំគ្នាចេញហ្នឹងទៅ។ ចាសសូមបញ្ជាក់ត្រឹមហ្នឹង។

**ស៖** បាទ អរគុណលោកស្រី។ ក្នុងអំឡុងពេលដែលលោកស្រីចេញពីភ្នំពេញទៅហ្នឹង តើលោកស្រីចេញទៅប៉ុន្មាននាក់ ហើយក្នុងចំណោមក្រុមគ្រួសារលោកស្រីដែលបានចេញទៅហ្នឹង មានមនុស្សចាស់ជរា ឬក៏មានកូនក្មេងតូចតាចទេ?

**ផ៖** ខ្ញុំមានម្ដាយចាស់ចេញជាមួយ បងប្រុសពីរ និងប្អូនប្រុសមួយ ចេញទៅជាមួយអត់មានកុមារទេ តែមានម្ដាយចាស់។

**ស៖** បាទ អរគុណ។ ចុះលោកស្រីអាចជម្រាបជូនអង្គសវនាការបានទេថា ម្ដាយចាស់លោកស្រី ដែលត្រូវគេដេញឲ្យចេញពីភ្នំពេញ ធ្វើដំណើរទៅនុ៎ង តើលោកស្ថានភាពគាត់យ៉ាងម៉េចដែរ?

[១៥:៥៥:១៤]

**ផ៖** ចាស់ៗ គេចាស់ -- ម្ដាយចាស់គេដទៃ គឺថាគាត់ ខ្ញុំមិនដឹងថាគាត់យល់យ៉ាងម៉េចទេ ប៉ុន្តែ

ខ្ញុំដឹងថាគាត់នឹងស្លុតដូចទាំងអស់គ្នាហ្នឹង ព្រោះអាពេលគេដេញ និងមានកាំភ្លើងពីក្រោយហ្នឹងទាំងគេ ទាំងគាត់ ទាំងខ្ញុំស្លុតណាស់លោក បើថាដេញចេញអត់មានកាំភ្លើង ហើយនិងអត់ឃើញសាកសពនៅតាមផ្លូវ មិនជាស្លុតណាស់ណា។ ស្លុតតែប៉ុន្តែវាស្លុតដល់កម្រិត -- ខ្ញុំដឹងថាគាត់ស្លុត ប៉ុន្តែគាត់ជាចាស់ដែលមានការពិសោធក្នុងជីវិត គាត់មិនធ្វើអ្វីដែលឲ្យក្មេងៗហ្នឹងរឹតតែស្លុតទេ។ គាត់មានតែនិយាយថា ធ្វើដំណើរទៅកូនទៅមុខ ទៅតាមគេតាមឯង។ ចាស ខ្ញុំចាំសម្ដីគាត់ច្បាស់ប៉ុណ្ណឹង។

**ស៖** បាទ អរគុណ។ ចុះការធ្វើដំណើរចេញទៅរកាកោងហ្នឹង នៅតាមផ្លូវតើមានទាហាន ឬក៏កម្លាំងរបស់ខ្មែរក្រហមបានទៅជាមួយលោកស្រីដែរទេ? ចង់និយាយថា ពីការអមដំណើរចេញទៅតើមានអីចឹងដែរទេ?

**ឆ៖** ពេលខ្ញុំឆ្លងទូកពីកៀនស្វាយទៅធ្វើដំណើរបន្តទៅរកាកោងចេះតែមានទាហានខ្មែរខ្មៅអីចឹងដែរ ដេញៗបន្តទៅទៀតចាស។ មិនមែនដេញតែខ្ញុំទេ ដេញបន្តទាំងអស់គ្នាហ្នឹងទៅ ហើយខ្ញុំចេះតែបន្តទៅ បន្តជាមួយគេហ្នឹងទៅ ដោយគ្មានទិសដៅថា ទៅច្បាស់ថាឲ្យដល់ណាទេ ប៉ុន្តែទិសដៅរបស់ម្ដាយខ្ញុំ គឺទៅបាត់ដំបង។ ដោយឆ្លងទូកពីកៀនស្វាយដើរតាមផ្លូវទៅរកាកោង។

[១៥:៥៦:៦៤]

**ស៖** បាទ អរគុណលោកស្រី។ មុននឹងដែរ លោកស្រីបានជម្រាបជូនអង្គសវនាការដែរថា នៅតាមផ្លូវលោកស្រីបានឃើញមានខ្មោចបណ្ដែតទឹក តើលោកស្រីអាចជម្រាបជូនបានទេថា ខ្មោចបណ្ដែតទឹកហ្នឹងក្នុងស្ថានភាពជាប្រជាជនធម្មតា ឬក៏ជាទាហាន?

**ឆ៖** សូមទោស សំណួរលោកខ្ញុំពិបាកជម្រាបថា ជាប្រជាជន ឬក៏ជាទាហានខ្មែរក្រហម ឬទាហានយើងចាស។ ព្រោះខ្ញុំមិនដឹងទាហានអីទេ ព្រោះឃើញតែខ្មោចអណ្ដែតទឹកទៅ ហើយស្លុតយ៉ាងហ្នឹងតើយកពេលឯណានឹងសង្កេតមើលថា តើប្រជាជនយើង ឬទាហានខ្មែរក្រហម ឬទាហានជំនាន់ប៉ុល ពត អី ជំនាន់ លន់ នល់ ខ្ញុំមិនអាចជម្រាបលោកបានទេចាស។ គ្រាន់តែឃើញអណ្ដែតអីចឹងទៅ ទាំងគេ ទាំងលោក ខ្ញុំជឿថា អ្នកទាំងអស់គ្នាមិនបានទៅមើលឲ្យជិត គ្មានអាស្អីផ្ទុះទៅមើលថាតើទាហានខ្មោចហ្នឹង ខ្មោចជាតិអី សាសន៍ទេ។ សូមលោកជ្រាប។

**ស៖** បាទ អរគុណ។ នេះគ្រាន់តែចង់ដឹងថាក្រែងលោលោកស្រីបានពិនិត្យឃើញច្បាស់ ប៉ុន្តែដោយសារតែលោកស្រីមិនបានពិនិត្យឃើញច្បាស់អីចឹង មិនជាបញ្ហាអ្វីទេ។ ហើយមួយទៀត សំណួរមួយទៀត ទាក់ទងទៅនឹងដែលលោកស្រីបានជម្រាបជូនអង្គសវនាការថា នៅពេលដែលលោកស្រីទៅ

ដល់រកាកោង ពេលនោះគេឲ្យលោកស្រីចូលសហករណ៍ តើលោកស្រីចាំទេថា គេនោះជាអ្នកណាដែរ លោកនៅចាំទេ? អ្នកណាគេអ្នកឲ្យលោកស្រីចូលសហករណ៍ហ្នឹង?

[១៥:៥៨:៤១]

**ឆ៖** ខ្ញុំមិនអាចជម្រាបបានថាអ្នកណាទេលោក ប៉ុន្តែវាគ្រាន់ថាគេដើរប្រកាសតាមមាត់ផ្លូវអ៊ីចឹងថា សូមឲ្យអ្នកប្រជាជនថ្មីមកពីភ្នំពេញ ជន១៧មេសា ចូលជាសហករណ៍។ អ្នកណាមានទ្រព្យសម្បត្តិប៉ុន្មាន មានស្អីៗប៉ុន្មានហ្នឹងកុំលាក់ កុំលៀម យកទៅឲ្យកន្លែងគេមួយដែលគេថា ជាសហករណ៍ហើយ យើងហូបចុកស្មើទាំងអស់ គ្មានអ្នកណាមានជាងអ្នកណាមានទេ។ រួចខ្ញុំមិនដឹងថា អ្នកណាទេជំនាន់នោះ។ សូមលោកជ្រាប។

**លោក សេង ប៊ុនឃាង៖**

បាទ អរគុណលោកស្រី។ ដោយសារពេលវេលាខ្ញុំសូមអស់សំណួរត្រឹមនេះ។ ហើយខ្ញុំ -- លោកប្រធានខ្ញុំអស់សំណួរហើយ ហើយក៏សូមអរគុណដល់លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីដែរ ដែលបានចូលរួមក្នុងដំណើរការនីតិវិធីរបស់តុលាការយើងនេះ ដើម្បីស្វែងរកការពិតបាទ។ អ៊ីចឹងសូមអរគុណ។

[១៥:៥៩:៤២]

**លោកស្រី ហ្វូ ចន្ថា៖**

ចាស សូមអរគុណលោកដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើក្រុមមេធាវី នួន ជា មានបំណងធ្វើដូច្នេះ។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

យើងខ្ញុំពុំមានសំណួរនោះទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ជាចុងក្រោយអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការ។ ក្នុងនាមលោក ខៀវ សំផន យើងខ្ញុំអត់

មានសំណួរអីសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ អរគុណលោកស្រី ឆេង អេងលី។ ការស្ដាប់លោកស្រីថ្លែងរៀបរាប់អំពីទុក្ខសោក វេទនានិងផល ប៉ះពាល់និងសក្ខីកម្មរបស់លោកស្រីរហូតដល់ពេលនេះបានចប់ហើយ។ ហើយវត្តមាន របស់លោកស្រី នៅកន្លែងផ្ដល់សក្ខីកម្មនៅទីនោះលែងមានភាពចាំបាច់ទៀតហើយ។ សេចក្ដីថ្លែងរៀប រាប់អំពីទុក្ខសោក វេទនា អំពីផលប៉ះពាល់ និងសក្ខីកម្មរបស់លោកស្រី និងអាចរួមវិភាគទានក្នុងការ ស្វែងរកការពិតក្នុងរឿងក្ដីនេះ។ សូមលោកស្រីមានសុខភាពល្អជួបតែសំណាងល្អហើយមានសេចក្ដីសុខ សុភមង្គល ហើយលោកស្រីអាចវិលត្រឡប់ទៅវិញបានហើយ។ សូមជម្រាបលាលោកស្រី ឆេងអេងលី។

**លោកស្រី ឆេង អេងលី៖**

ចាស ជម្រាបលា។ ហើយសូមផ្ដាំឲ្យជួយ ឲ្យតុលាការរកយុត្តិធម៌ឲ្យប្រជាជនខ្មែរយើង២លាន នាក់ដែលស្លាប់ទៅផង។ អរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី។

កិច្ចដំណើរការសវនាការនៅថ្ងៃនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ច ដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី៣០ ខែឧសភា ឆ្នាំ២០១៣ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃស្អែកនេះអង្គជំនុំជម្រះ នឹងធ្វើសវនាការស្ដាប់សេចក្ដីថ្លែងរៀបរាប់អំពីសេចក្ដីទុក្ខសោកវេទនាអំពីផលប៉ះពាល់របស់ដើមបណ្ដឹង រដ្ឋប្បវេណីនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនបួនរូបគឺ TCW -- TCCP-100, TCCP-149, TCCP-170 និង TCCP-117 សូមភាគីនៃរឿងក្ដី និងសាធារណជនជ្រាប។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួន លោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅ កាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ។ ហើយឲ្យនាំខ្លួនពួកគាត់មកចូលរួមសវនាការនេះវិញនៅព្រឹក ថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនមកនៅត្រឹមបន្ទប់ឃុំខ្លួន មួយស្ថិតនៅក្រោមសាលសវនាការនេះដែលមានរៀបចំឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ សម្រាកចុះ។៚

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*